**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍ ឃុំតានៃ (ខេត្តព្រះសីហនុ)

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ម៉ៅ រដ្ឋា**

**កញ្ញា វណ្ណា ចាន់ថី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ឡឿក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ក.ម៉ៅ រដ្ឋា** និង **ក.វណ្ណ ចាន់ធី** ដែលជានិស្សិតបរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ សូមធ្វើការគោរពគារវៈកិច្ច ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទៅដល់៖

- **លោកឪពុក ម៉ៅ សំអាត** **អ្នកម្ដាយ គួន ចាន់រី**
- **លោកឪពុក ពៅ សុវណ្ណា** **អ្នកម្ដាយ ទួន ប៉ាល់ថន**

កូនៗសូមសម្ដែងនូវកតញ្ញូតាធម៌ជាអនេកប្បការចំពោះលោកអ្នកមានគុណទាំងបួនរូប ដែលបានផ្ដល់កំណើតចិញ្ចឹមបីបាច់ទំនុកបម្រុង ព្រមទាំងបញ្ជូនកូនៗឲ្យចូលសិក្សាចាប់តាំងពីថ្នាក់មត្តេយ្យ រហូតមកដល់សាកលវិទ្យាល័យ។ លើសពីនេះទៅទៀតលោកឪពុកអ្នកម្ដាយគឺជាគ្រូដំបូងបំផុតដែលបានបង្ហាត់បង្រៀន ជួយតម្រង់ទិសដៅ ព្រមទាំងជាខ្នងបង្អែក ជាទីពឹងពំនាក់ដ៏កក់ក្ដៅផងដែរ។

យើងខ្ញុំសូមគោរពដឹងគុណទៅដល់ លោកតា លោកយាយ អ៊ំ ពូ មីង ដែលបានជួយជ្រោមជ្រែង ទំនុកបម្រុង ទាំងផ្នែកសម្ភារៈ ថវិកា និងស្មារតីដោយផ្ដល់នូវការលើកទឹកចិត្តដល់រូបយើងខ្ញុំទាំងពីរ ឲ្យខិតខំសិក្សារៀនសូត្ររហូតមកដល់ពេលនេះ។

សូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** ជាថ្នាក់ដឹកនាំដ៏ខ្ពង់ខ្ពស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា ប្រកបដោយគុណភាពល្អ ដោយផ្ដល់ឱកាសឱ្យនិស្សិតគ្រប់មជ្ឈដ្ឋានទទួលបានឱកាសក្នុងការចូលរៀននៅ ក្នុងសាកលវិទ្យាល័យដែលមានកេរ្តិ៍ឈ្មោះ និងមានកិត្តិនាមល្បីល្បាញមួយនេះ។

ជាពិសេសយើងខ្ញុំសូមគោរពអរគុណចំពោះ លោកសាស្ត្រាចារ្យជំនួយ **ឡើក ពិសោរ** ដែលបានចំណាយពេលវេលា កម្លាំងកាយកម្លាំងចិត្តនៅក្នុងការផ្ដល់ដំបូន្មានចង្អុលបង្ហាញនិងដឹកនាំការសរសេរអត្ថបទសារណាមួយនេះតាំងពីដើមរហូតដល់បានសម្រេចជាស្ថាពរ។ ក្រៅពីនេះក៏សូមអរគុណយ៉ាងជ្រាលជ្រៅទៅដល់សាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន និងផ្ដល់ដំបូន្មានព្រមទាំងឯកសារល្អៗដល់រូបយើងខ្ញុំទាំងពីរ និងនិស្សិតគ្រប់រូប។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរ លោកឪពុក អ្នកម្ដាយ អ្នកមានគុណទាំងអស់ ឯកឧត្តមបណ្ឌិត លោកបណ្ឌិតសាស្ត្រាចារ្យ សាស្ត្រាចារ្យ ព្រមទាំងក្រុមគ្រួសារឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមក្នុងនាមយើងខ្ញុំ ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៤ ជំនាន់ទី១៧ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយយើងខ្ញុំទាំងពីរនាក់ បានធ្វើការពិភាក្សាយ៉ាងល្អិតល្អន់ក្នុងការជ្រើសរើសយកនូវប្រធានបទមួយដែលទាក់ទងនឹងការគ្រប់គ្រប់រដ្ឋបាល និងការអភិវឌ្ឍឃុំមួយក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រធានបទនោះគឺ **ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំតានៃ**។

ចំពោះប្រធានបទមួយនេះគឺជាសមិទ្ធផលថ្មីរបស់យើងខ្ញុំទាំងពីរនាក់ដែលបាន រួបរួមកម្លាំងគ្នា ខិតខំធ្វើការស្រាវជ្រាវរកឯកសារផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រធានបទ និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងចុះទៅស្រាវជ្រាវឯកសារផ្ទាល់នៅសាលាឃុំតានៃ ដែលមានទីតាំងស្ថិតនៅ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីសរសេរអត្ថបទសារណាបញ្ចប់ការសិក្សាមួយនេះឡើងឱ្យបានល្អប្រសើរ។ ចំពោះគោលបំណងនៃការសរសេរអត្ថបទសារណានេះវិញ គឺដើម្បីបង្ហាញទៅដល់សាធារណជនឱ្យបានដឹងកាន់តែស៊ីជម្រៅ ពីការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សមាសភាពថ្នាក់ដឹកនាំ ទិដ្ឋភាពរស់នៅរបស់ប្រជាពលរដ្ឋ ការផ្តល់សេវាសាធារណៈ ពិសេសនោះគឺការអភិវឌ្ឍរបស់ឃុំនេះផ្ទាល់តែម្តង។

ម្យ៉ាងវិញទៀតយើងខ្ញុំសង្ឃឹមថាអត្ថបទសារណាមួយនេះអាចផ្តល់ជាអត្ថប្រយោជន៍ និងជាជំនួយដល់មិត្តអ្នកអាន និងប្អូនៗនិស្សិតជំនាន់ក្រោយដែលមានបំណងចង់ឈ្វេងយល់ពីប្រធានបទមួយនេះទុកគ្រាន់ជាគំនិតក្នុងការត្រិះរិះពិចារណា និងជាឯកសារជំនួយស្មារតី ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសិក្សា។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់រង់ចាំទទួលនូវការរិះគន់ពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់នូវរាល់កំហុសខុសឆ្គងដែលកើតឡើងដោយអចេតនាដើម្បីជាការចូលរួមកែលម្អអត្ថបទសារណាមួយនេះឱ្យកាន់តែមានប្រសិទ្ធភាពល្អជាងមុនទៀត។

# មាតិកា

ទំព័រ

សេចក្តីផ្តើម.........................................................................................................................................................១

**ជំពូកទី១**

**ការគ្រប់គ្រងរដ្ឋបាលឃុំតានៃ**

**ផ្នែកទី១. ភូមិសាស្ត្រ ប្រជាសាស្ត្រ និងសេដ្ឋកិច្ចនៃឃុំតានៃ**

កថាខណ្ឌទី១. ភូមិសាស្ត្រ. .........................................................................................................................៥

កថាខណ្ឌទី២.ប្រជាសាស្ត្រ .........................................................................................................................៦

កថាខណ្ឌទី៣.ស្ថានភាពទូទៅ.......................................................................................................................៨

**ផ្នែកទី២.ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលឃុំតានៃ**

កថាខណ្ឌទី១. ការរៀបចំ ឃុំតានៃ ...............................................................................................................១២

កថាខណ្ឌទី២.ការប្រព្រឹត្តិទៅ នៃរដ្ឋបាលឃុំតានៃ..............................................................................................២០

**ជំពូកទី២**

**ការអភិវឌ្ឍឃុំតានៃ**

**ផ្នែកទី១. ក្របខ័ណ្ឌអភិវឌ្ឍន៍ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ**

កថាខណ្ឌទី១. ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ.....................................................................................២៤

កថាខណ្ឌទី២.យុទ្ធសាស្ត្រអភិវឌ្ឍន៍ ...............................................................................................................២៩

**ផ្នែកទី២. ថវិកានៃការអភិវឌ្ឍ**

កថាខណ្ឌទី១.មូលនិធិឃុំតានៃ.......................................................................................................................៣៤

កថាខណ្ឌទី២.ការអនុម័តថវិការ.....................................................................................................................៣៦

**ជំពូកទី៣**

**សមិទ្ធផលរបស់ឃុំតានៃ**

**ផ្នែកទី១.សមិទ្ធផលនៃផែនការអភិវឌ្ឍន៍**

កថាខណ្ឌទី១. សមិទ្ធផលនៃផែនការអភិវឌ្ឍន៍ឃុំតានៃ .........................................................................................៣៨

**ផ្នែកទី២.បញ្ហាប្រឈម និងដំណោះស្រាយ**

កថាខណ្ឌទី១.បញ្ហាប្រឈម........................................................................................................................ ៤០

កថាខណ្ឌទី២.ដំណោះស្រាយ.......................................................................................................................៤២

កថាខណ្ឌទី៣.ទិសដៅថ្ងៃអនាគត ......................................................................................... ៤៣
**សេចក្តីសន្និដ្ឋាន** ........................................................................................................... ៤៤
**អនុសាសន៍** ..................................................................................................................... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

រដ្ឋបាល គឺជាអង្គការចាត់តាំងសាធារណៈ ក្រោមការដឹកនាំរបស់រដ្ឋាភិបាលក្នុងសកម្មភាពសាធារណៈ ដែលរួមមានការកំណត់វិធានការរកយុត្តិធម៌ ការដឹកនាំ និងការគ្រប់គ្រង ដើម្បីសម្រេចនូវគោលដៅនៃការបម្រើប្រយោជន៍សាធារណៈ ដោយប្រើមធ្យោបាយពិសេសរបស់រដ្ឋាភិបាលគឺ បុព្វសិទ្ធិនៃអំណាចសាធារណៈ និងការបង្ខំធម្មានុរូប។ ក្រុមប្រឹក្សាឃុំ ជារដ្ឋបាលដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ គឺជាតំណាងឱ្យសំឡេងរបស់ប្រជាពលរដ្ឋ។ ហេតុនេះ ក្រុមប្រឹក្សាឃុំត្រូវធានាថា តម្រូវការអភិវឌ្ឍនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវធ្វើឱ្យសម្រេចដោយខ្លួនឯងផ្ទាល់ ឬដោយរដ្ឋបាលប្រភេទផ្សេងទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើមុខងារនានាដែលត្រូវបានផ្ទេរឱ្យថ្នាក់រដ្ឋបាលនោះ។

អាស្រ័យហេតុនេះហើយ សរបញ្ជាក់ឱ្យឃើញថាក្រុមប្រឹក្សាឃុំ ពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួម ជាចំណែកដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រជាជន ជាភ្នែកច្រមុះជំនួសឱ្យរដ្ឋាភិបាល។ បើយើងក្រឡេកទៅមើលឃុំតានៃក្នុងខេត្តព្រះសីហនុ ដែលជាឃុំទើបតែបង្កើតថ្មីក្នុងកំឡុងឆ្នាំ២០១៦ នៅក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់លោកមេឃុំ ក៏ដូចជាការដៅគោលដៅរបស់ឯកឧត្តម គួច ចំរើន ដែលបានណែនាំដល់ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធ ឃើញថាឃុំតានៃពិតជាមានការរីកចម្រើនគួរអោយកត់សម្គាល់ មានការអភិវឌ្ឍឆ្ពោះទៅរកភាពដែលល្អប្រសើរទាំងដែលជាឃុំទើបតែបង្កើតថ្មីក្នុងអាណត្តិទី៤នេះប៉ុណ្ណោះ តែអាចកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើន រីឯធនធានមនុស្សក៏ប្រកបដោយប្រសិទ្ធភាព កាត់បន្ថយអនក្ខរកម្ម និងមានការចូលរួមអំពីសំណាក់ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលឃុំ/ស្រុក ដែលញ៉ាំងឲ្យជីវភាពប្រជាពលរដ្ឋក្នុងតំបន់កាន់តែល្អប្រសើរ ឃុំមានភាពជឿនលឿនទៅមុខ។

ស្របជាមួយនិងការអភិវឌ្ឍក៏មាននូវផលវិបាកមួយចំនួនដូចគ្នា ដែលផលវិបាកទាំងអស់នោះរួមមាន ខ្វះខាតកម្លាំងពលកម្ម ព្រោះមនុស្សវ័យជំទង់ជាច្រើនបានចាកចេញពីស្រុកភូមិកំណើតដើម្បីបន្តការសិក្សានៅទីក្រុង។ ការទន្ទ្រានដីសម្រាប់រស់នៅ និងដាំដុះរបស់ប្រជាពលរដ្ឋ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសង្កេតឃើញថាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឃុំតានៃដែលជាឃុំមួយក្នុងចំណោមឃុំទាំង១៥នៃស្រុកព្រៃនប់ មានការរីកចម្រើនយ៉ាងខ្លាំងទាំងការអភិវឌ្ឍ និងការគ្រប់គ្រង។ ដូចនេះការស្រាវជ្រាវលើប្រធានបទ៖ ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំតានៃ ខេត្តព្រះសីហនុ នេះត្រូវធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

១.តើការគ្រប់គ្រប់រដ្ឋបាលឃុំតានៃរៀបចំយ៉ាងដូចម្តេច?

២.តើកត្តាអ្វីខ្លះជំរុញឱ្យឃុំតានៃមានការអភិវឌ្ឍ?

៣.តើការអភិឌ្ឍឃុំតានៃជួបប្រទះនឹងបញ្ហាប្រឈមអ្វីខ្លះ ហើយត្រូវដោះស្រាយយ៉ាងដូចម្ដេច?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវខាងលើនេះ គឺមានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងថ្មីមួយទៀតសម្រាប់ជាជំនួយដល់សិស្សនិស្សិតជំនាន់ក្រោយ និងបុគ្គលដែលមានបំណងចង់ឈ្វេងយល់ពីចំណេះដឹងទូទៅពាក់ព័ន្ធការគ្រប់គ្រងរដ្ឋបាលឃុំតានៃ និងចង់បង្ហាញពីសមិទ្ធផល រួមទាំងការអភិវឌ្ឍរបស់ឃុំមួយនេះ។ គោលបំណងចម្បងដែលជំរុញដល់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺៈ

១. ឈ្វេងយល់លម្អិតអំពីការរៀបចំ និងគ្រប់គ្រងរដ្ឋបាលឃុំតានៃ។

២. ឈ្វេងយល់អំពីដំណើរការ និងការប្រព្រឹត្តទៅរដ្ឋបាលឃុំតានៃ។

៣. ឈ្វេងយល់លម្អិតអំពីការដំណើរការអភិវឌ្ឍរបស់ឃុំតានៃ និងសមិទ្ធផលដែលសម្រេចបាន។

៤. ឈ្វេងយល់ពីបញ្ហានិងដំណោះស្រាយ ក្នុងការអភិវឌ្ឍឃុំតានៃ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺយើងខ្ញុំបានផ្ដោតសំខាន់ទៅលើការគ្រប់គ្រង់រដ្ឋបាល និងការអភិវឌ្ឍឃុំតានៃ ដែលស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ តែមួយប៉ុណ្ណោះ ពុំមានវិសាលភាពធំផេងទៅលើខេត្តព្រះសីហនុទាំងមូលនោះទេ។ ចំពោះការស្រាវជ្រាវ គឺយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យ លើអ៊ីនធើណេត ប្រមូលឯកសារបទដ្ឋានគតិយុត្តនានា រួមទាំងចុះទៅស្រាវជ្រាវឯកសារផ្ទាល់នៅសាលាឃុំតានៃ ចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទខាងលើ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះ ពលរដ្ឋទូទៅ សិស្សនិស្សិត និងមនុស្សជំនាន់ក្រោយទុកស្វែងយល់បន្ថែម ដើម្បីជាជំនួយទៅដល់ការសិក្សារបស់ពួកគេនាពេលអនាគត ដោយមានការផ្ដោតសំខាន់ទៅលើការគ្រប់គ្រងរដ្ឋបាលឃុំ ការអភិវឌ្ឍភូមិឃុំ និងបានបង្ហាញពីទីតាំងភូមិសាស្ត្រដ៏តូចមួយដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្ដីពី ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំតានៃ គឺគ្រាន់តែជាសារណាបញ្ចប់ការសិក្សាប៉ុណ្ណោះ ដូច្នេះយើងខ្ញុំ ធ្វើការសិក្សាស្រាវជ្រាវដកស្រង់ លើកយក និងប្រមូលទិន្នន័យពាក់ព័ន្ធមួយចំនួនមកសរសេរសារណានេះឡើង ដើម្បីឱ្យមានជាលក្ខណៈបែបវិទ្យាសាស្ត្រ អាចទទួលយកបាន ដែលក្នុងនោះមានដូចជា ទិន្នន័យចម្បង ទិន្នន័យបន្ទាប់បន្សំ និងទិន្នន័យវិភាគ។

**ក. ទិន្នន័យចម្បង**

- ការចុះសិក្សាស្រាវជ្រាវឯកសារនៅសាលាឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- ធ្វើការសម្ភាសន៍ជាមួយមេឃុំ ក្រុមប្រឹក្សា សមាជិក ស្មៀន និងបុគ្គលិកឃុំតានៃ
- ធ្វើការសាកសួរជាក់ស្តែងជាមួយប្រជាពលរដ្ឋមួយចំនួននៅក្នុងឃុំតានៃ
- សុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា។

**ខ. ទិន្នន័យបន្ទាប់បន្សំ**

- ឯកសារគតិយុត្តនានាដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំជាដើម
- សៀវភៅផ្សេងៗដែលទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ឯកសារពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារទទួលបានពីសាស្ត្រាចារ្យដឹកនាំ
- ឯកសារមេរៀនដែលបានសិក្សាកន្លងមក
- ឯកសារដែលទទួលបារតាមរយៈប្រព័ន្ធអ៊ិនធើណេត។

**គ. ទិន្នន័យវិភាគ**

ការប្រមូលឯកសារ ទិន្នន័យ ព័ត៌មានជាច្រើនប្រភេទយកមកធ្វើការវិភាគពណ៌នាយ៉ាងល្អិតល្អន់ ដើម្បីធ្វើ ឱ្យខ្លឹមសារនៃសារណានេះមានអត្ថន័យ និងទឡ្ហីករណ៍ច្បាស់លាស់ ជាពិសេស គឺដើម្បីធ្វើការសិក្សាប្រៀបធៀប និងឆ្លុះបញ្ចាំងរវាងទ្រឹស្តី ជាមួយនឹងការងារជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលនៅឃុំតានៃ។

## ៧ . រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំបានបែងចែកជា ៣ជំពូក គឺ៖

- **ជំពូកទី១ ការគ្រប់គ្រប់រដ្ឋបាលឃុំតានៃ** ក្នុងជំពូកនេះយើងខ្ញុំបែងចែកជា២ផ្នែក៖
  - ផ្នែកទី១ផ្តោតទៅលើ ភូមិសាស្ត្រ ប្រជាសាស្ត្រនិងសេដ្ឋកិច្ចនៃឃុំតានៃ
  - ផ្នែកទី២ផ្តោតទៅលើ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលឃុំតានៃ។ ក្នុងផ្នែកនេះយើងខ្ញុំបានបែងចែកជាពីកថាខណ្ឌ ព្រមជាមួយនឹងការរៀបរាប់ពីការបោះឆ្នោត រចនាសម្ព័ន្ធ និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ។
- **ជំពូកទី២ ការអភិវឌ្ឍឃុំតានៃ** ក្នុងជំពូកនេះយើងខ្ញុំបែងចែកជា២ផ្នែក៖

- ផ្នែកទី១យើងខ្ញុំបានលើកអំពី ក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ដែលមានដូចជា ចក្ខុវិស័យ គោលបំណង និងគោលដៅនៃការអភិវឌ្ឍ។
- ផ្នែកទី២ យើងខ្ញុំបាន ចាប់យកថវិការរបស់ឃុំមកបង្ហាញដែលមាន ស្ថានភាពចំណូល ចំណាយ។

❖ **ជំពូកទី៣ សមិទ្ធផលរបស់ឃុំតានៃ** ក្នុងជំពូកនេះយើងខ្ញុំមាន២ផ្នែកៈ

- ផ្នែកទី១ យើងខ្ញុំបានលើកពី សមិទ្ធផលនៃផែនការអភិវឌ្ឍមកបង្ហាញ ដែលក្នុងនោះយើងខ្ញុំ បានបង្ហាញពី សមិទ្ធផលផ្នែកហេដ្ឋារចនាសម្ព័ន្ធ ផ្នែកសង្គមកិច្ច និងការផ្ដល់សេវាសាធារណៈ។
- ចំពោះផ្នែកទី២ និយាយអំពីបញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងបានលើកយកទិសដៅថ្ងៃអនាគតរបស់ឃុំតានៃមកធ្វើការបង្ហាញ។

# ជំពូកទី១
# ការគ្រប់គ្រងរដ្ឋបាលឃុំតាំង

# ជំពូកទី១
# ការគ្រប់គ្រងរដ្ឋបាលឃុំតានៃ

## ផ្នែកទី១. ភូមិសាស្ត្រ ប្រជាសាស្ត្រ និងសេដ្ឋកិច្ចនៃឃុំតានៃ

### កថាខណ្ឌទី១. ភូមិសាស្ត្រ

**ក.ប្រវត្តិឃុំតានៃ**

មានតំណាលថា កាលពីដើមឡើយមានបុរសកសិករម្នាក់ឈ្មោះនៃ បានមកតាំងទីលំនៅ ព្រមទាំងបានរានដីដាំដុះ ធ្វើស្រែចម្ការ ក្រោយមកមានប្រជាជនឆ្លងកាត់ទីនោះ ឃើញមានស្រែ ចម្ការ ដំណាំ ផ្លែឈើ គួបផ្សំដីមានទំហំទូលំទូលាយផងនោះ នាំឲ្យប្រជាជនចាប់ផ្ដើមនាំគ្នាមកតាំងទីលំនៅជាច្រើនប្រមូលផ្ដុំបង្កើតបានជាភូមិឈ្មោះ « **ភូមិតានៃ** » រហូតក្លាយជាឈ្មោះឃុំគឺ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុចាប់តាំងពី ឆ្នាំ១៩៨០រហូតមកដល់បច្ចុប្បន្ន។

ឃុំតានៃគឺជាឃុំមួយក្នុងចំណោមឃុំទាំង១៥នៃស្រុកព្រៃនប់។ ឃុំតានៃ គឺជាឃុំដែលបានបំបែកចេញពីឃុំជើងគោ តាមអនុក្រឹត្យលេខ១៦៤អនក្រ/បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦។[1] ដោយបានកាត់យក៥ភូមិរបស់ឃុំជើងគោមានភូមិគឺៈ

- ភូមិតានៃ
- ភូមិតាពៅ
- ភូមិស្វាយ
- ភូមិមនោរម្យ
- ភូមិអន្លង់ក្រពើ

**ខ.ភូមិសាស្ត្រឃុំតានៃ**

ឃុំតានៃ មានទីតាំងនៅតាមបណ្ដោយផ្លូវជាតិលេខ៤ពីព្រះសីហនុទៅភ្នំពេញ ឃុំមានទីតាំងនៅប៉ែកខាងត្បូងនៃសាលាស្រុកមានចំងាយប្រមាណ ១៦ គ.ម ពីទីរួមស្រុក ។ ឃុំតានៃមានផ្លូវកៅស៊ូ ចំនួន២ខ្សែៈ

- ❖ ខ្សែទី១លាតសន្ធឹងតាមផ្លូវជាតិលេខ៤ ចំនួន១៣គីឡូម៉ែត្រ
- ❖ ខ្សែទី២តាមបណ្ដោយផ្លូវចូលកំពង់ផែឧញ្ញា ម៉ុងឬទ្ធី៥គីឡូម៉ែត្រ

ឃុំ មានព្រំប្រទល់ៈ

- ខាងជើងទល់និង ឃុំស្ទឹងឆាយ និងឃុំចំការហ្លួងស្រុកកំពង់សិលា
- ខាងកើត ទល់ភ្នំបូកគោខេត្តកំពត
- ខាងត្បូងទល់នឹងឃុំសាមគ្គី និងឃុំជើងគោ

[1] អនុក្រឹត្យលេខ១៦៤អនក្រ/បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ស្ដីពីការបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

- ខាងលិចទល់ ឃុំកែវផុស ស្រុកស្ទឹងហាវ

លក្ខណៈភូមិសាស្ត្ររបស់ឃុំជាតំបន់ភ្នំស្ថិតនៅជាប់ជើងភ្នំបូកគោ មានផ្ទៃដីសរុប១៧,៣២៣,៦៧ ហ.ត ចែកចេញជា៖ ផ្ទៃដីលំនៅដ្ឋានចំនួន២៥៤,៥ហ.ត ផ្ទៃដីកសិកម្ម ១៦.៩៨៨ហ.ត (ក្នុងនោះផ្ទៃដី អាចធ្វើស្រែវស្សាបានចំនួន ២៦១,៨០ហ.ត ផ្ទៃដីដំណាំរយៈពេលវែងខ្លីចំនួន ១៦,៧២៦,២០ហ.ត ) នឹងផ្ទៃដីផ្សេងៗ (ដីព្រៃនិងបឹង)ចំនួន ៨១,១៧ហ.ត។

**កថាខណ្ឌទី២. ប្រជាសាស្ត្រ**

ឃុំតានៃមានប្រជាពលរដ្ឋរស់នៅចំនួន១២៣៣គ្រួសារ មានមនុស្សសរុប៦០៥៥នាក់ ក្នុងនោះស្ត្រី ២៧៤៨នាក់ ស្ត្រីជាមេគ្រួសារមាន ១០,៧០% ទំហំគ្រួសារមធ្យមមាន ៤ទៅ៩នាក់/គ្រួសារ ដង់ស៊ីតេប្រជាជនមានចំនួន៣៤,៩៥នាក់/គ.ម$^2$ ដែនដីរដ្ឋបាលឃុំមានភូមិចំនួន៥ចំណុះ (ភូមិតាពៅ តានៃ មនោរម្យ ស្វាយ និង ភូមិអន្លង់ក្រពើ) ។

**ក.ភាពក្រីក្រ**

ភាពក្រីក្រស្ថិតនៅក្នុងកម្រិតអត្រាក្រោម ៣%នៅដើមឆ្នាំ២០២៣ បើធៀបទៅនឹងដើមឆ្នាំ២០២២ មានអត្រាថយចុះ0.១៥% ។ ដោយឡែកការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទី១៤ឆ្នាំ២០២០ តាមការស្នើសុំឆ្នាំ ២០២១-២០២៣ មានចំនួន៤៤១គ្រួសារ និងគ្រួសារងាយរងហានិភ័យ មានចំនួន៣៧គ្រួសារ (សរុប៤៧៨ គ្រួសារស្មើនិងអត្រា៣៧.៦៣%នៃចំនួនគ្រួសារសរុបក្នុងឃុំ)។

**ខ.សាសនា និងប្រពៃណី**

ឃុំតានៃមានវត្តចំនួនបី និងអាស្រមមួយ

- វត្តសុវណ្ណគិរីវ័ន្ត (វត្តតានៃ) ស្ថិនៅក្នុងភូមិតានៃ មានព្រះសង្ឃគង់នៅចំនួន១៨អង្គ
- វត្តមនោធម្មាភិរម្យ (វត្តដូងប្រេង) ស្ថិតនៅក្នុងភូមិមនោរម្យមានព្រះសង្ឃគង់នៅចំនួន៣អង្គ
- វត្តព្រះស្នាគិរីរុក្ខារាម (វត្តអន្លង់ក្រពើ) ស្ថិតនៅក្នុងភូមិអន្លង់ក្រពើ មានព្រះសង្ឃគង់នៅចំនួន៥អង្គ
- អាស្រមស្វាយស្ថិតនៅក្នុងភូមិស្វាយមានព្រះសង្ឃគង់នៅ៤អង្គ

ចំពោះទំនៀមទម្លាប់ប្រពៃណី គឺធ្វើឡើងតាមប្រពៃណីខ្មែរទូទៅ ដូចជាបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ បុណ្យមាឃបូជា វិសាខបូជា បុណ្យកឋិនទាន...ជាដើម។

**គ.ប្រព័ន្ធអប់រំ**

វិស័យអប់រំ បានទទួលនូវការគាំទ្រពីរាជរដ្ឋាភិបាល ពីមន្ទីរអប់រំ និងបានធ្វើការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធអប់រំ ចាប់ពីថ្នាក់មត្តេយ្យរហូតដល់សាលាអនុវិទ្យាល័យ ធ្វើឲ្យវិស័យអប់រំមានលទ្ធភាពផ្ដល់ការអប់រំ កម្រិតមូលដ្ឋានដល់កុមារស្ថិតក្នុងវ័យសិក្សាទាំងអស់។ ជាពិសេសកុមារដែលជាកូនមកពីគ្រួសារក្រីក្រទទួល បានសេ

វាអប់រំប្រកបដោយសមធម៌ និងមានលទ្ធភាពបញ្ចប់ការសិក្សាអប់រំកម្រិតមូលដ្ឋាន តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

តាមប្រសាសន៍របស់លោកមេឃុំតានៃ ចំពោះប្រព័ន្ធអប់រំក្នុងឃុំតានៃនេះមានសាលាបឋមសិក្សាចំនួន ៦ និងអនុវិទ្យាល័យមួយ

- បឋមសិក្សា ហ៊ុនសែនតានៃ មានលោកគ្រូអ្នកគ្រូចំនួន១១នាក់
- បឋមសិក្សា ហ៊ុនសែនដូងប្រេង មានលោកគ្រូអ្នកគ្រូចំនួន៧នាក់
- បឋមសិក្សា ហ៊ុននាងដំឡូងមី មានលោកគ្រូអ្នកគ្រូចំនួន៥នាក់
- បឋមសិក្សាព្រែកស្វាយ មានលោកគ្រូអ្នកគ្រូចំនួន៤នាក់
- បឋមសិក្សាអន្លង់ក្រពើ មានលោកគ្រូអ្នកគ្រូចំនួន៦នាក់
- បឋមសិក្សា ហ៊ុន សែន មនោរម្យមានលោកគ្រូអ្នកគ្រូចំនួន៦នាក់
- អនុវិទ្យាល័យដូងប្រេងតានៃ មានលោកគ្រូអ្នកគ្រូចំនួន១១នាក់ ។

ក្រៅពីនេះឃុំតានៃ មានទាំងមត្តេយ្យសហគមន៍ និងមត្តេយ្យរដ្ឋដើម្បីជួយសម្រួលដល់កូនៗរបស់ប្រជាពលរដ្ឋដែលនៅឆ្ងាយពីសាលា។

**ឃ.យេនឌ័រ**

ប្រជាពលរស់នៅតាមសហគមន៍ប្រកបដោយភាពស្មើភាព គ្មានអំពើហិង្សា ដោយកន្លងមកក្រុមប្រឹក្សាឃុំ ជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារ បានខិតខំសហការជាមួយបណ្តាលស្ថាប័នជំនាញ និងបណ្តាលអង្គការនានា ជំរុញការផ្សព្វផ្សាយបញ្ជ្រាបគោលគំនិតយេនឌ័រ ដល់សហគមន៍គ្រប់មូលដ្ឋានទូទាំងឃុំ តាមរយៈការអប់រំផ្សព្វផ្សាយពីច្បាប់នានា ដែលពាក់ព័ន្ធនិងបានបង្ហាញពីភាពរស់នៅប្រកបដោយសមភាព និងសមធម៌ រវាងបុរស-ស្ត្រី យល់ដឹងពីសិទ្ធិបញ្ចេញមតិរបស់ស្ត្រី និងតួនាទីស្ត្រីចូលរួមក្នុងការអភិវឌ្ឍសង្គម ការយល់ដឹងនូវបញ្ហាជាមូលដ្ឋានសម្រាប់កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។ ទន្ទឹមនឹងនោះក៏បានជំរុញឱ្យស្ត្រីទទួលយកនូវចំណេះដឹងជំនាញវិជ្ជាជីវៈ លើកកម្ពស់សមត្ថភាពស្ត្រីឈានទៅប្រកបការងារក្នុងសង្គម ដោយសមភាពនិងសមធម៌។

- ស្ត្រីប្រកបមុខរបរធ្វើកសិកម្មជាចម្បងមានអត្រា១១.៩០%បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ១.៩០%។
- ស្ត្រីមានមុខរបរចម្បងក្រៅពីវិស័យកសិកម្មជាចម្បងមានអត្រា៤៣.៥០%បើធៀបទៅនឹងដើមឆ្នាំ ២០១៨មានអត្រាថយចុះ៦.៤០%។
- ស្ត្រីធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្នុងប្រទេសមានអត្រា៥.៣០%បើធៀបទៅនឹងដើមឆ្នាំ ២០១៨ មានអត្រាថយចុះ0.១0%នឹងស្ត្រីធ្វើចំណាកស្រុកទៅក្រៅប្រទេសមានអត្រា១.៧0%បើធៀបទៅនឹង

ដើមឆ្នាំ២០១៨មានអត្រាកើនឡើង០.៧០% ការសម្រេចចិត្តចូលរួមក្នុងចលនាអភិវឌ្ឍន៍ សង្គមដូចជា មេភូមិជាក្រុមប្រឹក្សាឃុំនៅមានកំរិតទាប។

**ង.សេវាសុខភាព**

ឃុំតានៃមានឱសថស្ថាននិងឱសថស្ថានរងមានចំនួន០២កន្លែង។ សុខភាពប្រជាពលរដ្ឋទទួលបាន នូវការផ្តល់សេវាថែទាំព្យាបាលបានទាន់ពេលវេលានិងបានល្អប្រសើរ ការផ្គត់ផ្គង់និងការផ្តល់សេវាថែទាំព្យាបាល សាធារណៈដូចជា ការជួយគាំពារនិងការថែរក្សាការពារសុខភាពផ្តល់នូវអាហារូបត្ថម្ភ និងការចាក់វ៉ាក់សាំងការ ពារដល់ស្ត្រី-កុមារការផ្សព្វផ្សាយបង្កើនការយល់ដឹងពីការការពារថែទាំសុខភាពអនាម័យ និងការអនុវត្តតាមណែ នាំរបស់ក្រសួងសុខាភិបាលពង្រឹងវិធានការទប់ស្កាត់ជម្ងឺឆ្លងនិងការអប់រំបង្កើនការយល់ដឹងពីដល់យុវវ័យពីសុខ ភាពបន្តពូជ តាមរយៈមណ្ឌលសុខភាពស្ថិតនៅក្នុងឃុំជើងគោ និងការបង្កើតបណ្តាញភ្នាក់ងារសុខភាពភូមិ។

**ច.អន្តោប្រវេសន៍ និងការផ្លាស់ប្តូរលំនៅ**

ប្រជាពលរដ្ឋក្នុងឃុំតានៃធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្នុងប្រទេសមានអត្រា៣.៦០% និងធ្វើចំ ណាកស្រុកទៅក្រៅប្រទេសមានអត្រា១.៥០%។ បច្ចុប្បន្នប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរទីលំនៅមករស់នៅក្នុង ឃុំ ភាគច្រើនប្រកបរបរសេវាកម្ម និងកសិកម្ម ការស្នាក់នៅទៅបំពេញការងារនៅតាមបណ្តារោងចក្រ សហគ្រាស កសិដ្ឋានចំការដូង ដែលមាននៅក្នុងឃុំនិងឃុំជាប់ព្រំប្រទល់នឹងរដ្ឋបាលឃុំ ។[2]

## កថាខណ្ឌទី៣.ស្ថានភាពទូទៅ

**ក.ការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច**

នៅក្នុងឃុំតានៃការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច បានផ្អែកទៅលើប្រភពសក្តានុពល ជាច្រើនដែលមាន ស្រាប់ និងកំពុងធ្វើការអភិវឌ្ឍបំពេញតាមភាពរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ចនិងតម្រូវការក្នុងសហគមន៍រួមមាន៖

- វិស័យកសិកម្ម (ផ្ទៃដីស្រែ ចំការដំណាំកសិ-ឧស្សាហកម្ម (ចំការដូងប្រេង កៅស៊ូ) និងដំណាំរយៈពេលខ្លី
- តំបន់អភិវឌ្ឍឧស្សាហកម្ម (រោងចក្រ សហគ្រាស កសិដ្ឋានចំការដូងប្រេង ចិញ្ចឹមសត្វ)
- ទេសចរណ៍ (រមណីយដ្ឋានតាមព្រែក ស្ទឹងក្នុងតំបន់ភ្នំ)
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

**ក.១.កសិកម្ម**

វិស័យកសិកម្មនៅក្នុងឃុំតានៃ បានជំរុញការធ្វើពិពិធកម្មកសិកម្ម និងបរិយាប័ន្នដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលចំពោះការដាំដំណាំគ្រប់ប្រភេទដូចជា បង្កើនកិច្ចសហការផ្តល់សេវាបច្ចេកទេសដំណាំឈើហូប ផ្លែ ដំណាំកសិ-ឧស្សាហកម្ម ដំណាំស្រូវវស្សា ការជួយអន្តរាគមន៍ដល់ដំណាំកសិកម្មសំដៅបង្កើនទិន្នផល ការធ្វើ

[2] សៀវភៅពត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ចឃុំតានៃ

បន្សាំដំណាំទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការវិនិយោគដំណាំកសិ-ឧស្សាហកម្ម និងការបង្កើនផលិតកម្មសត្វ ។

- មនុស្សអាយុ១៨ឆ្នាំឡើង ប្រកបរបរកសិកម្មជាចម្បងមានចំនួន៦៤៨នាក់ ស្មើនិងអត្រា២១.៨០% ក្នុងនោះស្ត្រីមានអត្រា ៩.៥០% ចំនួនមនុស្សប្រកបរបរកសិកម្ម បានថយចុះក្នុងអត្រាប្រមាណ៤.៤០%បើធៀបទៅនឹងដើមឆ្នាំ២០២២។
- ប្រជាជនអត្រាប្រមាណ ១.៦០% មានមុខរបរធ្វើស្រែជាចម្បងនៃគ្រួសារប្រកបរបរកសិកម្មជា ចម្បងសរុបបើធៀបទៅនឹងដើមឆ្នាំ២០២២ មានអត្រាថយចុះប្រមាណ២.៥០%។
- ការងារបង្កបង្កើនផលស្រូវវស្សាអនុវត្តបានលើផ្ទៃដី៩៧.៥% នៃផ្ទៃដីដែលអាចធ្វើស្រែបាន ទិន្នផលមធ្យម១,៥តោន/ហ.តបរិមាណផលស្រូវប្រចាំឆ្នាំនេះប្រជាពលរដ្ឋទទួលបានចំនួនប្រមាណ៦៩គ.ក្រ សម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០២៣។
- ពលរដ្ឋប្រកបរបរដាំដំណាំឈើហូបផ្លែ ដំណាំរួមផ្សំ និងបន្លែជាចម្បងមានអត្រា១១.៤០%នៃគ្រួសារប្រកបរបរកសិកម្មជាចម្បងសរុបបើធៀបនឹងដើមឆ្នាំ២០២២ មានអត្រាថយចុះប្រមាណ១.៣០% និងក្រុមហ៊ុនក្នុងស្រុកវិនិយោគដំណាំដូងប្រេងចំនួន១៤.៦៦៧ ហ.តចំការកៅស៊ូ៣.០០០ ហ.តនិងពលរដ្ឋប្រកបរបរដាំដំណាំឈើហូបផ្លែមានប្រមាណ ១៧១ហ.ត។ បច្ចុប្បន្នក្នុងដែនរដ្ឋបាលឃុំ មានការអភិវឌ្ឍលើកសិដ្ឋានចិញ្ចឹមសត្វ រោចក្រផលិតចំណីសត្វ រោងចក្រកែច្នៃជ័រកៅស៊ូ។
- ប្រជាជនមានរបរចិញ្ចឹមសត្វជាចម្បងមានអត្រា៦.៤០%នៃគ្រួសារប្រកបរបរកសិកម្មជាចម្បងសរុប (បើធៀបនឹងដើមឆ្នាំ២០២២មានអត្រាកើនឡើងប្រមាណ០.៣០% ២០២៣) ។

**ក.២.វិស័យអាជីវកម្ម**

វិស័យអាជីវកម្ម ត្រូវបានបង្កើនលើការគ្រប់គ្រងធ្វើការកែលម្អទីផ្សារ និងតំបន់ទីតាំងផលិតកម្ម អាជីវកម្មសេវាកម្ម ដើម្បីឱ្យការធ្វើអាជីវកម្មប្រកបដោយស្មើភាពនិងការធ្វើចរាចរទំនិញគ្រប់ប្រភេទប្រកបដោយ សុវត្ថិភាពនិងបានបើកទូលាយ ក្នុងការផ្តល់លទ្ធភាពប្រកបរបរសេវាកម្មនានា សម្រាប់ការផ្គត់ផ្គង់ជីវភាពប្រជាពលរដ្ឋបង្កើនកិច្ចសហការជាមួយស្ថាប័នជំនាញ និងវិស័យឯកជនផ្តល់សេវាបច្ចេកទេសជំនាញវិជ្ជាជីវៈ និងសហការជំរុញការផ្តល់ប្រាក់កម្ចីពីមីក្រូហិរញ្ញវត្ថុសម្រាប់បង្កើតមុខរបរ។ ពលរដ្ឋអាយុ១៨ឡើង មានមុខរបរចំបងក្រៅពីវិស័យកសិកម្ម(ផលិតកម្មសេវាកម្ម)មានចំនួន២៣២២នាក់ស្មើនឹង អត្រា៧៨.២% ក្នុងនោះស្ត្រីមាន អត្រា៣៨.៥% បើធៀបទៅនឹងដើមឆ្នាំ២០២២ មានអត្រាកើនឡើង៤.៤០%។

បច្ចុប្បន្នឃុំតានៃមានទីផ្សារមួយកន្លែង មានទីតាំងសិប្បកម្ម និងសេវាកម្មចំនួន១៣៧កន្លែង (មានម៉ាស៊ីនកិនស្រូវ ខ្នាតតូច លក់សំភារៈសំណង់សេវាកម្មលក់ដូរចំណីអាហារ ជួសជុលម៉ូតូជួសជុល លក់គ្រឿងយន្តនិងឧបករណ៍កសិកម្ម និងជួសជុលគ្រឿងអេឡិចត្រូនិក) និងសេវាកម្មទេសចរណ៍។ ពលរដ្ឋក្នុងវ័យ១៧-

២៥ឆ្នាំភាគច្រើនជាកម្មករ កម្មការិនីនៅតាមបណ្តារោងចក្រ ចេញទៅបម្រើការងារនោះនៅតាមបណ្តារោងចក្រ សហគ្រាសដែលមានទីតាំងនៅតាមបណ្តាឃុំ។

**ក.៣.កសិដ្ឋាន**

នៅក្នុងឃុំតានៃមានកសិដ្ឋានចំនួន០១គឺកសិដ្ឋានដូនតាទូត អិមភីក របស់ ឧញ៉ា ម៉ុង រិទ្ធី។ មួយវិញទៀត នាពេលថ្មីៗនេះមន្ទីកសិកម្ម រុក្ខប្រមាញ់ និងនេសាទ បានសហការណ៍ជាមួយរដ្ឋបាលឃុំតានៃក្នុការបង្កើតសហគមន៍ចិញ្ចឹមមាន់ស្រែ សម្រាប់រយៈពេល២ឆ្នាំ (២០២៤-២០២៦) សម្រាប់១៥០គ្រួសារ ដោយមានមន្ត្រីបច្ចេកទេសជួយណែនាំ ជួយរកទីផ្សារ និងផ្តល់ដើមទន់។

**ក.៤.រោងចក្រ**

ឃុំតានៃមានរោងចក្រចំនួន៣កន្លែង៖

- រោងចក្រផលិតចំណីសត្វ (កសិដ្ឋានពាណិជ្ជកម្ម អិមភីកទី៣) របស់ឧញ៉ា ម៉ុង រិទ្ធី ដែលមានទីតាំងស្ថិតនៅភូមិអន្លង់ក្រពើ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- រោងចក្រចម្រាញ់ដូងប្រេង២កន្លែង
- រោងចក្រនំ និងស្ករគ្រាប់

**ក.៥.វិស័យទេសចរណ៍**

រដ្ឋបាលឃុំ បាននឹងកំពុងសហការជាសហគមន៍មូលដ្ឋានធ្វើការកែលម្អរមណីយដ្ឋាន ដែលមានស្រាប់ (រមណីយដ្ឋានធម្មជាតិនៅភូមិអន្លង់ក្រពើ និងភូមិស្វាយ) ឱ្យក្លាយទៅជាតំបន់រមណីយដ្ឋានមានសោភ័ណ្ឌភាពស្រស់ស្អាត និងធ្វើការអភិវឌ្ឍសេវាកម្មនានាដែលបម្រើដល់ភ្ញៀវទេសចរណ៍។ ទន្ទឹមនេះដើម្បីបម្រើដល់ភ្ញៀវទេសចរណ៍ឃុំតានៃមាន៖ ផ្ទះសំណាក់ចំនួន០១ផ្ទះសំណាក់ ភោជនីដ្ឋានចំនួន០៣កន្លែង អាហារដ្ឋានចំនួន២៩កន្លែង អាជីវកម្មខ្នាតតូច(លក់បាយ គុយទាវ)សេវាកម្មខ្នាតតូច(កាត់សក់ ម៉ាស្សា) មានចំនួន៧កន្លែងនិងលក់សំភារៈសិក្សានិងកីឡាមានចំនួន០១កន្លែង។

**ក.៦.គមនាគមន៍**

ស្ថានភាពប្រព័ន្ធគមនាគមន៍ បានផ្តល់ភាពងាយស្រួលដល់ការអភិវឌ្ឍគ្រប់ផ្នែក ឃុំមានប្រព័ន្ធដឹកជញ្ជូនផ្លូវគោក ដោយមានផ្លូវតភ្ជាប់ទៅកំពង់ផែកែវផុស (ស្រុកស្ទឹងហាវ) និងផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៤ ទៅក្នុងមូលដ្ឋានភូមិ។ ក្រុមប្រឹក្សាឃុំធ្វើការស្តារ និងជួសជុលឡើងវិញតាមរយៈការប្រើប្រាស់មូលនិធិឃុំ និងមានការជួយគាំទ្រពីសាលាខេត្ត មន្ទីរអភិវឌ្ឍន៍ជនបទ សាលាស្រុក និងសប្បុរសជនរួមមាន ផ្លូវក្រាលក្រួសក្រហម ផ្លូវក្រាលបេតុង ប្រព័ន្ធផ្លូវទាំងអស់ជាប្រភពសក្តានុពលសំខាន់បានផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារ គឺការធ្វើចរាចរនូវកសិផល និងផលិតផលគ្រប់ប្រភេទទៅទីផ្សារ និងការផ្សាភ្ជាប់ទំនាក់ទំនងទៅ

បណ្ដាក្រុង ស្រុក និងខេត្តផ្សេងៗ។ ក្នុងមូលដ្ឋានឃុំមានរថយន្តធុនតូច និងធុនធំសម្រាប់ដឹកទំនិញ ចំនួន១៧ គ្រឿង និងអ្នកដំណើរ(ទេសចរណ៍) មានចំនួន១៣គ្រឿង។

**ក.៧.ការវិនិយោគ**

វិស័យឯកជន បានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបានធ្វើឲ្យឃុំមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ព្រមទាំងធ្វើឲ្យជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរ និងកាត់បន្ថយភាពក្រីក្រពីមួយឆ្នាំទៅមួយឆ្នាំ។ ស្ថានភាពនៃការវិនិយោគរបស់អ្នកវិនិយោគិនក្នុងស្រុក បាននឹងកំពុងផ្តោតលើវិស័យមួយចំនួនដូចជា ដំណាំដំណាំកសិ-ឧស្សាហកម្ម កសិដ្ឋាន ដូងប្រេង ចំការកៅស៊ូ ចិញ្ចឹមសត្វ រោងចក្រ សហគ្រាស (ផលិតចំណីសត្វ កែច្នៃជ័រកៅស៊ូ) បានផ្តល់លទ្ធភាពដល់ប្រជាជនក្នុងឃុំចូលរួមបម្រើការងារប្រមាណ១៩០៥នាក់ ក្នុងនោះស្រីមានចំនួន៩៣០នាក់។

ប្រភពសក្តានុពលទាំងនេះជាមូលដ្ឋានគ្រឹះសំខាន់ៗសម្រាប់បម្រើដល់ការអភិវឌ្ឍនៅក្នុងមូលដ្ឋាន និងបានលើកស្ទួយនូវជីវភាពប្រពលរដ្ឋ ក្នុងគោលដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតាមសហគមន៍។[3]

**ខ.ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងសវត្ថិភាពសង្គម**

ប្រជាពលរដ្ឋរស់នៅប្រកបដោយ សុខដុមរមនាមានសុវត្ថិភាព និងមានសន្តិសុខសណ្តាប់ធ្នាប់ល្អ។ ដោយយើងបានអនុវត្តនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព តាមរយៈការបង្កើត និងពង្រឹងប្រជាការពារតាមភូមិកិច្ចសហការជាមួយបណ្តាស្ថាប័នជំនាញ និងអង្គការនានា ធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹងពីច្បាប់នានា ដែលពាក់ព័ន្ធដល់កិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍជាមូលដ្ឋាន កាត់បន្ថយនូវអស្ថិរភាពក្នុងសហគមន៍មូលដ្ឋាន និងបង្កើនការចូលរួមពីប្រជាពលរដ្ឋបានល្អប្រសើរ។

បច្ចុប្បន្នមានអាគាររដ្ឋបាលឃុំសម្រាប់ ធ្វើការទំនាក់ទំនងបានល្អប្រសើរ ដែលអាចផ្តល់នូវការប្រាស្រ័យទាក់ទងនិងការផ្តល់ព័ត៌មានទៅថ្នាក់ភូមិ និងមានយន្តការច្រកចេញចូលតែមួយដែលមានលទ្ធភាពងាយ ស្រួលចំពោះផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានសហគមន៍ទូទាំងឃុំ ។

**គ.ការងារបរិស្ថាន និងអន្តរវិស័យ**

**គ.១.បរិស្ថាន**

ការថែរក្សាអនាម័យបរិស្ថានមានភាពល្អប្ររសើរ បង្កើតបាននូវបរិយាកាសល្អ និងធានាបាននូវកិច្ចគាំពារបរិស្ថាន ការអភិរក្ស ជីវចម្រុះ ការរស់នៅរបស់ពលរដ្ឋប្រកបដោយចីរភាព។ ទន្ទឹមនឹងនោះមន្ទីរជំនាញបានធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីច្បាប់ គោលការណ៍ និងវិធានការ នានាស្តីពីការថែរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រនៃការរក្សាសុខភាព អនាម័យ សុវត្ថិភាពចំណីអាហារ និងការសម្អាតអនាម័យបរិស្ថាន

[3] សៀវភៅព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ចឃុំតានៃ

នៅតាមផ្ទះសម្បែង ភូមិឃុំរបស់ខ្លួន។ ផ្តល់ចំណេះដឹងពីការវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដើម្បីភូមិដ្ឋានរបស់យើងមានអនាម័យ បរិស្ថានល្អមានផាសុកភាពសម្រាប់ការរស់នៅ សុខុមាលភាពប្រជាពលរដ្ឋល្អ ជៀសផុតពីការឆ្លងជំងឺទាំងឡាយ។

ក្រុមប្រឹក្សាក៏ដូចរដ្ឋបាលឃុំបាន សហការជាមួយមន្ទីរអង្គភាពជំនាញបង្កើនយល់ដឹងការគ្រប់គ្រង និងពង្រឹងវិធានការទប់ស្កាត់ការបំពុលបរិស្ថាន ដោយការបង្ហូរសំណល់រាវចូលក្នុង ប្រឡាយ អូរ និងតាមទីប្រជុំជន។

**គ.២.ការប្រើប្រាស់ដីធ្លី**

បច្ចុប្បន្នដែនដីរដ្ឋបាល បានប្រើប្រាស់ដីតាមស្ថានភាពនៃការរស់នៅរបស់ប្រជាជន និងតាមការកំណត់របស់រាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ដែលបានកំណត់ក្នុងភូមិសាស្ត្ររបស់ឃុំ គឺមានដី សម្រាប់តំបន់លំនៅឋាន ផ្ទៃដីអភិរក្សតំបន់ឧទ្យានជាតិបូកគោ និងផ្ទៃដីតំបន់ការពារគម្របព្រៃឈើ ។

ប្រជាពលរដ្ឋប្រមាណ ១៣៨គ្រួសារមានប័ណ្ណកម្មសិទ្ធិដីធ្លី ផលធៀបគ្រួសារមានប័ណ្ណកម្មសិទ្ធដីធ្លីក្នុង ១000គ្រួសារមាន៨៣៤គ្រួសារដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី បើធៀបទៅនឹងដើមឆ្នាំ២០១៨ គ្រួសារមានប័ណ្ណកម្មសិទ្ធិដីធ្លីថយចុះចំនួន៤២គ្រួសារ ។

**គ.៣.ធនធានធម្មជាតិ**

បច្ចុប្បន្នការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពពិតជាមានការចាំបាច់ណាស់ សម្រាប់សុខុមាលភាពប្រជាជន។ ធនធានធម្មជាតិនៅមូលដ្ឋានសម្បូរដោយប្រព័ន្ធជីវៈចម្រុះ តំបន់ការពារធនធានធម្មជាតិ តំបន់ការពារជាប់ជើងភ្នំបូកគោ និងតំបន់ការពារព្រៃឈើ ការពារព្រៃបំរុងទុកជាប់ជើងភ្នំ តំបន់ទាំងនោះបានធ្វើនិងកំណត់អត្តសញ្ញាណកម្មក្បាលដីបោះបង្គោលព្រំដី។ ព្រមទាំងបានធ្វើការផ្សព្វផ្សាយបានយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងមានក្រុមការពារបរិស្ថានថែរក្សាជាប្រចាំ។[4]

## ផ្នែកទី២. ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលឃុំតានៃ

## កថាខណ្ឌទី១.ការរៀបចំឃុំតានៃ

### ក.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំតានៃ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ គឺជាការបោះឆ្នោតសកល (បោះដោយផ្ទាល់ពីប្រជាពលរដ្ឋដែលមានសិទ្ធិ ១៨ឆ្នាំឡើងទៅ) សម្រាប់ការជ្រើសរើសតំណាងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន គឺឃុំ។ ជាទូទៅនៅប្រទេសកម្ពុជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំមានអាណត្តិ៥ឆ្នាំម្តង។ គណបក្សដែលទទួលបានអាសនៈ

[4] សៀវភៅទិន្នន័យទូទៅរបស់ឃុំតានៃ

ឬការគាំទ្រច្រើនជាងគេនឹងទទួលបានការដឹកនាំជាមេឃុំ គណបក្សឈ្នះបន្ទាប់នឹងទទួលបានតួនាទីជាជំទប់ទី១ និងទី២។[5]

**ក.១.គណៈបក្សនយោបាយនៅក្នុងឃុំតានៃ**

នៅក្នុងឃុំតានៃមានគណៈបក្សនយោបាយចូលរួមក្នុងការបោះឆ្នោតចំនួន៤ គណៈបក្ស៖

- គណៈបក្សប្រជាជនកម្ពុជា
- គណៈបក្សភ្លើងទៀន
- គណៈបក្សហ៊្វុនស៊ិនប៉ិច
- គណៈបក្សខ្មែររួបរួមជាតិ

**ក.២.លិទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំតានៃ**

លិទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំតានៃ ខេត្តព្រះសីហនុ អាណត្តិទី៥ ឆ្នាំ២០២២ មាន ០៩ការិយាល័យ ទទួលបាន០៩នៃការិយាល័យសរុប

- គណៈបក្សប្រជាជនកម្ពុជា ទទួលបាន ២២៦១ សម្លេង ទទួលបាន០៥អសណ្ណៈ ទទួលបានដំណែងជាប្រធាន ជាមេឃុំ ជាជំទប់ទី១ និងជំទប់ទី២
- គណៈបក្សភ្លើងទៀនទទួលបាន ២៥៩សម្លេងពុំ ទទួលបានអសណ្ណៈ
- គណៈបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៨០សម្លេង ពុំទទួលបានអសណ្ណៈ
- គណៈបក្សខ្មែររួបរួមជាតិទទួលបាន ៣៦សម្លេង ពុំទទួលបានអសណ្ណៈ។[6]

**ក.៣.ក្រុមប្រឹក្សាឃុំតានៃ**

ក្រុមប្រឹក្សាឃុំ គឺជាអង្គការតំណាងប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួន និងជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតក្រោមការចាត់ចែង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។ ក្រុមប្រឹក្សាឃុំ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមាន ប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំរបស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិ ស្របតាមនយោបាយទូទៅរបស់រដ្ឋ។

ក្រុមប្រឹក្សាឃុំ មានតួនាទីពីរប្រភេទគឺ៖

- ❖ តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ និងប្រជាពលរដ្ឋក្នុងឃុំ របស់ខ្លួន។
- ❖ តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

[5] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់

[6] បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៣របស់ឃុំតានៃ

**ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន** រដ្ឋបាលឃុំ មានភារកិច្ចៈ

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែង សេវាសាធារណចាំបាច់ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះ ដំណើរការបានល្អ
- លើកទឹកចិត្តឲ្យមានការបង្កើនជាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឲ្យមានការយោគយល់ អធ្យាស្រ័យទៅវិញទៅ មក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ។

**ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ** រដ្ឋបាលឃុំមានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្ដត់ផ្គង់មធ្យោបាយ សំភារៈ ថវិកា សម្រាប់អនុវត្ត។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្ដល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំតែប៉ុណ្ណោះ។[7]

➢ **សមាសភាព និងសិទ្ធអំណាច**

ក្រុមប្រឹក្សាឃុំ កើតឡើងពីការបោះឆ្នោត ដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ និងមានស្វ័យភាពក្នុងការដឹកនាំ និងគ្រប់គ្រងការងារអភិវឌ្ឍន៍មូលដ្ឋាន។

យោងតាមប្រកាស របស់ក្រសួងមហាផ្ទៃ ស្ដីពីការទទួលស្គាល់សមាសភាព សមាជិកក្រុមប្រឹក្សាឃុំតានៃ[8] និងអនុក្រឹត្យ ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំតានៃ អាណត្តិទី៤[9] សមាសភាពនៃក្រុមប្រឹក្សាឃុំតានៃមានដូចតទៅៈ

១. លោក អ៊ុក សារឿន ជា ប្រធានក្រុមប្រឹក្សា

២. លោក ង៉ែត ច័ន្ទដេត ជា សមាជិក

៣. លោក អ៊ិន ចាត ជា សមាជិក

៤. លោកស្រី រ៉ើក បូផា ជា សមាជិក

៥. លោក កង ភក្ត្រា ជា សមាជិក។

[7] មាត្រា៤១,មាត្រា៤២,មាត្រា៤៣,មាត្រា៤៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ឆ្នាំ២០០១

[8] ប្រកាសលេខ៣៦៦៩ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការទទួលស្គាល់សមាសភាព សមាជិកក្រុមប្រឹក្សា មេឃុំ ជំទប់ទី១ ជំទប់ទី២ នៃឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

[9] អនុក្រឹត្យ-ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំនីមួយៗត្រូវរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ ដើម្បីធានានិរន្តរភាព និងភាពរលូននៃការងាររបស់ក្រុមប្រឹក្សាអាណត្តិចាស់មកក្រុមប្រឹក្សាអាណត្តិថ្មី ការងារចាំបាច់មួយចំនួនដែលក្រុមប្រឹក្សាអាណត្តិថ្មីត្រូវធ្វើបន្ទាប់ពីការប្រកាស ចូលកាន់តំណែងរួមមានដូចខាងក្រោម៖

- ការរៀបចំបទបញ្ជាផ្ទៃក្នុង
- ការបន្តការងារគ្រប់គ្រង និងដឹកនាំរដ្ឋបាលឃុំ សង្កាត់។[10]

ក្រុមប្រឹក្សាឃុំ ជាផ្នែកមួយនៃអំណាចនីតិប្រតិបត្តិរបស់រដ្ឋ ដែលមានន័យថាក្រុមប្រឹក្សាឃុំ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានជាធរមាន។

ក្រុមប្រឹក្សាឃុំ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ រាល់ការអនុវត្តផែនការ កម្មវិធីគម្រោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់។ ក្រុមប្រឹក្សាឃុំ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះផែនការកម្មវិធី និងគម្រោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណា ដែលខ្លួនបានជ្រើសយកក៏ដោយ។[11]

❖ **ប្រធានក្រុមប្រឹក្សា-មេឃុំ**

ប្រធានក្រុមប្រឹក្សាឃុំ ដែលជាមេឃុំ ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសំឡេងឆ្នោតច្រើនជាងគេបង្អស់។ តួយ៉ាងនៅក្នុងឃុំតានៃ លោក **អ៊ុក សារឿន** ជាប្រធានក្រុមប្រឹក្សា ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំតានៃ ខេត្តព្រះសីហនុ អាណត្តិទី៥ ឆ្នាំ២០២២ ដោយគណៈបក្សប្រជាជនកម្ពុជា ទទួលបាន ២២៦១ សម្លេង ទទួលបាន០៥អសណ្ណៈ ទទួលបានដំណែង ជាប្រធាន ជាមេឃុំ ជាជំទប់ទី១ និងជំទប់ទី២។

ប្រធានក្រុមប្រឹក្សាឃុំ មានតួនាទី និងការទទួលខុសត្រូវដូចជា៖

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ
- ធានាថា ក្រុមប្រឹក្សាឃុំបានប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ
- ធានាថា កិច្ចប្រជុំក្រុមប្រឹក្សាឃុំ ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ។

❖ **សមាជិកក្រុមប្រឹក្សាឃុំ**

សមាជិកក្រុមប្រឹក្សាឃុំគឺជាបេក្ខជនដែលត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងបន្ទាប់ពីបេក្ខជនទី១ ចំនួន៤រូបបន្តបន្ទាប់។

[10] សៀវភៅណែនាំ ស្តីពី«ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០២២»

[11] សៀវភៅស្តីពីការ «គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ តាមបែបវិមជ្ឈការ»ខែកក្កដា ឆ្នាំ២០១៧ ដោយក្រសួងមហាផ្ទៃ

ខាងក្រោមនេះគឺជាសមាជិកទាំង៤រូបនៃក្រុមប្រឹក្សាឃុំតានៃ ៖

1. លោក ង៉ែត ច័ន្ទដេត ជា សមាជិក
2. លោក អ៊ិន ចាត ជា សមាជិក
3. លោកស្រី វ៉ើក បូផា ជា សមាជិក
4. លោក កង ភក្ត្រា ជា សមាជិក។

សមាជិកក្រុមប្រឹក្សាមានតួនាទី៖

- ធានាថាក្រុមប្រឹក្សាឃុំប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

**ខ. រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលរបស់ឃុំតានៃ**

ខាងក្រោមនេះជាឈ្មោះ និងតួនាទីក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ឃុំតានៃ៖

➢ **លោក អ៊ុក សារឿន ជាមេឃុំតានៃ**

ត្រូវបំពេញតួនាទីភារកិច្ចដូចខាងក្រោមនេះ៖

- អនុវត្តសេចក្តីសម្រេចក្រុមប្រឹក្សាឃុំ
- អនុវត្តនូវបទប្បញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ
- ធ្វើសេចក្តីរាយការណ៍ អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំរបស់ខ្លួន យ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗ និងជួយដល់ក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំរបស់ខ្លួនប្រគល់ឲ្យជំទប់ ជាជំនួយការរបស់មេឃុំ ក្នុងការអនុវត្តភារកិច្ចដែលមេឃុំប្រគល់ឲ្យ និងជំនួសមេឃុំទៅតាមឋានានុក្រមនៃជំទប់នៅពេលដែលមេឃុំអវត្តមាន។

➢ **លោក ង៉ែត ច័ន្ទដេតជា ជំទប់ទី១**

- ទទួលជួយមេឃុំ លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំស្តីទី ក្នុងករណីដែលមេឃុំអវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ។

➢ **លោក អ៊ិន ចាតជា ជំទប់ទី២**

- ជួយមេឃុំ លើការងារផ្នែករដ្ឋបាលសេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ

- បំពេញការងារជាមេឃុំស្តីទី ក្នុងករណីដែលមេឃុំ និងជំទប់ទី១អវត្តមាន។
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ។

➢ **គណៈកម្មាធិការនានា**

មេឃុំ មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់។ គណៈកម្មាធិការទាំងនោះអាចយកសមាជិកណាម្នាក់ ក្នុងក្រុមប្រឹក្សាឃុំសង្កាត់ឲ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធបោះឆ្នោតណាម្នាក់ក្នុងឃុំរបស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឲ្យធ្វើជាប្រធានក៏បាន។ នៅក្នុងឃុំតានៃមានគណៈកម្មាធិការសំខាន់ៗជាច្រើន ដែលបានចូលរួមបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ក្នុងដែនសម្តកិច្ចរបស់ខ្លួន ដែលគណៈកម្មាធិការទាំងនោះរួមមាន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ (គ.ក.ន.ក) គណៈកម្មាធិការកសាងផែនការ និងថវិការឃុំ គណៈកម្មាធិការលទ្ធកម្ម...។ គណៈកម្មាធិការទាំងនោះមានតួនាទីដូចខាងក្រោម៖

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្ស ឃុំដូចជាការកសាងផែនការ និងថវិកា
- រាយការណ៍អំពីការវិវត្តិការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារ ជាសមត្ថកិច្ចរបស់ខ្លួន។

➢ **លោក គង់ សន្តាន មានតួនាទីជា ស្មៀន**

ស្មៀនឃុំ ជាមន្ត្រីស្ថិតក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលនៃក្រសួងមហាផ្ទៃ ដែលត្រូវបានតែងតាំង និងបម្រើការងារក្រោមរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ។ ស្មៀនឃុំធ្វើការនៅក្នុងសាលាឃុំ និងទទួលខុសត្រូវដោយផ្ទាល់ និងជាប្រចាំចំពោះក្រុមប្រឹក្សាឃុំរបស់ខ្លួន។ នៅក្នុងការបំពេញមុខងាររបស់ខ្លួនស្មៀនឃុំត្រូវតែអព្យាក្រឹត្យ មិនលម្អៀងហើយត្រូវប្រកាន់ឥរិយាបទឱ្យបានស្មើៗគ្នាចំពោះ ប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សមាជិកក្រុមប្រឹក្សាគ្រប់រូបដោយ មិនប្រកាន់និន្នាការនយោបាយ និងចំពោះគណៈកម្មាធិការនានា។ ស្មៀនឃុំ ជាអ្នក ៖

- ជួយក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងគណៈកម្មាធិការនានាបំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ស្របទៅនឹងល័ក្ខខ័ណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានា
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ឬគណៈកម្មាធិការ លើកលែងតែបានទទួលការអនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ មេឃុំ

- ជួយដល់ក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំឱ្យមានក្ដារខៀនព័ត៌មានមួយឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្ដីជូនដំណឹង សេចក្ដីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ និងមេឃុំសម្រាប់ឱ្យសាធារណៈជនទូទៅបានដឹងនូវព័ត៌មានទាំងនោះ។[12]

➢ **បុគ្គលិកឃុំ**

មាត្រា២៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំចែងថា « ឃុំ អាចជ្រើសរើសបុគ្គលិកក្រៅ ក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្ដីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ អាណត្តិបន្ទាប់ »។

➢ **មេភូមិ**

មេភូមិ គឺជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ។ មេភូមិត្រូវរៀបចំចាត់តាំងឲ្យមានអនុប្រធានមួយរូប និងសមាជិកមួយរូបជាជំនួយការ។ ខាងក្រោមនេះជាមេភូមិទាំង៥រូប នៅក្នុងឃុំតានៃ៖

**១.លោក ឡុច សុផលជា មេភូមិតាពៅ**
**២.លោក ឌិន សុខុម ជាមេភូមិមនោរម្យ**
**៣.លោក ឃុន យ៉ាន់ជា មេភូមិអន្លង់ក្រពើ**
**៤.លោក ឈូក ឌឹមជា មេភូមិតានៃ**
**៥.លោក ឈិន សំអាងជា មេភូមិស្វាយ**

ភារកិច្ចរបស់មេភូមិនិងការទទួលខុសត្រូវមានដូចខាងក្រោមនេះ៖

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- តំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បង សម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ
- បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំរបស់ខ្លួន
- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ ឬមេឃុំប្រគល់ឲ្យដើម្បី ធានាសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំអំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ មេឃុំ ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ នៅពេលដែលក្រុមប្រឹក្សាឃុំតម្រូវ ដើម្បីផ្ដល់យោបល់អំពីកិច្ចការ ដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍៖
    + ផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំ អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ

[12] ប្រកាសលេខ ១៣២៩ ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់ក្រសួងមហាផ្ទៃស្ដីពី តួនាទី ភារកិច្ចនិងសិទ្ធរបស់ស្មៀនឃុំ សង្កាត់

+ ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ អំពីរបៀបបង្កើន កសាងសមត្ថភាព និងធនធានរបស់ភូមិ
+ ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំអំពី៖
    - តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ
    - ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំក្នុងភូមិរបស់ខ្លួន
    - ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំក្នុងភូមិរបស់ខ្លួន។

- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ
- ត្រូវធានាផ្តល់ព័ត៌មានជាឯកសារជាសាធារណៈ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ ប្រជាពលរដ្ឋរបស់ខ្លួន។ ឯកសារព័ត៌មានទាំង នោះអាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយ ក្រុមប្រឹក្សាឃុំរបស់ខ្លួន។

**បញ្ជាក់**

មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។

មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ។

ក្រុមប្រឹក្សាឃុំ មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមាន ការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ។

➢ **អនុប្រធានភូមិ**

**១.លោក ឈុន សុខណៃមជា អនុភូមិតាពៅ** **៤.លោក បាន កន្ទល់ជា អនុភូមិតានៃ**

**២.កញ្ញា ម៉ៅ រដ្ឋាជា អនុភូមិមនោរម្យ** **៥.លោក ម៉ម ប្រុសជា អនុភូមិស្វាយ**

**៣.លោក មាស ពៅជា អនុភូមិអន្លង់ក្រពើ**

អនុប្រធានភូមិទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមានដោយមានមូលហេតុច្បាស់លាស់ដូចជា មានជម្ងឺ ឬមានបេសកម្មចេញក្រៅឃុំរបស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ។

➢ **សមាជិកភូមិ**

**១.លោកស្រី ម៉ុក សុភាពជា សមាជិកភូមិតាពៅ** **៤.លោក ញឹក ស៊ីថាជា សមាជិកភូមិតានៃ**

**២.លោក សៅ លន់ជា សមាជិកភូមិមនោរម្យ** **៥.លោក ប៊ុន សុភ័ណ្ឌជា សមាជិកភូមិស្វាយ**

**៣.លោក ហ៊ុយ ហ៊ីនជា សមាជិកភូមិអន្លង់ក្រពើ**

សមាជិកភូមិ ទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

**បញ្ជាក់**

ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំសាមី។

## កថាខណ្ឌទី២.ការប្រព្រឹត្តិទៅនៃរដ្ឋបាលឃុំតានៃ

### ក.កិច្ចប្រជុំក្រុមប្រឹក្សាឃុំតានៃ

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ និងគណៈកម្មាធិការជំនួយការត្រូវធ្វើជាសាធារណៈ។ ប្រធានក្រុមប្រឹក្សាឃុំតានៃ ជាអ្នកកោះអញ្ជើញសមាជិកក្រុមប្រឹក្សារបស់ខ្លួន ឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ។ ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំតានៃ មិនអាចកោះអញ្ជើញប្រជុំបានដោយសារកាលៈទេសពិសេស ឬអវត្តមានរបស់ប្រធានក្រុមប្រឹក្សា ជំទប់រងតាមឋានានុក្រម អាចកោះអញ្ជើញប្រជុំក្រុមប្រឹក្សាស្របតាមច្បាប់ និងលិខិតបទដ្ឋានកំណត់។ គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ត្រូវមានលិខិតអញ្ជើញដែលត្រូវប្រគល់ជូនសមាជិកគ្រប់រូប នៃក្រុមប្រឹក្សាឃុំក្នុងរយៈពេល ៣ថ្ងៃមុនកិច្ចប្រជុំចាប់ផ្តើម។ លិខិតអញ្ជើញត្រូវបញ្ជាក់ពីកន្លែង ពេល ម៉ោង ថ្ងៃ ខែ ឆ្នាំ របៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងត្រូវភ្ជាប់ជាមួយនូវឯកសារនានាប្រសិនបើមាន។

#### ក.១. ប្រភេទកិច្ចប្រជុំ និងគោលការណ៍សំខាន់ៗ

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ មានពីរប្រភេទគឺ កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ៖

**កិច្ចប្រជុំសាមញ្ញ៖** ក្រុមប្រឹក្សាឃុំតានៃ ត្រូវធ្វើការប្រជុំសាមញ្ញយ៉ាងតិចចំនួនមួយដងក្នុងមួយខែ និងមិនត្រូវប្រារព្ធធ្វើឡើងមុន២៥ថ្ងៃ និងលើសពី ៣៥ថ្ងៃបន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ។ ក្រុមប្រឹក្សាឃុំតានៃ ត្រូវអនុម័តប្រតិទិន នៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនសម្រាប់កិច្ចប្រជុំរយៈពេល១២ខែ មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី២ និងប្រតិទិនសម្រាប់កិច្ចប្រជុំលើកក្រោយៗទៀតក្នុងរយៈពេល១២ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងឱ្យបានជាក់លាក់។

**កិច្ចប្រជុំវិសាមញ្ញ៖** កិច្ចប្រជុំវិសាមញ្ញត្រូវប្រារព្ធឡើងក្នុងអំឡុងពេល៣ថ្ងៃ បន្ទាប់ពីប្រធានក្រុមប្រឹក្សាឃុំសម្រេចឱ្យមានការរៀបចំកិច្ចប្រជុំវិសាមញ្ញនេះ ឬបន្ទាប់ពីសមាជិកចំនួន១/៣(មួយភាគបី)យ៉ាងតិច នៃសមាជិកក្រុមប្រឹក្សាទាំងមូល ស្នើសុំឱ្យរៀបចំកិច្ចប្រជុំវិសាមញ្ញ។ ការសម្រេច ឬការស្នើសុំឱ្យមានកិច្ចប្រជុំវិសាមញ្ញ ត្រូវបញ្ជាក់ពីមូលហេតុសមស្រប។

របៀបវារៈ នៃកិច្ចប្រជុំសាមញ្ញចាំបាច់ត្រូវមាន៖

- ការពិនិត្យឡើងវិញ និងអនុម័តកំណត់ហេតុនៃអង្គប្រជុំលើកមុន
- ការពិភាក្សា និងអនុម័តកិច្ចការដែលបានអនុវត្តក្នុងខែ កិច្ចការដែលនៅសេសសល់ និងទិសដៅការងារខែបន្ទាប់
- ការពិភាក្សា និងអនុម័តលើឯកសារដែលបានប្រគល់ជូនសមាជិកក្រុមប្រឹក្សាឃុំ រួមមាន៖
    + ស្ថានភាពនៃការគ្រប់គ្រងប្រើប្រាស់មូលនិធិឃុំ និងចំណូល ចំណាយថវិកាឃុំ សង្កាត់
    + ស្ថានភាពនៃការអនុវត្តគម្រោងនានាដោយរដ្ឋបាលឃុំ
    + ឯកសារផ្សេងៗទៀត។
- បញ្ហាផ្សេងៗ។

**ក.២.ដំណើរការរៀបចំកិច្ចប្រជុំ**

ប្រធានក្រុមប្រឹក្សាឃុំតានៃ ដោយមានស្មៀនឃុំជាជំនួយការត្រូវរៀបចំរបៀបវារៈនៃកិច្ចប្រជុំ។ សមាជិកក្រុមប្រឹក្សាឃុំចំនួន១/៣ នៃសមាជិកក្រុមប្រឹក្សាឃុំ ទាំងមូលមានសិទ្ធិស្នើសុំដាក់បញ្ចូលនូវបញ្ហានានាដែលស្ថិតក្នុងរង្វង់តួនាទី មុខងារ និងអំណាចរបស់ក្រុមប្រឹក្សាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ។ ការស្នើសុំដាក់បញ្ចូលបញ្ហានានាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ ត្រូវមានពាក្យសុំដែលភ្ជាប់ជាមួយនូវរបាយការណ៍ ជាលាយលក្ខណ៍អក្សរ ហើយនិងត្រូវផ្តល់ជូនប្រធានក្រុមប្រឹក្សាឃុំ តាមរយៈស្មៀនឃុំក្នុងរយៈពេលយ៉ាងតិច២ថ្ងៃ មុនការប្រជុំចាប់ផ្តើម។ ស្មៀនឃុំតានៃ ត្រូវរក្សាទុកនូវឯកសារច្បាប់ដើមនៃរបៀបវារៈកិច្ចប្រជុំ ឯកសារ កំណត់ហេតុ និងមាតិកាសំខាន់ៗ នៃកិច្ចប្រជុំនៅក្នុងសាលាឃុំ និងត្រូវថតចម្លងជាឯកសារសម្រាប់បិទផ្សាយឲ្យសាធារណៈជនពិនិត្យមើល។

**ក.៣.អំពីរបៀបរបបប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ដែលអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកក្រុមប្រឹក្សាឃុំលើសពីពាក់កណ្តាល នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូលចូលរួម ជាក់ស្តែងក្រុមប្រឹក្សាឃុំតានៃ មានសមាជិកចំនួន៥រូប ដូចនេះត្រូវមានសមាជិកយ៉ាងតិចចំនួន ៣រូប ចូលរួមក្នុងអង្គប្រជុំ

ក្រុមប្រឹក្សាឃុំតានៃ ត្រូវដំណើរការប្រជុំតាមកម្មវិធីដែលមានតាមលំដាប់លំដោយដូចតទៅ៖

+ ពិនិត្យកូរ៉ុមសម្រាប់ការប្រជុំ
+ ពិនិត្យនិងអនុម័តរបៀបវារៈនៃកិច្ចប្រជុំមានជាអាទិ៍៖
    - ពិភាក្សា និងអនុម័តលើកំណត់ហេតុកិច្ចប្រជុំលើកមុន
    - ពិភាក្សា និងអនុម័តលើឯកសារដែលបានដាក់ជូនសមាជិកក្រុមប្រឹក្សាឃុំ
    - បញ្ហាផ្សេងៗ។

សមាជិកគ្រប់រូប នៃក្រុមប្រឹក្សាឃុំតានៃ មានសិទ្ធិបញ្ចេញមតិយោបល់ និងបោះឆ្នោតអនុម័តនៅគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ។ ស្មៀនឃុំតានៃ និងបុគ្គលិកផ្សេងទៀតដែលតែងតាំងដោយ ក្រុមប្រឹក្សាឃុំ មានសិទ្ធិ

ចូលរួម និងអាចបញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ទៅតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាឃុំតានៃ ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយ។ រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ប្រធានក្រុមប្រឹក្សាត្រូវអញ្ជើញតំណាង២រូបនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ និងប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំតានៃ ដើម្បីចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ។

ក្រុមប្រឹក្សាឃុំតានៃអាចចាត់ឱ្យមានកិច្ចប្រជុំជាសម្ងាត់បាន។ កិច្ចប្រជុំជាសម្ងាត់របស់ក្រុមប្រឹក្សាឃុំ គឺជាការប្រជុំដើម្បីពិភាក្សាលើបញ្ហាដូចតទៅ៖

- ការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ
- អំពីបញ្ហាសន្តិសុខក្នុងឃុំ
- អំពីការរៀបចំគម្រោងដើម្បីធ្វើលទ្ធកម្មអ្វីមួយ
- ការរៀបចំសំណុំរឿងដើម្បីតវ៉ាឬការពារក្តីអ្វីមួយ
- ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងកិត្តិយសបុគ្គល...។

ក្នុងកិច្ចប្រជុំជាសម្ងាត់ ប្រធានក្រុមប្រឹក្សាឃុំ ដោយមានស្មៀនឃុំជាជំនួយការត្រូវពិនិត្យឱ្យបានច្បាស់ថាមានតែសមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំតែប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងអង្គប្រជុំ។

**ក.៤.អំពីកំណត់ហេតុនៃកិច្ចប្រជុំ**

កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ត្រូវកត់ត្រានូវបញ្ហាដូចខាងក្រោម៖

- ថ្ងៃ ខែ ឆ្នាំ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ
- ការបញ្ជាក់អះអាងថាការប្រជុំមានលក្ខណៈស្របច្បាប់ (កូរ៉ុម របៀបវារៈ ការបន្ថែមរបៀបវារៈ...)
- បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ ដែលមានវត្តមាននិងអវត្តមាន
- ឈ្មោះនិងអង្គភាពរបស់អ្នកដែលបានចូលរួមប្រជុំ ប្រសិនបើមាន
- ការអនុម័ត និងចុះហត្ថលេខាលើកំណត់ហេតុ នៃកិច្ចប្រជុំលើកមុន
- សេចក្តីសម្រេច និងលទ្ធផលនៃការបោះឆ្នោតអនុម័តលើបញ្ហាទាំងឡាយក្នុងរបៀបវារៈនៃកិច្ចប្រជុំ រួមទាំងចំណុចដែលបានបន្ថែមក្នុងរបៀបវារៈ
- បញ្ហាផ្សេងៗទៀតដែលត្រូវកត់ត្រា
- ពេលវេលាបិទអង្គប្រជុំ។

ស្មៀនឃុំ ត្រូវជួយដល់ក្រុមប្រឹក្សាឃុំ ដើម្បីរៀបចំកំណត់ហេតុគ្រប់កិច្ចប្រជុំ។

**ក.៥.ការធ្វើសេចក្តីសម្រេច**

គ្រប់ការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ដែលអាចចាត់ទុកជាបានការ លុះត្រាតែ សេចក្តីសម្រេចនោះ ត្រូវបានអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក ក្រុមប្រឹក្សាឃុំទាំ

ងមូល ជាពិសេសការអនុម័តលើបញ្ហាណាមួយ ដូចមានខាងក្រោម៖

- ផែនការអភិវឌ្ឍឃុំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- គម្រោងថវិកាឃុំ
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំណត់កម្រៃសេវាផ្សេងៗ
- ដីកា និងបទបញ្ជាផ្ទៃក្នុងរបស់ឃុំ
- ការដាក់វិន័យសមាជិកក្រុមប្រឹក្សាឃុំណាម្នាក់ដែលស្របទៅតាមមាត្រា៨៤ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ចំពោះការសម្រេចលើកិច្ចការផ្សេងពីនេះអាចចាត់ទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃចំនួនសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំ។ សំឡេងរបស់អធិបតីអង្គប្រជុំ មានឧត្តមានុភាព។ ក្នុងពេលអនុម័តប្រសិនបើមានសំឡេងស្មើ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ និងត្រូវប្រកាសភ្លាមៗនូវចំនួនសំឡេងយល់ព្រម សំឡេងជំទាស់ និងសំឡេងអនុប្បវាទ ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុ។[13]

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។នេះមានន័យថា រដ្ឋបាលឃុំមិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹង គោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

រដ្ឋបាលឃុំគ្មានអំណាចសម្រេចលើវិស័យ ៖

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ ។[14]

---

[13] ប្រការ១,២,៣,៤,៥,៦,៧,៨,៩,១០,១១,២០, នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំតានៃ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២

[14] មាត្រា៤៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ឆ្នាំ២០០១

# ជំពូកទី២

# ការអភិវឌ្ឍឃុំតានៃ

# ជំពូកទី២
# ការអភិវឌ្ឍឃុំតានៃ

## ផ្នែកទី១. ក្របខ័ណ្ឌអភិវឌ្ឍន៍ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

### កថាខណ្ឌទី១. ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ

**ក. ចក្ខុវិស័យនៃការអភិវឌ្ឍឃុំ**

ចក្ខុវិស័យនៃការអភិវឌ្ឍឃុំតានៃ គឺប្រជាពលរដ្ឋមានកម្រិតជីវភាពកើនឡើង មានចំណេះដឹង មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថាន ស្អាត មានអនាម័យ មានសន្តិសុខ សណ្តាប់ធ្នាប់ល្អ និងទទួលបានសេវាសាធារណៈប្រកបដោយសមធម៌ ។[15]

ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ ត្រូវបានផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម ៖

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។ [16]

ដូចនេះការរៀបចំកសាងផែនការអភិវឌ្ឍន៍ ត្រូវបានធ្វើឱ្យមានសង្គតិភាពជាមួយផែនការអភិវឌ្ឍន៍ ស្រុក ខេត្ត និងមានតម្លាភាពគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ការធានាសមធម៌ ការចូលរួមពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និងបានផ្តល់ឱកាសឱ្យមានការចូលរួមផ្ទាល់ពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ(គ.ក.ន.ក)អង្គភាពពាក់ពន្ធ័នានាដែលមានទីតាំងនៅក្នុងឃុំ អង្គការសង្គមស៊ីវិល ក្រុមជនងាយរងគ្រោះ និងប្រជាពលរដ្ឋ នៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២៣-២០២៧) នេះ។

**ខ.គោលបំណងនៃការអភិវឌ្ឍ**

**ខ.១. ផ្នែកសេដ្ឋកិច្ច**

- ពលរដ្ឋមានចំណូលខ្ពស់ពីការធ្វើស្រែ

---

[15] ចង្ខុវិស័យរបស់ឃុំតានៃ

[16] សេចក្តីណែនាំបច្ចេកទេស ស្តីពី ការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ឆ្នាំ២០១៧

- ពលរដ្ឋមានចំណូលខ្ពស់ពីការដាំដំណាំ
- ពលរដ្ឋមានចំណូលខ្ពស់ពីការចិញ្ចឹមសត្វ
- ផ្លូវធ្វើដំណើរដោយប្រកបដោយសុវត្ថិភាព
- ប្រជាពលរដ្ឋធ្វើចំណាកស្រុកត្រូវបានថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ
- ប្រជាពលរដ្ឋទទួលបានប្រាក់ចំណូលពីការធ្វើសេវាកម្ម និងផលិតកម្មកើនឡើង
- ស្ត្រីមានឱកាសរកប្រាក់ចំណូលសម្រាប់ជីវភាពគ្រួសារ
- ប្រជាពលរដ្ឋទទួលបានប្រាក់ចំណូលពីវិស័យទេសចរណ៍
- ការផ្គត់ផ្គង់ថាមពអគ្គិសនីបានគ្រប់តម្រូវការក្នុងមូលដ្ឋាន

**ខ.២.ផ្នែកសង្គមកិច្ច**

- អប់រំកុមារ ៣-៥ឆ្នាំ បានចូលរៀនគ្រប់ៗគ្នា
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា និងអនុវិទ្យាល័យ
- ប្រជាពលរដ្ឋមានចំណេះដឹងនិងបានលុបបំបាត់អនក្ខរភាព
- កាត់បន្ថយការឈឺ និងស្លាប់របស់មាតា ទារក និងកុមារ
- កាត់បន្ថយអត្រាស្លាប់ និងឆ្លងដោយសារជំងឺអេដស៍
- កាត់បន្ថយអត្រាស្លាប់ និងឆ្លងដោយសាររបេងគ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗ
- ក្រុមជនងាយរងគ្រោះទទួលសេវាថែទាំឧបត្ថម្ភគាំពារសុខភាព និងសុវត្ថិភាពល្អប្រសើរ
- ជនពិកា និងកុមារកំព្រាមានលទ្ធភាពនិងសមត្ថភាព ចេញទៅប្រកបរបរតាមទីផ្សារពលកម្ម
- លើកកម្ពស់ឱ្យស្ត្រីបានចូលបម្រើការងារក្នុងសង្គម

**ខ.៣.ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

- កាត់បន្ថយទំនាស់ដីធ្លី
- ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់គ្រួសារ
- បង្កើនការផ្គត់ផ្គង់ទឹកស្អាតឱ្យបានដល់មូលដ្ឋានក្នុងសហគមន៍
- ប្រជាពលរដ្ឋរស់នៅក្នុងបរិស្ថានស្អាត
- ភូមិ និងផ្លូវមិនមានការលិចលង់ដោយសារទឹកភ្លៀង
- បរិស្ថានស្អាតគ្មានការបំពុល
- ធនធានព្រៃឈើ និងសត្វមាននិរន្តរភាព
- ធនធានជលផលមាននិរន្តរភាព

**ខ.៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

- កាត់បន្ថយភាពងាយរងគ្រោះស្រ្តី-កុមារដោយសារការជួញដូរនិងការរំលោភផ្លូវភេទ
- កាត់បន្ថយភាពងាយរងគ្រោះស្រ្តី-កុមារដោយសារអំពើហិង្សាក្នុងគ្រួសារ
- ប្រជាពលរដ្ឋបានយល់ដឹងពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
- សន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានភាពល្អប្រសើរឡើង
- ផ្តល់ការយល់ដឹងត្រៀមបង្ការមិនឱ្យមានគ្រោះថ្នាក់ដោយសារសំណល់ជាតិផ្ទុះសល់ពីសង្រ្គាម
- រដ្ឋបាលឃុំ និងភូមិមានទីកន្លែងល្អប្រសើរសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ

**គ.គោលដៅនៃការអភិវឌ្ឍ**

**គ.១.ផ្នែកសេដ្ឋកិច្ច**

- បង្កើនទិន្នផលស្រូវ៖ ទិន្នផលស្រូវកើនឡើងពី ១.៥ ត/ហាត ទៅ ២ ត/ហាត
- បង្កើនកម្លាំងពលកម្មធ្វើស្រែ៖ ប្រជាពលរដ្ឋដែលមានមុខរបរធ្វើស្រែ និងកើនឡើងពីអត្រា ៤.១០% ទៅអត្រា ៩.៦០%
- គ្រួសារដាំដំណាំគ្រប់ប្រភេទកើនឡើង៖ ប្រជាពលរដ្ឋដែលមានមុខរបរធ្វើចំការ ដាំដំណាំគ្រប់ប្រភេទកើនឡើងពី អត្រា៩.៤០% ទៅអត្រា ១០.៧២%
- ប្រជាពលរដ្ឋមានចំណេះដឹងថែទាំសុខភាពសត្វឱ្យមានភាពល្អប្រសើ និងមានគុណភាពខ្ពស់៖ ផ្តល់ចំណេះដឹងដល់គ្រួសារកសិករចិញ្ចឹមសត្វដើម្បីបង្កើនគ្រួសារចិញ្ចឹមសត្វពីអត្រា៦.១០%ទៅដល់អត្រា ៦.៧០%
- ផ្លូវមានគុណភាពល្អ អាចធ្វើចរាចរណ៍បាន៖ ការស្តារ កសាង ជួសជុល ថែទាំ ពង្រីកផ្លូវ និងរៀបប្រព័ន្ធរំដោះទឹក
- កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ៖ ប្រជាពលរដ្ឋធ្វើចំណាកស្រុកត្រូវបានកាត់បន្ថយពីអត្រា៧.២០% មកត្រឹមអត្រា៥.១៦%
- ប្រជាពលរដ្ឋប្រកបរបរសេវាកម្ម និងផលិតកម្មកើនឡើង៖ ប្រជាពលរដ្ឋប្រកបរបរសេវាកម្មផលិតកម្មកើនដល់អត្រា៧៦.៣៤%
- ស្រ្តីមានចំណេះដឹងចូលរួមប្រកបរបរ ក្រៅពីផលិតកម្ម កសិកម្ម កើនឡើង៖ ស្រ្តីមានមុខរបរសេវាកម្ម និងផលិតកម្ម កើនឡើងពី អត្រា៣២.១០% ទៅ អត្រា៣៥.៥៨%
- ស្រ្តីមានលទ្ធភាពរកប្រាក់ចំណូលតាមទីផ្សាពលកម្មក្នុងមូលដ្ឋាន៖ ស្រ្តីទទួលបានចំណេះដឹងជំនាញវិជ្ជាជីវៈ

- ប្រជាពលរដ្ឋមានលទ្ធភាព និងសមត្ថភាពអាចទទួលចំណូលពីវិស័យទេសចរណ៍ខ្ពស់៖ ប្រជាពលរដ្ឋទទួលបានការផ្តល់ជំនាញវិជ្ជាជីវៈបង្កើនសមត្ថភាពបម្រើ និងរកចំណូលក្នុងវិស័យទេសចរណ៍
- កែលម្អរមណីយដ្ឋាន និងពង្រីកសេវាកម្មទេសចរណ៍៖ រមណីដ្ឋានទេសចរណ៍ និងសេវាកម្មទេសចរណ៍ ចំនួន០១កន្លែងបានធ្វើការស្តានិងអភិវឌ្ឍន៍
- ប្រជាពលរដ្ឋមានអគ្គិសនីគ្រប់ផ្ទះ និងគ្រប់តម្រូវការ៖ ប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ ក្នុងអត្រា ៩៨.៧៨%

**គ.២.ផ្នែកសង្គមកិច្ច**

- បង្កើនការចូលរៀនរបស់កុមារនៅមត្តេយ្យសិក្សា៖កុមារ ៣-៥ ឆ្នាំ បានចូលរៀនពីកម្រិតអត្រា ៤៦.៧០% ទៅអត្រា ៥៥.៨២%
- កុមារអាយុ៦ឆ្នាំបាន ចូលរៀនគ្រប់ៗគ្នា៖ កុមារ៦ឆ្នាំបានចូលរៀនកើនឡើងពីអត្រា ៨៩.៨០% ទៅអត្រា ៩៧.៩០%
- កុមារអាយុ៦-១១ឆ្នាំបានចូលរៀនគ្រប់ៗគ្នា៖ កុមារ៦-១១ឆ្នាំបានចូលរៀនកើនឡើងពីអត្រា ៧៨.៣០% ទៅ អត្រា៩៤.៧០
- កាត់បន្ថយអត្រា បោះបង់ការសិក្សារបស់កុមារ៖ កុមារបោះបង់ចោលការសិក្សាត្រូវបានកាត់បន្ថយ ពីអត្រា ២០.៤០% មកត្រឹម អត្រា៦.៩០%
- លើកកម្ពស់នៃការអនុវត្តកម្មវិធីអក្ខរកម្មនិងក្រោយអក្ខរកម្ម៖ អត្រាអ្នកមិនចេះអក្សរក្រុមអាយុ ១៥-៤៥ បានថយចុះពីអត្រា០.៩០% មកត្រឹមអត្រ ០.៣០%
- លើកកម្ពស់លទ្ធភាពការផ្តល់និងមកទទួលយកសេវាសុខភាព មាតានិងទារក និងការថៃទាំសុខភាព៖ មាតា ទារកនិងកុមារទទួលបានសេវាថៃទាំគាំពារសុខភាព និងការផ្តល់អាហារូបត្ថម្ភ
- លើកកម្ពស់លទ្ធភាពមកទទួលសេវាសុខភាពបន្តពូជ៖ ស្ត្រីក្រុមអាយុ១៥-៤៥ទទួលសេវាអប់រំផ្សព្វផ្សាយការយល់ដឹងនិងសេវាថៃទាំសុភាពអនាម័យនិងបន្តពូជ
- គ្រួសារដែលមានជម្ងឺអេដស៍ មកទទួលយកសេវាថៃទាំសុខភាពបានគ្រប់ៗគ្នា៖ ការផ្តល់សេវានិងការមកទទួលយកសេវាគាំពារជំងឺអេដស៍
- កាត់បន្ថយការឆ្លងជម្ងឺរបេង គ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗនៅតាមគ្រួសារ៖ ប្រជាពលរដ្ឋទទួលបានសេវាគាំពារថៃរក្សា និងមានការយល់ដឹងពីការឆ្លង នៃជំងឺឆ្លងគ្រប់ប្រភេទ
- លើកកម្ពស់ការផ្តល់សេវាថៃទាំឧបត្ថម្ភគាំពារសុខភាព និងសុវត្ថិភាពដល់ក្រុមជនងាយរងគ្រោះនិងក្រុមជនរងគ្រោះ៖ ក្រុមជនងាយរងគ្រោះ និងក្រុមជនរងគ្រោះមានលទ្ធភាពទទួលយក សេវាថៃទាំឧបត្ថម្ភគាំពារសុខភាព និងសុវត្ថិភាពគ្រប់ៗគ្នា

- លើកកម្ពស់ការផ្តល់លទ្ធភាព និងចំណេះដឹងជំនាញវិជ្ជាជីវៈដល់ជនពិកា និងកុមារកំព្រាអាចបំពេញការងារនិងបង្កើតមុខរបរ៖ ជនពិកានិងកុមារកំព្រាអត្រា៦៦.៤០%មានមុខរបរនិងការងារធ្វើតាមស្ថាប័ន
- ស្ត្រីមានសមត្ថភាពនិងចំណេះដឹង និងមានសមភាពការងារស្មើបុរស៖ ការងារសង្គមកើនឡើងពីអត្រា ២៩.៨៥%ដល់អត្រា៤៨.៦០%
- លុបបំបាត់ការរើសអើងចំពោះនារីភេទ៖ ប្រជាពលរដ្ឋ និងជនបង្គោលយេនឌ័រតាមមន្ទីរវិស័យ និងអ្នកពាក់ព័ន្ធមានការយល់ដឹងស្តីពី ការបញ្ជ្រាបយេនឌ័របរិយាប័ន្ន និងសមធម៌សង្គម

**គ.៣.ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

- លុបបំបាត់ការរំលោភបំពានយកដីសាធារណៈជាកម្មសិទ្ធិ៖ ប្រជាពលរដ្ឋបានយល់ដឹងពីច្បាប់ភូមិបាល និងច្បាប់នានាដែលពាក់ព័ន្ធដីធ្លី
- ប្រជាពលរដ្ឋមានប័ណ្ណកម្មសិទ្ធិដីធ្លី៖ប្រជាពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីក្នុង១០០០គ្រួសារមាន ៨០៩,៣ គ្រួសារ
- ពលរដ្ឋមានបង្គន់អនាម័យប្រើប្រាស់គ្រប់គ្រួសារ៖ប្រជាពលរដ្ឋមានបង្គន់អនាម័យ ប្រើប្រាស់មានអត្រា ៩១.១០%
- កាកសំណល់រឹងរាវគ្រប់គ្រងបានល្អ៖ ពលរដ្ឋទទួលបានការអប់រំពីចំណេះដឹងការគ្រប់គ្រង និងទុកដាក់សំណល់
- បញ្ចៀសទឹកជំនន់ទឹកភ្លៀង៖ ស្ពារ ជួសជុលនិងពង្រីកប្រព័ន្ធបង្ហូរទឹកភ្លៀង
- បង្កើនកិច្ចការពារនូវនិរន្តរភាពបរិស្ថាន៖ ប្រជាពលរដ្ឋ អាជីវករ ក្រុមហ៊ុនរោងចក្រ សហគ្រាស និងសប្បុកម្ម បានយល់ដឹងពីការរក្សាទុកដាក់ សំណល់ រាវ និងរឹងដែលជាវត្ថុបំពុលបរិស្ថាន
- ការពារព្រៃឈើនិងសត្វព្រៃឱ្យមាននិរន្តរភាព៖ ប្រជាពលរដ្ឋបានយល់ដឹងពីសារៈប្រយោជន៍នៃព្រៃឈើ និងសត្វព្រៃ
- ប្រជាពលរដ្ឋបានយល់ដឹងពីកិច្ចការពារនិងថែរក្សាធនធានជលផល៖ ប្រជាពលរដ្ឋបានយល់ដឹងពីការនេសាទប្រកបដែលការធានានិរន្តភាពធនធានជលផល
- បង្កើនគ្រួសារប្រកបរបរវារីវប្បកម្ម៖ គ្រួសារប្រកបរបរវារីវប្បកម្មមានអត្រា០.៥០%

**គ.៤- ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

- លុបបំបាត់ពលកម្មកុមារ និងការជួញដូរលើផ្លូវភេទស្ត្រី-កុមារ៖ ប្រជាពលរដ្ឋទទួលបានការយល់ដឹងពីអប់រំនិងផ្សព្វផ្សាយច្បាប់
- ប្រជាពលរដ្ឋយល់ដឹងពីសមភាពយេនឌ័រ៖ អប់រំផ្សព្វផ្សាយពលរដ្ឋបានយល់ដឹងពីច្បាប់អំពើហិង្សា និងការរស់នៅក្នុងសង្គមគ្រួសារប្រកបសមភាព

- លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ៖ អប់រំផ្សព្វផ្សាយប្រជាពលរដ្ឋបានយល់ដឹងពីសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- លើកម្ពស់ជីវភាពគ្រួសារក្រីក្រ៖ គ្រួសារក្រីក្រចំនួន១៣១គ្រួសារ ទទួលបានការជួយឧបត្ថម្ភគាំទ្រលើកកម្ពស់ជីវភាព
- ប្រជាពលរដ្ឋបានយល់ដឹងមកចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់គ្នា៖ប្រជាពលរដ្ឋមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងអត្រា១០០%
- ប្រជាពលរដ្ឋចេះគោរពច្បាប់ចរាចរណ៍ផ្លូវគោក និងការធ្វើដំណើរប្រកបដោយសុវត្ថិភាព៖ ផលធៀបអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរក្នុងប្រជាជន១០ម៉ឺននាក់កាត់បន្ថយត្រឹម៣៤៦នាក់
- ទប់ស្កាត់លុបបំបាត់ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន៖ កាត់បន្ថយផលធៀបគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀនក្នុង១០០០គ្រួសារមានចំនួន៨គ្រួសារ
- ទប់ស្កាត់លុបបំបាត់កាលេងល្បែងស៊ីសង៖ ប្រជាពលរដ្ឋទទួលបានការអប់រំយល់ដឹងពីការប្រព្រឹត្ត ការលេងល្បែងស៊ីសងដែលជាអំពើខុសច្បាប់
- ទប់ស្កាត់លុបបំបាត់អំពើចោរកម្មនានា៖ មូលដ្ឋានសហគមន៍ទទួលបានកិច្ចការពារសន្តិសុខជាប្រចាំ
- ប្រជាពលរដ្ឋបានយល់ដឹងពីគ្រោះថ្នាក់ដោយសារសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម៖ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ដឹងគ្រោះថ្នាក់ដោយសារសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម
- កែលម្អអាគារសាលាឃុំ និងទីធ្លាសាលាឃុំ៖ ធ្វើការជួសជុលកែលម្អអាគារនិងទីធ្លាសាលាឃុំ
- រដ្ឋបាលភូមិមានទីកន្លែងធ្វើការសម្រាប់ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋតាមភូមិចំនួន៥មានទីស្នាក់ការសម្រាប់ការងាររដ្ឋបាល ។[17]

## កថាខណ្ឌទី២.យុទ្ធសាស្ត្រអភិវឌ្ឍន៍

### ក.យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

- ជំរុញការស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។
- បង្កើនការផ្តល់ចំណេះដឹងផ្នែកបច្ចេកទេសដាំដំណាំស្រូវបង្កើនទិន្នផលស្រូវ។
- ជំរុញការផ្តល់និងផ្សព្វផ្សាយពូជស្រូវដែលមានទិន្នផលខ្ពស់ ពង្រឹងសេវាផ្សព្វផ្សាយកសិកម្ម។
- ពង្រឹងការផ្សព្វផ្សាយនិងលើកទឹកចិត្តដល់ប្រជាកសិករនិងការធ្វើស្រែតាមបែបប្រពលវប្បកម្ម។
- ពង្រឹងសមត្ថភាពនិងការគ្រប់គ្រងសហគមន៍កសិកម្ម។
- ជំរុញការផ្តល់បច្ចេកទេសដាំដំណាំ ផ្តល់ពូជដំណាំបង្កើនគុណភាព។

[17] តារាងក្របខណ្ឌអភិវឌ្ឍន៍ ឃុំតានៃ

- ពង្រឹងភ្នាក់ងារកសិកម្មជួយអន្តរាគមន៍ទាន់ពេលវេលា
- បង្កើនការផ្តល់បច្ចេកទេសយល់ដឹងពីសុខភាពសត្វ និងជំងឺឆ្លង។
- បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធទប់ស្កាត់ការនាំចូល និងជួយរកទីផ្សារផលិតផលសត្វជូនកសិករ។
- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។
- ជំរុញការអភិវឌ្ឍប្រព័ន្ធរំដោះ និងបង្ហូរទឹកការពារគុណភាពផ្លូវ។
- សហការបង្កើនការផ្សព្វផ្សាយព័ត៌មានឧតុនិយម។
- ជំរុញការផ្តល់ជំនាញវិជ្ជាជីវៈជំនាញអាជីវកម្ម សិប្បកម្ម និងការសហការផ្តល់ទុនបង្កើតមុខរបរ។
- បង្កើនការយល់ដឹងពីផលប៉ះពាល់នៃការធ្វើចំណាកស្រុក និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព
- បង្កើនកិច្ចសហការជាមួយអង្គការពាក់ព័ន្ធ ជួយផ្តល់ការបណ្តុះបណ្តាលសមត្ថភាពស្ត្រី បង្កើនភាពអង់អាចចូលរួមអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ដើម្បីឲ្យមានជំនឿចិត្តលើខ្លួនឯង ពីការធ្វើអាជីវកម្ម ឬការងាររកប្រាក់ចំណូលផ្សេងៗ ។
- សហការជំរុញការផ្តល់ជំនាញវិជ្ជាជីវៈផ្នែកទេសចរណ៍ បង្កើនធនធានមនុស្សដើម្បីកសាងពង្រីក ហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ និងធ្វើការស្តាអភិវឌ្ឍនូវរមណីយដ្ឋានដែលមានស្រាប់ រមណីយដ្ឋានដែលរងការបំពុលបរិស្ថានឱ្យមានសោភ័នភាពសម្រាប់ភ្ញៀវទេសចរណ៍។
- ពង្រឹងវិធានការការពាររមណីយធម្មជាតិ ។
- បង្កើនកិច្ចសហការជំរុញការរៀបចំបណ្តាញអគ្គិសនី ឱ្យបានដល់ផ្ទះប្រជាពលរដ្ឋនៅមូលដ្ឋាន គ្រប់តាមតម្រូវការ។

**ខ.យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច**

- ជំរុញការអប់រំផ្សព្វផ្សាយ ដល់ឪពុកម្តាយឲ្យយល់ដឹងពីតំម្លៃការសិក្សារបស់កុមារតូចៗ បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍពង្រីកការគាំទ្រតាមគ្រប់រូបភាពឱ្យសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍មានដំណើរការបានល្អប្រសើរ។
- បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងមន្ទីរអប់រំជួយបង្កើតសាលាមត្តេយ្យ និងមត្តេយ្យសហគមន៍បានគ្រប់តាមតម្រូវការ។
- បង្កើនការយល់ដឹងដល់ឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុ ក្រោម៦ឆ្នាំ។

- ពង្រឹងកិច្ចសហការជំរុញការជួយគាំទ្រ ដល់មធ្យោបាយធ្វើដំណើរនានាដល់គ្រួសារ សិស្សក្រីក្រនិង ការផ្តល់អាហារូបករណ៍ បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីតម្លៃនៃការសិក្សា ដល់មូលដ្ឋានដាច់ស្រយាល។
- ពង្រីកការផ្សព្វផ្សាយ និងបង្កើនការប្រមូលកុមារដល់អាយុចូលរៀន (៦-១៤ឆ្នាំ) នៅបឋមសិក្សា និងអនុវិទ្យាល័យ និងការផ្សព្វផ្សាយជំរុញឱ្យប្រជាពលរដ្ឋមានការចូលរួមលើកកម្ពស់អក្ខរកម្ម និងលុបបំបាត់អនក្ខរភាព។
- សហការនិងជំរុញបង្កើតឥណទានកម្ចីការប្រាក់ទាប ដើម្បីផ្តល់ដល់សិក្ខាកាមប្រជាពលរដ្ឋ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈរួច និងគ្មានលទ្ធភាពបង្កើតមុខរបរផ្ទាល់ខ្លួនប្រចាំគ្រួសារ។
- បង្កើនការយល់ដឹងពីការថែរក្សាសុខភាពដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយសម្រាល និងជំរុញការផ្តល់សេវាពិនិត្យផ្ទៃពោះនៅតាមមូលដ្ឋាន បង្កើនការយល់ដឹងពីការសម្រាលកូន និងគាំទ្រមធ្យោបាយធ្វើដំណើរដល់ស្ត្រីមានបញ្ហាពេលសម្រាល។
- បង្កើនការទទួលយកសេវាសុខភាពសម្រាប់កុមារ ការថែទាំសុខភាពប្រជាពលរដ្ឋតាមគ្រួសារឱ្យបានល្អប្រសើរ និងបង្កើនការយល់ដឹងនិងសហការជំរុញការផ្តល់ពីអាហារូបត្ថម្ភដល់ស្ត្រី ទារកនិងកុមារអាយុក្រោម ៥ឆ្នាំ។
- ពង្រឹងនិងពង្រីកការផ្តល់សេវាសុខភាពបន្តពូជ សកម្មភាពពន្យារកំណើត និងការចាក់ថ្នាំការពារដល់ស្ត្រីក្នុងវ័យបន្តពូជ។
- សហការផ្សព្វផ្សាយនិងជំរុញដល់ប្រជាពលរដ្ឋដែលកើតជំងឺអេដស៍ មកទទួលយកសេវាថែទាំសុខភាព និងបង្កើនសកម្មភាពអប់រំផ្សព្វផ្សាយអំពីជំងឺអេដស៍ និងជំងឺកាមរោគ ជំរុញការផ្តល់សេវាថែទាំ គាំពារជំងឺអេដស៍។
- ពង្រឹងនិងពង្រីកសេវាការពារ និងបង្ការការចម្លងពីម្តាយទៅកូន ផ្តល់ការយល់ដឹងជំរុញការថែទាំ គាំពារសុខភាព និងមានវិធានការទប់ស្កាត់នៃការឆ្លងជំងឺគ្រប់ប្រភេទ។
- ពង្រឹងកិច្ចសហការបង្កើនការអប់រំផ្សព្វផ្សាយក្នុងសហគមន៍ ឲ្យគោរពនូវសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលពីវិធានការការពារទប់ស្កាត់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ (ពិសេសពាក់ពាការពារ)។
- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន គ្រប់សហគមន៍ អនុវត្តឲ្យបានម៉ឺងម៉ាត់នូវសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ពីវិធានការការពារសុខភាពអនាម័យដើម្បីការពារទប់ស្កាត់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺរាតត្បាតផ្សេងទៀត។
- បង្កើនការផ្សព្វផ្សាយនូវយុទ្ធសាស្ត្រស្តីពី ការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទជំងឺកូវីដ-១៩។

- បង្កើនកិច្ចសហការជំរុញការផ្តល់សេវាសង្គម ជួយថែទាំឧបត្ថម្ភគាំពារសុខភាពនិងសុវត្ថិភាព បង្កើនកិច្ចសហការបង្កើតសមាគមន៍ជនងាយរងគ្រោះ។
- ផ្សព្វផ្សាយនិងជំរុញក្រុមជនងាយរង និងក្រុមជនរងគ្រោះ មកទទួលយកសេវាថែទាំឧបត្ថម្ភគាំពារសុខភាពនិងសុវត្ថិភាពបង្កើនការផ្តល់ចំណេះដឹងនិងសមត្ថភាពជំនាញវិជ្ជាជីវៈសមស្រប និងការផ្សព្វផ្សាយលុបបំបាត់ភាពរើសអើង។
- សហការជាមួយមន្ទីរជំនាញចុះអង្កេតស្រាវជ្រាវកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រចំពោះក្រុមគ្រួសារងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយជំរុញឱ្យគ្រប់ស្ថាប័នរដ្ឋនិងឯកជន អនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ផ្តល់អនុសាសន៍ ឬព័ត៌មានត្រឡប់ផ្តល់ការលើកទឹកចិត្ត ជួយដោះស្រាយរាល់បញ្ហាដែលជួបប្រទះ គាំទ្រជួយផ្តល់ឱកាសឱ្យស្ត្រីចូលរួមក្នុងកម្មវិធីផ្សេងៗដូចជាសិក្ខាសាលា និងជំរុញការផ្តល់ចំណេះដឹងស្តីពីការបង្រ្កាបយេនឌ័របរិយាប័ន្ន និងសមធម៌សង្គម។
- បង្កើនការផ្តល់ព័ត៌មានពីការជ្រើសរើសស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍ សង្គមដល់ស្ត្រីឱ្យបានទាន់ពេល។

**គ.យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួល អាកាសធាតុ**

- សហការជំរុញ ការផ្គត់ផ្គង់អណ្តូងទឹកស្អាត និងបង្កើនការផ្សព្វផ្សាយពីការប្រើប្រាស់ទឹកស្អាត។
- បង្កើនការផ្សព្វផ្សាយពីការប្រើប្រាស់បង្គន់អនាម័យ និងការថែរក្សាអនាម័យបរិស្ថាន បង្កើនការផ្គត់ផ្គង់បង្គន់អនាម័យ និងផ្តល់សម្ភារៈ សាងសង់បង្គន់
- បង្កើនការផ្សព្វផ្សាយយល់ដឹងពីការថែរក្សាអនាម័យបរិស្ថាន។
- បង្កើនការយល់ដឹងពីគ្រប់គ្រង ទុកដាក់សំណល់រឹងរាវ និងការផ្តល់សម្ភារៈទុកដាក់សំណល់រឹង តាមទីសាធារណៈ ទីប្រជុំជននិងគ្រួសារសហគមន៍ និងជំរុញឱ្យមានសេវាប្រមូលនិងដឹកជញ្ជូនសម្រាម។
- ជំរុញការស្តា និងរៀបចំប្រព័ន្ធទុកដាក់បង្ហូរទឹកស្អុយ ការស្តា និងអភិវឌ្ឍន៍ប្រព័ន្ធរំដោះទឹក។
- បង្កើនការយល់ដឹង ពីការគ្រប់គ្រងទុកដាក់ កាកសំណល់រាវមិនឱ្យហូរចូលក្នុងសមុទ្រ និងជំរុញឱ្យបង្កើតប្រ ព័ន្ធការពារ និងទុកដាក់កាកសំណល់រាវ។
- ពង្រឹងវិធានការទប់ស្កាត់ការបង្ហូរកាកសំណល់ និងការចាក់ដីចូលអូរប្រឡាយ និងការបំពានយកដីចំណីផ្លូវនិងប្រឡាយអូរជាកម្មសិទ្ធិ។
- ពង្រឹងវិធានការគ្រប់គ្រងការពារទប់ស្កាត់ការបំផ្លាញព្រៃឈើយកដីជាកម្មសិទ្ធ និងការធ្វើអាជីវកម្មលើព្រៃឈើហួសកម្រិត។

- បង្កើនការយល់ដឹងពីច្បាប់និងសារៈប្រយោជន៍ព្រៃឈើ និងពង្រឹងវិធានការគ្រប់គ្រងការពារទប់ស្កាត់ការប្រម៉ាញ់សត្វ។
- ពង្រឹងវិធានការទបប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក និងការធ្វើអាជីវកម្មក្នុងតំបន់អភិរក្ស។
- សហការជំរុញផ្តល់ជំនាញវារីវប្បកម្ម និងការផ្តល់ពូជនិងទុនបង្កើតរបរ។

**ឃ.យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

- បង្កើនផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់នានា ពង្រឹងការអនុវត្តច្បាប់ភូមិបាល និងជំរុញការចុះវាស់វែង និងផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី។
- បង្កើនការយល់ដឹងពីច្បាប់ប្រើប្រាស់ពលកម្មកុមារ ការជួញដូរមនុស្ស និងពង្រឹងវិធានការទប់ស្កាត់ ការជួញដូរ និងការប្រើប្រាស់ពលកម្មកុមារ។
- បង្កើនការផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សា ពង្រឹងវិធានការអប់រំទប់ស្កាត់នៅគ្រប់សហគមន៍ និងបង្កើនសកម្មភាពជួយសង្គ្រោះជនរងគ្រោះ បន្តពង្រឹងការជួយឧបត្ថម្ភដល់គ្រួសារក្រីក្រ បន្តកិច្ចសហការជួយថែរក្សាគាំពារសុខភាពនិងសុខមាលភាពរបស់គាត់ អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សហការផ្តល់ជំនាញចំណេះដឹង និងការជួយផ្តល់ទុនសម្រាប់បង្កើតមុខរបរ។
- បង្កើនការផ្តល់ចំណេះដឹងស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។
- បង្កើនការយល់ដឹងពីសារៈប្រយោជន៍នៃអគ្រានុកូលដ្ឋាន ជំរុញការផ្តល់សេវា និងបង្កើនការផ្សព្វផ្សាយប្រជាពលរដ្ឋឱ្យមកទទួលយកសេវាអគ្រានុកូលដ្ឋាន។
- បង្កើនការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹង និងទទួលយកសេវាសាធារណៈ តាមច្រកចេញចូលតែមួយ និងលើកកម្ពស់ការសេវាជូនពលរដ្ឋ ប្រកបដោយតម្លាភាពគណនេយ្យភាព និងមានប្រសិទ្ធភាពខ្ពស់
- បង្កើនការយល់ដឹងពីច្បាប់ ពង្រឹងវិធានការអនុវត្តច្បាប់ចរាចរណ៍ ។
- បង្កើនការផ្សព្វផ្សាយនិងពង្រឹងវិធានការទប់ស្កាត់ការលែងសត្វពាហណៈនៅតាមដងផ្លូវសាធារណៈ។
- បង្កើនការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់ដោយសារផលពីការប្រើប្រាស់គ្រឿងញៀន។
- ពង្រឹងវិធានការការពារថែរក្សារក្សាសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន។
- បង្កើនការផ្សព្វផ្សាយនិងពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។
- បង្កើនកិច្ចសហការស្វែងរកមូលនិធិខាងក្រៅ និងប្រើប្រាស់មូលនិធិរដ្ឋបាលឃុំធ្វើការកែលម្អ និងសាងសង់ទីស្នាក់ការភូមិ។[18]

[18] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ឃុំតានៃ(២០២៣-២០២៧)

## ផ្នែកទី២. ថវិកានៃការអភិវឌ្ឍ

### កថាខណ្ឌទី១.មូលនិធិឃុំតានៃ

ថវិការឃុំ គឺជាលិខិតគតិយុត្តិដែលគ្រោងអនុញ្ញាតចំណូល និងចំណាយដោយផ្អែកលើមូលដ្ឋានឆ្នាំ។ ថវិការបស់ឃុំចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ។ ថវិកានោះត្រូវរួមបញ្ចូលរាល់ចំណូលចំណាយរបស់ឃុំ ដោយមិនគិតដល់ប្រភពដើម ឬចរិតលក្ខណះឡើយ។ ថវិការបស់ឃុំ ត្រូវឆ្លុះបញ្ចាំងផងដែររាល់ការចំណាយជាអាទិភាព នៃផែនការអភិវឌ្ឍន៍របស់ឃុំ។

| ល.រ | ការបរិយាយ | សរុបប្រចាំឆ្នាំ | ថវិការទទួលបាន(គិតជារៀល) | | |
|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ០១ | មូលនិធិរដ្ឋបាល | 243,000,000 | 60,750,000 | 60,750,000 | 121,500,000 |
| ០២ | មូលនិធិផ្នែកអភិវឌ្ឍន៍ | 161,000,000 | 40,250,000 | 40,250,000 | 80,500,000 |
| **សរុបរង** | | **404,000,000** | 101,000,000 | 101,000,000 | 202,000,000 |
| ០៣ | ថវិការវិនិយោគ ឬមូលនិធិបន្ថែមផ្នែកអភិវឌ្ឍន៍ | 193,200,000 | 33,750,000 | 33,750,000 | 67,500,000 |
| ០៤ | ថវិការពីប្រភពផ្សេងៗ | 12,000,000 | 0 | 0 | 0 |
| **សរុបរង** | | **205,200,000** | **33,750,000** | **33,750,000** | **67,500,000** |
| **សរុបរួម** | | **609,200,000** | **134,750,000** | **134,750,000** | **268,500,000** |

តារាងមូលនិធិឃុំតានៃ[19]

#### ក.ការអនុវត្តថវិការឃុំ

#### ក.១.ស្ថានភាពចំណូល

ស្ថានភាពចំណូលនៅក្នុងឃុំតានៃ គិតត្រឹមខែឧសភា ឆ្នាំ២០២៤ ទទួលបានពី៖

- មូលនិធិផ្នែករដ្ឋបាល ចំនួន ២៤៣,000,000 រៀល
- មូលនិធិផ្នែកអភិវឌ្ឍន៍ ចំនួន ១៦១,000,000 រៀល
- ថវិការវិនិយោគ ឬមូលនិធិបន្ថែមផ្នែកអភិវឌ្ឍន៍ ចំនួន ១៩៣,២00,000 រៀល
- ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា ចំនួន ១២,000,000 រៀល

#### ក.២.ស្ថានភាពចំណាយ

ស្ថានភាពចំណាយនៅក្នុងឃុំតានៃ ឆ្នាំ២០២៤ ចំណាយទៅលើ៖

- ការទិញ ចំនួន ៣៦,៨៥៦,000 រៀល ជាក់ស្តែងគិតត្រឹមខែឧសភា ឃុំតានៃបានចំណាយអស់ ៨,៩១៤,000 រៀល

[19] តារាងមូលនិធិឃុំតានៃ

- សេវាកម្មចំនួន ៤៧,៦០៦,០០០រៀល ជាក់ស្តែងគិតត្រឹមខែឧសភា ឃុំតានៃបានចំណាយអស់ ១០,៥៦៦,០០០រៀល
- បន្ទុកបុគ្គលិកចំនួន ១៥៣,៤០០,០០០រៀល ជាក់ស្តែងគិតត្រឹមខែឧសភា ឃុំតានៃបានចំណាយអស់ ៥៨,០៦០,០០០រៀល
- អត្ថប្រយោជន៍សង្គមចំនួន ២៧,០៨៨,០០០រៀល ជាក់ស្តែងគិតត្រឹមខែឧសភា ឃុំតានៃបានចំណាយអស់ ៧,៥៨៨,០០០រៀល
- ចំណាយមិនបានព្រៀងទុកចំនួន ១០,០០០,០០០រៀល
- អចលកម្មអរូបីចំនួន ៣៣៤,២៥០,០០០រៀល។ ដូចនេះចំណាយសរុបរបស់ឃុំតានៃគិតត្រឹមខែឧសភាឆ្នាំ២០២៤នេះបានចំណាយអស់៨៥,១២៨,០០០ លានរៀល ស្មើនឹង១៣.៩៧% នៃថវិការសរុបដែលឃុំបានអនុម័ត។

| **ល.រ** | **ផ្នែកចំណូល** | **ឥណទានអនុញ្ញាត** | **ជាក់ស្តែង (បូកយោង)** | **ភាគរយ (%)** |
|---|---|---|---|---|
| ០១ | ចំណូលសារពើពន្ធក្នុងស្រុក | | | |
| ០២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | | | |
| ០៣ | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា | ១២,០០០,០០០ | ១,៨៥៦,០០០ | |
| ០៤ | ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | | | |
| ០៥ | ការឧបត្ថម្ភ និងអំណោយ | ៥៩៧,២០០,០០០ | ២៦៩,៥០០,០០០ | |
| ០៦ | ផលហិរញ្ញវត្ថុ | | | |
| ០៧ | ផលផ្សេងៗ និងផលពិសេស | | | |
| **សរុបចំណូល** | | **៦០៩,២០០,០០០** | **២៧១,៣៥៦,០០០** | |
| ល.រ | ផ្នែកចំណាយ | | | |
| ០១ | ការទិញ | ៣៦,៨៥៦,០០០ | ៨,៩១៤,០០០ | ២៤.១៨ |
| ០២ | សេវាកម្ម | ៤៧,៦០៦,០០០ | ១០,៥៦៦,០០០ | ២២.១៩ |
| ០៣ | បន្ទុកបុគ្គលិក | ១៥៣,៤០០,០០០ | ៥៨,០៦០,០០០ | ៣៧.៨៤ |
| ០៤ | បន្ទុកហិរញ្ញវត្ថុ | | | |
| ០៥ | អត្ថប្រយោជន៍សង្គម | ២៧,០៨៨,០០០ | ៧,៥៨៨,០០០ | ២៨.០១ |
| ០៦ | ឧបត្ថម្ភធន | | | |
| ០៧ | ពន្ធ និងអាករ | | | |
| ០៨ | បន្ទុកពិសេស | | | |
| ០៩ | ទាយជ្ជទានឲ្យដល់រំលោះអចលកម្ម | | | |

| | | | | |
|---|---|---|---|---|
| ១០ | ចំណាយមិនបានគ្រោងទុក | ១០,000,000 | | |
| ១១ | អចលកម្មអរូបីយ | | | |
| ១២ | អចលកម្មរូបីយ | ៣៣៤,២៥០,000 | | |
| ១៣ | អចលកម្មកំពុងដំណើរការ | | | |
| **សរុបចំណាយ** | | **៦០៩,២០០,000** | **៨៥,១២៨,000** | **១៣.៩៧** |

តារាងចំណូល ចំណាយរបស់ឃុំតានៃ[20]

## កថាខណ្ឌទី២.ការអនុម័តថវិការ

អភិបាលខេត្ត និងក្រុង ត្រូវពិនិត្យការអនុលោមភាព និងបញ្ជាក់ទទួលស្គាល់គម្រោងថវិកាមុនថ្ងៃ៣០ ខែវិច្ឆិកា។ ការត្រួតពិនិត្យអនុលោមភាពត្រូវតែឆ្លើយតបទៅនឹងចំណុចខាងក្រោម៖

- ទម្រង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំថវិកា
- តុល្យភាពថវិកា និងការប្រើប្រាស់ចំណូលមូលធន។
- ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ថវិកាឃុំ ដែលទទួលបាន
- រៀបចំគម្រោងឥណទានថវិកាតាមគោលការណ៍ចំណាយចាំបាច់
- តម្រូវការថវិកាវិនិយោគ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ក្នុងផែនការឃុំ។

អភិបាលខេត្ត ក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជម្រើសនៃការចំណាយដែលសម្រេចដោយក្រុមប្រឹក្សាឃុំ ក្រៅពីការពិនិត្យមើលលើលក្ខខណ្ឌទាំងឡាយ ដែលឆ្លើយតបនឹងការត្រួតពិនិត្យអនុលោមភាព។

ប្រសិនបើ គម្រោងថវិកាត្រូវបានបំពេញតាមល័ក្ខខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាព អភិបាលខេត្ត ក្រុង ត្រូវបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា និងចេញសេចក្ដីជូនដំណឹងជាលាយល័ក្ខអក្សរ ជូនមេឃុំ។ សេចក្ដីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកា ដែលមានហត្ថលេខាសង្ខេបរបស់អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ ។

អភិបាលខេត្ត ក្រុងត្រូវចំលងជូនសេចក្ដីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរតនាគារខេត្ត ក្រុង ។

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងបន្ទាន់ ជាលាយល័ក្ខអក្សរដល់មេឃុំ ដោយបញ្ជាក់ពីមូលហេតុហើយណែនាំដល់មេឃុំឲ្យអនុវត្តវិធានការកែតម្រូវ។

[20] តារាងចំណូល ចំណាយរបស់ឃុំតានៃ

មេឃុំ ត្រូវពិនិត្យកែសម្រួលគម្រោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូន ក្រុមប្រឹក្សាឃុំ អនុម័តក្នុងរង្វង់១៥ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាល ខេត្ត ក្រុង ។[21]

ថវិកាសរុបរបស់រដ្ឋបាលឃុំតានៃដែលបានអនុម័តនៅក្នុងឆ្នាំ២០២៤ នេះមានចំនួន ៦០៩,២០០,០០០ រៀល(ប្រាំមួយរយ ប្រាំបួនលានពីរយពាន់រៀល) គិតត្រឹមខែឧសភា ឆ្នាំ២០២៤[22]៖

[21] មាត្រា១៤,១៥,១៦ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

[22] របាយការណ៍ហិរញ្ញវត្ថុរបស់ឃុំ

# ជំពូកទី៣
# សមិទ្ធផលរបស់ឃុំតាំងនៃ

# ជំពូកទី៣
# សមិទ្ធផលរបស់ឃុំតានៃ

## ផ្នែកទី១.សមិទ្ធផលនៃផែនការអភិវឌ្ឍន៍

### កថាខណ្ឌទី១.សមិទ្ធផលនៃផែនការអភិវឌ្ឍន៍ឃុំតានៃ

#### ក.ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

ដោយបានអនុវត្តតាមផែនការដែលបានគ្រោងទុកកន្លងមកយើងឃើញថាឃុំតានៃមានការអភិវឌ្ឍនិងទទួលបានសមិទ្ធផលជាច្រើនគួឲ្យកត់សម្គាល់។ ជាក់ស្តែងផ្លូវបេតុងដែលមាននៅក្នុងឃុំតានៃ គម្រោងផ្លូវដែលបានសាងសង់រួចមានចំនួន ១១ខ្សែ ប្រវែង ៤,១៣០ ម៉ែត្រ ។

- គម្រោងមូលនិធិឃុំមានចំនួន ០៩ ខ្សែ ប្រវែង ២,៣៦០ ម៉ែត្រ ។
- គម្រោងផ្លូវបេតុងរបស់រដ្ឋបាលខេត្តចំនួន០២ ខ្សែ ប្រវែង ១,៧៧០ ម៉ែត្រ ។

នៅក្នុងអាណត្តិទី៤ លោកមេឃុំបានជួសជុលផ្លូវលំប្រវែង ៥០០ម៉ែត្រ និងស្ពានឈើ០១កន្លែង សាងសង់ស្ពានបេតុង ០១កន្លែង មានបណ្តោយ ២០ម៉ែត្រ ទទឹង ៣,៥ម៉ែត្រ ជូនប្រជាពលរដ្ឋនៅភូមិស្វាយ និងផ្លូវ ៥០០ម៉ែត្រ និងស្ពានប្រឡាយប្រវែង ៥០០ម៉ែត្រ នៅភូមិតាពៅ អស់ថវិកា ១២,៥០០ដុល្លា។

ចំពោះថវិការរបស់ក្រុមការងារអភិវឌ្ឍន៍ទៅលើផ្លូវគ្រោះក្រហមចំនួន៨ខ្សែ ដែលស្ថិតនៅក្នុងភូមិតាពៅ ភូមិតានៃ និងភូមិអន្លង់ក្រពើ ភូមិស្វាយ ដែលក្នុងនោះធ្វើថ្មីចំនួន២ខ្សែរ។

នៅដើមឆ្នាំ២០២៤ ឃុំតានៃបានសម្រេចនូវ សមិទ្ធផលមួយចំនួនដូចជា បើកការដ្ឋានស្ថាបនាផ្លូវបេតុមូលនិធិឃុំឆ្នាំ២០២៤ ប្រវែង៥៥០ម៉ែត្រ ព្រមទាំងជុសជុលផ្លូវគ្រួសក្រហម និងសាងសង់ផ្លូវបេតុងផងដែរ។

លោកមេឃុំបានបញ្ជាក់ផងដែរថា ក្នុងឃុំតានៃមានគម្រោងផ្លូវមិនទាន់បានសាងសង់ ត្រូវអនុវត្តបន្តមានចំនួន៣៩ ខ្សែ ប្រវែង២៣,២៧០ ម៉ែត្រ ។ ក្នុងនោះមាន៖

- ភូមិតាពៅ ១០ខ្សែ ប្រវែង ២,៣០៧ ម៉ែត្រ ។
- ភូមិតានៃ ០៥ខ្សែ ប្រវែង ៤,០៨០ ម៉ែត្រ ។
- ភូមិមនោរម្យ ១២ខ្សែ ប្រវែង ៥,២៤៩ ម៉ែត្រ ។
- ភូមិស្វាយ ០៥ ខ្សែប្រវែង ៥,៣១១ ម៉ែត្រ ។
- ភូមិអន្លង់ក្រពើ ០៧ខ្សែ ប្រវែង ៦,៣២៣ ម៉ែត្រ ។[23]

#### ខ.ផ្នែកសង្គមកិច្ច

ទន្ទឹមនឹងនេះរដ្ឋបាលឃុំក៏បានបង្កើនជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស

[23] ប្រព័ន្ធបណ្តាញសង្គម រដ្ឋបាលឃុំតានៃ និងប្រព័ន្ធបណ្តាញសង្គម គង់ សន្តាន សៀនឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ដល់ប្រជាពលរដ្ឋឲ្យចេះដាំដើមឈើហូបផ្លែ បច្ចេកទេសប្រើជីធម្មជាតិ បណ្តុះបណ្តាលជំនាញខ្នាតតូច បណ្តុះបណ្តាលពីការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត ផ្តល់ពូជត្រីអន្ទែង និងជីកស្រះសម្រាប់ចិញ្ចឹមត្រីតាមគ្រួសារ ផ្តល់ពូជគោ ក្របី មាន់ ទា និងពូជបន្លែ ពូជស្រូវដែលផ្តល់គុណភាពខ្ពស់ ព្រមទាំងផ្តល់ជាវគ្គបច្ចេកទេសចិញ្ចឹមសត្វជូនដល់គ្រួសារទាំងអស់នៅក្នុងឃុំ ដើម្បីឲ្យពួកគាត់មានកាយល់ដឹងកាន់តែច្រើន ហើយអាចបង្កើតចំណូលឲ្យគ្រួសារបានជាប្រចាំ។ លើសពីនេះរដ្ឋបាលឃុំក៏បានធ្វើការចុះផ្សព្វផ្សាយពី ផលប្រយោជន៍ក៏ដូចជាបញ្ហាទូរទៅជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំតានៃ ដែលមានដូចជា៖

- បានចុះផ្សព្វផ្សាយការបង្កើតសហគមន៍ចិញ្ចឹមមាន់ស្រែ
- បានចុះផ្សព្វផ្សាយពីការរៀនជំនាញបច្ចេកទេសដល់ប្រជាពលរដ្ឋដែលមានប័ណ្ណសមធម៌នៅក្នុងមូលដ្ឋានឃុំតានៃ ។
- ចុះផ្សព្វផ្សាយគោលនយោបាយភូមិឃុំមានសុវត្ថិភាពដល់សិស្សានុសិស្សអនុវិទ្យាល័យដូងប្រេងតានៃ
- ចុះផ្សព្វផ្សាយការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ជូនដល់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយគោលនយោបាយភូមិឃុំមានសុវត្ថិភាព ជូនប្រជាពលរដ្ឋ
- បានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយអាណាព្យាបាលសិស្សដែលធ្លាក់មធ្យមភាគ
- ផ្សព្វផ្សាយជំរុញឳពុកម្តាយនាំកូនគ្រប់អាយុចូលរៀន ឲ្យបានចូលរៀនគ្រប់ៗគ្នា
- ផ្សព្វផ្សាយពីអនាម័យបរិស្ថាន
- ផ្សព្វផ្សាយច្បាប់ជលផល
- ផ្សព្វផ្សាយច្បាប់ព្រៃឈើ
- បង្កើតសហគមន៏ព្រៃឈើ
- ទប់ស្កាត់បទល្មើសនេសាទ
- ដាក់លូរំដោះទឹកចេញពីភូមិ
- ផ្សព្វផ្សាយពីការគ្រប់គ្រងកាកសំណល់...។

លើសពីនេះ តាមប្រសាសន៍លោក អ៊ុក សារឿន មេឃុំតានៃលោកបានបញ្ជាក់ថានៅចុងឆ្នាំ២០២៤ ឬដើមឆ្នាំ២០២៥ ឃុំតានៃនឹងមានមន្ទីពេទ្យបង្អែកក្នុងឃុំតានៃផ្ទាល់ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[24]

[24] ប្រព័ន្ធបណ្តាញសង្គម រដ្ឋបាលឃុំតានៃ, ប្រព័ន្ធបណ្តាញសង្គម អ៊ុក សារឿនមេឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងប្រព័ន្ធបណ្តាញសង្គម សេក សុភា នាយប៉ុស្តិ៍នគរបានរដ្ឋបាលឃុំតានៃស្រុលព្រៃនប់ខេត្តព្រះសីហនុ

**គ.ការផ្តល់ការងារផ្តល់សេវាសាធារណៈ**

នៅឃុំតានៃ ប្រជាពលរដ្ឋទទួលបានសិទ្ធស្មើរៗគ្នា ទៅលើសេវាសាធារណៈនៅការិយាល័យច្រកចេញចូលតែមួយរបស់ឃុំ ដែលនៅទីនោះមានបិទផ្ទាំងតារាង ប្រភេទឯកសារដែលឃុំមានសិទ្ធសម្រេច រយះពេលធ្វើជូន និងតម្លៃសេវា ដែលមានវិក័យប័ត្រត្រឹមត្រូវ។ ពិសេសជាងនេះទៅទៀតនោះ ក្រុមប្រឹក្សាឃុំ ដែលមានលោក អ៊ុក សារឿន ជាប្រធាន និងជាមេឃុំ លោកតែងតែចុះទៅផ្ទាល់ដល់គេហដ្ឋានប្រជាពលរដ្ឋ ដើម្បីធ្វើអាត្រានុកូលដ្ឋានដល់ទារកទើបនឹងកើត ព្រមទាំងចុះធ្វើសំបុត្រមរណភាពជូនប្រជាពលរដ្ឋផ្ទាល់ផងដែរ។

ខាងក្រោមនេះ ប្រភេទសេវាសាធារណៈដែលឃុំតានៃ បានផ្តល់ជូនប្រជាពលរដ្ឋក្នុងឆ្នាំ២០២៤ (គិតត្រឹមខែឧសភា)៖

- សំបុត្រកំណើត ៣៨ ច្បាប់
- សំបុត្របញ្ជាក់កំណើត ចំនួន ៤១ ច្បាប់
- សំបុត្រអាពាហ៍ពិពាហ៍ ចំនួន ៣៤ ច្បាប់
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ចំនួន 0 ច្បាប់
- សំបុត្រមរណៈភាព ចំនួន ១២ ច្បាប់
- សេចក្តីចម្លងសំបុត្រកំណើត ចំនួន ៧ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចំនួន ៩ ច្បាប់
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចំនួន ៥២ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ចំនួន 0 ច្បាប់
- សេចក្តីចម្លងសំបុត្រមរណៈភាព ចំនួន ១៧ ច្បាប់
- លិខិតបញ្ជាក់លំនៅដ្ឋាន ចំនួន ៣៤ ច្បាប់
- លិខិតបញ្ជាក់ភាពនៅលីវ ចំនួន ២៩ ច្បាប់។[25]

## ផ្នែកទី២. បញ្ហាប្រឈម និងដំណោះស្រាយ

### កថាខណ្ឌទី១. បញ្ហាប្រឈម

**ក.ស្ថានភាពបច្ចុប្បន្ន**

ឃុំតានៃបច្ចុប្បន្ន មានស្ថេរភាពសង្គម សុវត្ថិភាព សន្តិភាព ស្របតាមបរិបទសង្គម។ បើក្រឡេកមើលទៅភូមិទាំង៥វិញមានផ្លូវបេតុងថ្មីៗខ្វាត់ខ្វែងសម្រាប់ប្រើប្រាស់ធ្វើដំណើរ។ សាលារៀនសម្រាប់កុមារមានគ្រប់ភូមិ។ ប្រជាពលរដ្ឋរស់នៅដោយមាន សន្តិសុខ សន្តិភាពពេញបរិបូរណ៍ មានជីវភាពកាន់តែប្រសើរឡើង។ ក្រុមប្រឹក្សាឃុំ អាជ្ញាធរពាក់ព័ន្ធ តែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះប្រជាជនទូទៅស្មើៗគ្នាដោយគ្មានការរើសអើង ពណ៌

[25] របាយការស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំ

សម្បុរ សាសនា ខ្ពស់ទាប មានក្រ និងតែងតែខិតខំរិះរកមធ្យោបាយផ្សេងៗ ដើម្បីបំពេញនូវចន្លោះខ្វះខាតដែលជាតម្រូវការចំបាច់របស់ប្រជាជន។

**ខ.បញ្ហាប្រឈម**

ផ្អែកតាមសក្តានុពល និងសមិទ្ធផលក្នុងការអនុវត្តជាក់ស្តែងកន្លងមក ឃុំបាននិងកំពុងជួបប្រទះ បញ្ហាប្រឈមគួរឲ្យកត់សម្គាល់ដូចជា៖

- ទិន្នផលបរិមាណផល និងគុណភាពកសិកម្មនៅមានកម្រិត មិនទាន់ឆ្លើយតបទៅនឹងតម្រូវការស្បៀង និងទីផ្សារ
- កសិករខ្វះទុន
- ខ្វះព័ត៌មានទីផ្សារ
- ការប្រែប្រួលអាកាសធាតុ បណ្តាលឲ្យកើតមានគ្រោះមហន្តរាយធម្មជាតិខុសប្រក្រតី បានធ្វើឱ្យដំណាំកសិកម្មទទួលរងនូវផលប៉ះពាល់ជាច្រើន
- បាត់បង់កម្លាំងពលកម្មលើវិស័យកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំ
- ការកាប់បំផ្លាញតំបន់អភិរក្សធនធានធម្មជាតិ
- ខ្វះបច្ចេកទេសធ្វើវារីវប្បកម្ម
- កំណើននៃការអភិវឌ្ឍគ្រប់វិស័យ នៅក្នុងមូលដ្ឋាន បាននិងកំពុងធ្វើឱ្យស្ថានភាពបរិស្ថានធម្មជាតិ និងបរិស្ថានអនាម័យ ប្រឈមនឹងការគំរាមកំហែង
- ប្រជាជនខ្វះការយល់ដឹងពីការគ្រប់គ្រងកាកសំណល់ ការចោលកាកសំណល់រឹងនៅតាមទីប្រជុំជន និងការបង្ហូរសំណល់រាវចូលក្នុងទឹក ព្រែក ស្ទឹង ប្រឡាយ អូរ និងតំបន់អាជីវកម្មទេសចរណ៍
- ទឹកភ្លៀងជន់លិចនៅទីប្រជុំជនគ្មានប្រព័ន្ធបង្ហូររំដោះទឹកចេញពីភូមិ។
- សំណង់លំនៅឋាននិងសំណង់ផ្សេងៗទៀត
- ការសាងសង់សំណងផ្សេងៗ ពុំទាន់បានត្រឹមត្រូវមានរបៀបរៀបរយ សមស្របទៅនឹងស្ថានភាពដី ឬតាមនគរូបនីយកម្មបញ្ញត្តិ។
- លំនៅឋានបច្ចុប្បន្ន ភាគច្រើនរីកដុះដាលតាមបណ្តោយផ្លូវសំខាន់ និងមួយចំនួនទៀតបានមកតាំងលំនៅលើដីសាធារណៈ តាមដីចំណីផ្លូវ លើផ្ទៃដីកសិកម្ម និងផ្ទៃដីតំបន់ការពារគម្របព្រៃឈើ។
- ភាពអនាធិបតេយ្យការទន្ទ្រាញដីព្រៃយកធ្វើជាកម្មសិទ្ធិនៅតែជាបញ្ហាប្រឈមរបស់រដ្ឋបាលឃុំ ដោយប្រជាពលរដ្ឋខ្វះការយល់ដឹងពីច្បាប់ និងការរំលោភបំពានចំពោះច្បាប់។
- ប្រជាពលរដ្ឋមានប័ណ្ណសមធម៌មិនបានទៅពិនិត្យសុខភាពតាមការណែនាំរបស់គ្រូពេទ្យ។

- ប្រជាពលរដ្ឋមិនសូវយកចិត្តទុកដាក់លើការធ្វើ អត្រានុកូលដ្ឋាន សុំបុត្រអាពាហ៍ពិពាហ៍ សៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណជាដើម។
- ប្រជាពលរដ្ឋមិនសូវយល់ដឹងអំពីឯកសារផ្សេងដែលត្រូវភ្ជាប់មកជាមួយនៅពេលដែល មកទទួលសេវា ដែលបណ្តាលឲ្យការធ្វើឯកសារមានការយឺតយ៉ាវ។
- ខ្វះការចូលរួមពីប្រជាពលរដ្ឋ។
- ប្រព័ន្ធផ្លូវមួយចំនួនត្រូវរងការខូចខាតនិងមួយចំនួនទៀតមានសភាពចាស់ទ្រុឌទ្រោម ត្រូវទឹកហូរកាត់ខូច ដោយគ្មានប្រព័ន្ធលូរំដោះទឹក និងមិនមានថវិកាគ្រប់ គ្រាន់សម្រាប់ធ្វើការស្តារ ថែទាំនិងជួសជុលឡើងវិញ ដែលអាចបំពេញតាមតម្រូវការរបស់មូលដ្ឋាន។
- ប្រជាពលរដ្ឋមិនមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញតាមតម្រូវការទីផ្សារពលកម្ម
- ស្ថានភាពបរិបទវិបត្តិជំងឺឆ្លងសកលកូវីដ បានបន្សល់ទុកនូវភាពអសកម្មជាច្រើនដល់ការអភិវឌ្ឍដោយទីតាំងខ្លះមិនទាន់មានសកម្មភាពពេញលេញនៅឡើយ (ពិសេសវិស័យអចលនទ្រព្យសំណង់អគារមួយចំនួន មិនមានដំណើរការបន្ត) ។

## កថាខណ្ឌទី២.ដំណោះស្រាយ

### ក.ដំណោះស្រាយក្នុងការអភិវឌ្ឍ

#### ក.១-កសិកម្ម

- បណ្តុះបណ្តាប្រជាកសិករ ពីការដាំដុះ ថែទាំ ដំណាំកសិកម្មដើម្បីទទួលបានទិន្នផលខ្ពស់
- ជម្រុញឲ្យប្រជាពលរដ្ឋធ្វើកសិកម្ម និងដាំដុះឲ្យបានកាន់តែច្រើន
- បង្កើនប្រព័ន្ធធារាសាស្ត្រ
- ផ្តល់កម្ចីជាដើមទុកជូនប្រជាពលរដ្ឋដែលខ្វះខាត
- បណ្តុះបណ្តាលការដាំដុះបែបទំនើបកម្ម
- ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើជីឬថ្នាំគីមី

#### ក.២-សេវាសង្គម

- បញ្ជ្រាបការយល់ដឹងប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយផ្សាយដល់មូលដ្ឋាន
- ណែនាំពីអត្ថប្រយោជន៍នៃប័ណ្ណសមធម៌ឲ្យកាន់តែទូលំទូលាយ
- បង្ខិតសេវាធ្វើអត្រានុកូលដ្ឋានឲ្យកាន់តែកៀកប្រជាពលរដ្ឋ
- បង្កើនសេដ្ឋកិច្ចប្រជាជន និងកាត់បន្ថយចំណាកស្រុកតាមរយៈ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
- សហការណ៍ជាមួយក្រសួងដែនដី ក្នុងការធ្វើប្លង់កម្មសិទ្ធដីធ្លី ដើម្បីជៀសវាងជម្លោះដីធ្លី
- ឃុំនៅយ៉ាងជិតស្និតជាមួយប្រជាពលរដ្ឋក្នុងការដោះស្រាយបញ្ហាផ្សេងៗ
- ឆ្លើយតបទៅនឹងតម្រូវការសង្គមបានឆាប់រហ័ស

**ក.៣-បរិស្ថាន**

- ណែនាំប្រជាជន ពីការទុកដាក់សម្រាមឲ្យមានប្រសិទ្ធភាព មិនប៉ះពាល់ដល់បរិស្ថាន និងសុខភាព
- កសាងប្រឡាយ ឬប្រព័ន្ធលូសម្រាប់រំដោះទឹក
- ផ្សព្វផ្សាយឲ្យកាន់តែទូលាយពីផលវិបាកនៃការបាត់បង់ព្រៃឈើ
- បង្កើតទីតាំងសម្រាប់ទុកដាក់សម្រាម
- បង្កើនការណែនាំប្រជាជនដើម្បីកាត់បន្ថយការប្រើប្រាស់ប្លាស្ទីក
- ផ្សព្វផ្សាយឲ្យកាន់តែទូលាយពីការនេសាទខុសច្បាប់
- បង្កើនក្តីស្រឡាញ់បរិស្ថានដល់ប្រជាជន
- លើកទឹកចិត្តចំពោះលំនៅដ្ឋានប្រជាជនដែលមានបរិស្ថានល្អ
- បង្កើនការយល់ដឹង ទៅលើសុខភាព អនាម័យ

**កថាខណ្ឌទី៣.ទិសដៅទៅអនាគត**

ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ ដែលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ឃុំតានៃរំពឹងខ្ពស់ថានឹងប្រែក្លាយឃុំនេះទាំងមូល ទៅជាឃុំសម្បូរបែប ដោយមានផ្លូវថ្នល់ ផ្លូវបេតុង ផ្លូវគ្រួស ផ្លូវលំ សាលារៀនចាប់ពីមត្តេយ្យដល់វិទ្យាល័យ មន្ទីរពេទ្យបង្អែកក្នុងឃុំ វត្តអារាម ធនធានមនុស្ស មានសន្តិសុខ សន្តិភាព សុវត្ថិភាព...។ ចំពោះវិស័យអប់រំ គឺជារឿងចម្បងដែលត្រូវគិតគូរផងដែរ ព្រោះពួកគេគឺជាអ្នកបន្តវេនក្នុងការដឹងនាំសង្គមឲ្យរីកចម្រើនបន្តទៅមុខ នាពេលខាងមុខនេះឃុំតានៃ នឹងចាប់ផ្តើមសាងសង វិទ្យាល័យថ្មីមួយនៅក្នុងឃុំតានៃផ្ទាល់។ លើសពីនេះ ក្រុមប្រឹក្សាឃុំ ធានាដល់កំណើនសេដ្ឋកិច្ច ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចខ្លួន តាមរយៈប័ណ្ណសមធម៌ ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ គណៈកម្មាធិការផ្សេងៗ ដែលនៅយ៉ាងជិតស្និតជាមួយប្រជាពលរដ្ឋ ដើម្បីផ្តល់សេវា និងតែងតែគិតគូពីបញ្ហាប្រឈមដែលប្រជាពលរដ្ឋកំពុងជួបប្រទះ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

អំណាចគ្រប់គ្រងរដ្ឋបាលឃុំ បានពីការបោះឆ្នោតជាសាកល ដោយសេរី ត្រឹមត្រូវ សម្ងាត់ យុត្តិធម៌ និងតម្លាភាព។ ការគ្រប់គ្រងឃុំ គឺជាការបម្រើប្រយោជន៍ទូទៅ និងប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងឃុំ។ ក្នុងន័យនេះ ឃុំ គឺជាអាណាព្យាបាលរបស់ប្រជាពលរដ្ឋ ដែលស្ថិតក្រោមដែនសមត្ថកិច្ចនៃការគ្រប់គ្រងរបស់ខ្លួន ដើម្បីធានាដល់ការលូតលាស់ក្លាយជាធនធាន និងជាសសរទ្រូងរបស់ប្រទេសជាតិ ស្របជាមួយការលើកស្ទួយលើគ្រប់វិស័យ ជាពិសេស វិស័យអប់រំ សុខាភិបាល សន្តិសុខនិងសេដ្ឋកិច្ច ដែលជាការការពារ និងការគាំពារលើគ្រប់ប្រជាពលរដ្ឋ។

ជាក់ស្តែងឃុំតានៃជានីតិបុគ្គលសាធារណៈដ៏សំខាន់ដែលមានតួនាទីបម្រើការងារនៅក្នុងមូលដ្ឋាន និងបម្រើផលប្រយោជន៍ទូទៅរបស់ឃុំ និងប្រជាពលរដ្ឋ។ រដ្ឋបាលឃុំតានៃ ត្រូវបានដឹកនាំនិងគ្រប់គ្រងការងារ រដ្ឋបាលដោយក្រុមប្រឹក្សាចំនួន ៥រូប ដែរមាន១ រូបជាប្រធានក្រុមព្រឹក្សា ៤រូប ទៀតជាសមាជិកក្រុមប្រឹក្សាក្នុងអាណត្តិទី៥ ។

តាមរយៈការចុះទៅយកព័ត៌មានផ្ទាល់នៅឃុំតានៃនាងខ្ញុំបានសង្កេតឃើញថា ប្រជាពលរដ្ឋនៅក្នុងឃុំនេះពិតជាមានសេដ្ឋកិច្ចកាន់តែប្រសើរឡើងពីមួយអាណត្តិទៅមួយអាណត្តិ មានផ្លូវល្អៗសម្រាប់ប្រើប្រាស់ មានសិទ្ធស្មើរគ្នាក្នុងការទទួលសេវា និងបំពេញការងារផ្សេងៗ ធនធានមនុស្សកាន់តែល្អប្រសើរ ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់នាយករដ្ឋមន្ត្រី សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ឃុំបានបំពេញការងាររបស់ខ្លួនយ៉ាងល្អប្រសើរ ដើម្បីបំពេញនូវតម្រូវការជូនប្រជាពលរដ្ឋរបស់ខ្លួននៅក្នុងមូលដ្ឋាន ដោយមានការអភិវឌ្ឍទៅលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន សេវាសាធារណៈ និងសន្តិសុខសណ្តាប់ធ្លាប់ជាដើម។ សឹងតែគ្រប់ទីកន្លែងត្រូវបានអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស និងមានការដោះស្រាយបញ្ហានានាដែរបានកើតមានឡើង នៅក្នុងមូលដ្ឋានរបស់ខ្លួន។

និយាយជារួមមកការគ្រប់គ្រងរដ្ឋបាលឃុំតានៃ គឺពិតជាទទួលបានសមិទ្ធិផលល្អ ដោយឃុំបានបម្រើ និងការពារប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងបានអនុវត្តតាមគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព ដែលធានាបាននូវលក្ខណៈ៧យ៉ាងគឺ **ទី១៖** ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាពនិងទទួលបានជំនឿទុកចិត្ត។ **ទី២៖** គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។**ទី៣៖** មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។**ទី៤៖** គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។ **ទី៥** ៖ ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។ **ទី៦៖** មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។ **ទី៧៖** ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព និងអនុវត្តការងាររបស់ខ្លួនជាប្រចាំ រួមជាមួយការងារផ្តល់សេវារដ្ឋបាលផ្សេងៗរបស់ឃុំជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំតានៃ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវអំពី «**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំតានៃ**» ដោយបានការចុះទៅដល់ឃុំផ្ទាល់រួចមកនាងខ្ញុំទាំងពីរនាក់យល់ឃើញថា ឃុំតានៃមានការអភិវឌ្ឍគួរឲ្យគត់សម្គាល់។ ប៉ុន្តែទោះជាយ៉ាងនេះក្តីយើងខ្ញុំយល់ថានៅមានផ្នែកមួយចំនួនដូចជា ផ្នែកសុខាភិបាល និងការអប់រំ ពុំសូវមានការអភិវឌ្ឍ និងរីកចម្រើនគួឲគត់សម្គាល់នៅឡើយ។

តួយ៉ាងដូចជាការយកចិត្តទុកដាក់លើបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋ មិនទាន់បានពេញលេញនៅឡើយ ដោយហេតុថានៅក្នុងឃុំពុំទាន់មានពេទ្យបង្អែកឡើយ ដែលធ្វើឲ្យប្រជាពលរដ្ឋត្រូវចំណាយ ពេលវេលាច្រើនព្រមទាំងថ្លៃធ្វើដំណើរផងដែរ ដើម្បីទៅព្យាបាលជំងឺនៅក្រៅឃុំដែលខ្លួនរស់នៅ នោះនាំឲ្យពលរដ្ឋដែលមានជីវភាពមិនសូវធូរជារគ្មានលទ្ធភាពទៅព្យាបាល។

ចំពោះការអប់រំក៏ដូចគ្នាដែរ យើងឃើញថានៅក្នុងឃុំក៏ពុំទាន់មានវិទ្យាល័យនៅឡើយ គឺមានត្រឹមកម្រិតអនុវិទ្យាល័យ។ ដូច្នេះបើសិនចង់បន្តការសិក្សានៅថ្នាក់វិទ្យាល័យ សិស្សានុសិស្ស ត្រូវធ្វើដំណើរទៅមករាល់ថ្ងៃពីឃុំតានៃទៅវាលវិញ (វិទ្យាល័យ ហ៊ុនសែនវាវិញ) ឬមួយក៏ត្រូវជួលកន្លែងស្នាក់នៅទីនោះតែម្តង។ ចំណុចនេះហើយ ទើបធ្វើឲសិស្សដែលមានជីវភាពក្រីក្រមួយចំនួន បោះបង់ការសិក្សានៅឯថ្នាក់វិទ្យាល័យ ព្រោះការចំណាយថវិការច្រើន ត្រូវធ្វើដំណើរឆ្ងាយ និងអាចមានហានិភ័យគ្រោះថ្នាក់នៅពេលកំពុងធ្វើដំណើរទៀតផង។

ម្យ៉ាងទៀត តាមការចុះទៅផ្ទាល់របស់នាងខ្ញុំទាំងពីរ ក៏បានមើលឃើញថា ការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើសេវាសង្គម ប័ណ្ណសមធម៌ ប័ណ្ណក្រីក្រ នៅមានកម្រិតទាបគួរឲ្យកត់សម្គាល់។ សព្វថ្ងៃនេះប្រជាពលរដ្ឋនៅតែមានសម្រាលនៅតាមលំនៅដ្ឋាន មិនហ៊ានទៅតាមដានសុខភាពតាមកាត់ណាត់របស់គ្រូពេទ្យ ពួកគាត់យល់ថាប័ណ្ណសមធម៌ ប័ណ្ណក្រីក្រ ពុំមានប្រសិទ្ធភាពក្នុងការប្រើប្រាស់។

មួយវិញទៀត បរិស្ថានអនាម័យ ក៏ជាបញ្ហាចម្បងដែលត្រូវគិតគូផងដែរ អនាម័យតាមដងផ្លូវ ការចោលសម្រាមពាសវាលពាសកាលនៅតែមាន ដោយពុំមានការរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវ នៅឡើយទេ។

ដោយឡែកសំណង់អណាធិបតេយ្យ និងបញ្ហាសណ្តាប់ធ្នាប់នៅតែមានវត្តមាននៅឡើយ សំណង់អាគារមួយចំនួនត្រូវបានបោះបង់ចោល សត្វពាហនៈដើរពាសវាលពាសកាល ជាពិសេសតាមផ្លូវជាតិ ផ្លូវបេតុងដែលជាហេតុនាំឲ្យបាត់បង់សោភណ្ឌភាពភូមិឃុំ និងបង្ករគ្រោះថ្នាក់ដោយយថាហេតុទៀតផង។

បញ្ហាគ្រោះថ្នាក់ចរាចរណ៍ នៅតែបន្តមានជារៀងរាល់ថ្ងៃនៅក្នុងឃុំតានៃ នេះបញ្ជាក់ឲ្យឃើញថា ការយល់ដឹងរបស់ប្រជាជន ចំពោះការគោរពច្បាប់បចរាចរណ៍នៅមានកម្រិតនៅឡើយ ពួកគាត់បើកបរក្នុងល្បឿនលឿន មិនបានពាក់មួក ឬខ្សែក្រវ៉ាត់ ពុំសូវយល់ច្បាស់ពីច្បាប់ចរាចរណ៍។

ដោយយោងតាមការយល់ឃើញខាងលើ នាងខ្ញុំទាំងពីរសង្ឃឹមថានៅថ្ងៃខាងមុខឃុំតានៃនឹងកាន់តែរីកចម្រើនវិវត្តន៍ទៅមុខ ដោយមានការបង្កើតនូវ មន្ទីរពេទ្យបង្អែក និងវិទ្យាល័យនៅក្នុងឃុំតានៃផ្ទាល់ ដែលជាផ្នែកដ៏សំខាន់ដែលជួយបង្កើតនិងពង្រឹងធនធានមនុស្សរបស់ឃុំផ្ទាល់ និងផ្សព្វផ្សាយកាត់តែទូលាយអំពីសេវាសង្គម ការថែទាំសុខភាព អនាម័យ ការទុកដាក់កាកសំណល់តាមប្រភេទ ការគោរពច្បាប់ចរាចរណ៍ឲ្យបានខ្ជាប់ខ្ជួនជាងនេះ។

# ឯកសារយោង

# ឯកសារយោង

## បទដ្ឋានគតិយុត្ត

- ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់
- អនុក្រឹត្យលេខ១៦៤អនក្រ/បកចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ស្តីពីការបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- អនុក្រឹត្យលេខ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រង់ហិរញ្ញវត្ថុឃុំ សង្កាត់
- អនុក្រឹត្យស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤
- ប្រកាសលេខ ១៣២៩ ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់ក្រសួងមហាផ្ទៃស្តីពី តួនាទី ភារកិច្ចនិង សិទ្ធរបស់ស្មៀនឃុំ សង្កាត់
- ប្រកាសលេខ៣៦៦៩ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាសភាព សមាជិកក្រុមប្រឹក្សា មេឃុំ ជំទប់ទី១ ជំទប់ទី២ នៃឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- សេចក្តីណែនាំបច្ចេកទេស ស្តីពី ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ឆ្នាំ២០១៧

## សៀវភៅ

- សៀវភៅ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០២២
- សៀវភៅស្តីពីការ «គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ តាមបែបវិមជ្ឈការ»ខែកក្កដា ឆ្នាំ២០១៧ ដោយក្រសួងមហាផ្ទៃ
- សៀវភៅទិន្នន័យទូទៅរបស់ឃុំតានៃ
- សៀវភៅពត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ចឃុំតានៃ
- សៀវភៅ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២
- សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ឃុំតានៃ(២០២៣-២០២៧)
- របាយការស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំ
- បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៣របស់ឃុំតានៃ
- តារាងចំណូល ចំណាយរបស់រដ្ឋបាលឃុំតានៃ
- តារាងមូលនិធិឃុំតានៃ

- ចង្កូវិស័យរបស់ឃុំតានៃ
- តារាងក្របខណ្ឌអភិវឌ្ឍន៍ ឃុំតានៃ
- របាយការណ៍ហិរញ្ញវត្ថុឃុំ

**ប្រព័ន្ធបណ្តាញសង្គម**

- ប្រព័ន្ធបណ្តាញសង្គម រដ្ឋបាលឃុំតានៃ

  https://www.facebook.com/profile.php?id=100066500694308
- ប្រព័ន្ធបណ្តាញសង្គម អ៊ុក សារឿនមេឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

  https://www.facebook.com/Taney99/
- ប្រព័ន្ធបណ្តាញសង្គម សេកសុភា នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំតានៃស្រុលព្រៃនប់ខេត្តព្រះសីហនុ

  https://www.facebook.com/seksophe?mibextid=LQQJ4d
- គង់ សន្ដាន ស្មៀនឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

  https://www.facebook.com/profile.php?id=100076173215175&mibextid=LQQJ4d

# ឧបសម្ព័ន្ធរូបភាព







រូបភាពទី០១៖ រូបភាពនាងខ្ញុំទាំងពីរចុះស្រាវជ្រាវឯកសារ
នៅឃុំតាន៉ៃ

រូបភាពទី០២៖ រូបភាពអនុស្សាវរីយ៍ ជាមួយអ៊ុំ ពូ មីង ដែលជា ក្រុមប្រឹក្សាឃុំ
ប៉ុស្តិ៍នគរបាល មេភូមិ អនុ.ភូមិ សាមាជិកភូមិ និងនាយកសាលា






រូបភាពទី០៣និងរូបភាពទី០៤៖ សម្មភាពនាងខ្ញុំទាំងពីរចូលរួមប្រជុំ គណៈកម្មធិការ គ.ក.ន.ក និងប្រជុំ
សាមញ្ញលើកទី២១របស់ឃុំតាន៉ៃ





រូបភាពទីរូបភាពទី០៥៖ព្រែកក្នុងឃុំតានៃ

រូបភាពទីរូបភាពទី០៦៖ ការប្រមូលផលដូងប្រេងក្នុងឃុំតានៃ






រូបភាពទីរូបភាពទី០៧៖ទឹកធ្លាក់ធម្មជាតិនៅក្នុងឃុំតានៃ

រូបភាពទីរូបភាពទី០៨៖ ទិន្នផលផ្លែឈើរបស់ប្រជាជននៅក្នុងឃុំតានៃ





រូបភាពទីរូបភាពទី០៩៖ ចម្ការស្វាយចន្ទីរបស់ប្រជាជននៅក្នុងឃុំតានៃ

រូបភាពទីរូបភាពទី១០៖ ចម្ការកៅស៊ូរបស់ប្រជាជននៅក្នុងឃុំតានៃ



រូបភាពទីរូបភាពទី១១៖ សម្មភាពចុះផ្តល់អត្រានុកូលដ្ឋានជូនប្រជាជន




រូបភាពទីរូបភាពទី១២៖ សម្មភាពចុះល្បាតរបស់កម្លាំងប៉ុស្តិ៍ និងកម្លាំងប្រជាការពារតាមតំបន់ស្មុគស្មាញនិងងាយគ្រោះថ្នាក់



រូបភាពទីរូបភាពទី១៣៖ ផ្លូវបេតុងក្នុងភូមិ



រូបភាពទីរូបភាពទី១៤៖ សម្មភាពចុះសម្អាតបរិស្ថាន



រូបភាពទីរូបភាពទី១៥៖ សម្មភាពជុសជុលស្ពានឡើងវិញ



រូបភាពទីរូបភាពទី១៦៖ ដំណាំស្រូវរបស់ប្រជាជន



រូបភាពទីរូបភាពទី១៧៖ ផែនទីរដ្ឋបាលឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ




រូបភាពទីរូបភាពទី១៧៖ រចនាសម្ព័ន្ធរដ្ឋបាលឃុំតានៃ



# តារាងតម្លៃសេវារដ្ឋបាល ឃុំតានៃ

យោងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសក្រសួងលេខ ១៤៣៤២ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦
ស្តីពីការផ្តល់សេវារដ្ឋបាល របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **ក/ ការងារអត្រានុកូលដ្ឋាន** | | | | | |
| ១ | សំបុត្រកំណើត | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ២ | សំបុត្របញ្ជាក់កំណើត(បិតតែមប្រ៍លើពាក្យស្នើសុំ) | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត ឬ បញ្ជាក់កំណើត | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៤ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍(បិតតែមប្រ៍លើពាក្យស្នើសុំ) | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ) | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេស ជាមួយពលរដ្ឋខ្មែរ) | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៧ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៨ | សំបុត្រមរណភាព(ក្នុងរយៈពេល១៥ថ្ងៃ) | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៩ | សំបុត្រមរណភាព(ហួសរយៈពេល១៥ថ្ងៃក្នុង១ឆ្នាំ) | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | 0 | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| **ខ/ ការចេញលិខិតអនុញ្ញាត** | | | | | |
| ១ | លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ | 0 | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |
| ២ | លិខិតបញ្ជាក់ទីលំនៅ | 0 | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |
| ៣ | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | ៤.០០០ | ៣ថ្ងៃ | ចប់កិច្ចសន្យា | ១សន្លឹក |
| ៤ | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | ១០.០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៥ | លិខិតបញ្ជាក់ទាយាទ | ៥.០០០ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៦ | លិខិតបញ្ជាក់កិរិយាមាយាទ | ៥.០០០ | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |
| ៧ | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | 0 | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |
| ៨ | លិខិតបញ្ជាក់ ទិញ លក់សត្វពាហនៈ(គិតក្នុង១ក្បាល) | ៣.០០០ | ៣ថ្ងៃ | ១លើក | ១សន្លឹក |
| ៩ | លិខិតបញ្ជាក់តបណ្តាញអគ្គិសនី | ៥.០០០ | ៧ថ្ងៃ | ១លើក | ១សន្លឹក |
| ១០ | លិខិតបញ្ជាក់តបណ្តាញទឹកស្អាត | ៥.០០០ | ៧ថ្ងៃ | ១លើក | ១សន្លឹក |
| ១១ | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | ១០.០០០ | ៣ថ្ងៃ | ចប់កិច្ចសន្យា | ១សន្លឹក |
| ១២ | លិខិតផ្ទះជួល បន្ទប់ស្នាក់នៅ | ៥.០០០ | ៧ថ្ងៃ | ១ឆ្នាំ | ១ច្បាប់ |
| ១៣ | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត(ដែលមិនមែនជាសម្ពក៏ច្ចរបស់ស្ថាប័នណាមួយ) | ៥.០០០ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |

រូបភាពទីរូបភាពទី១៨៖ តារាងតម្លៃសេវារដ្ឋបាលឃុំតានៃ

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖** ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

**ឧបសម្ព័ន្ធទី២ ៖** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់

**ឧបសម្ព័ន្ធទី៣ ៖** អនុក្រឹត្យលេខ១៦៤អនក្រ/បកចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ស្តីពីការបង្កើតឃុំតានៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ

**ឧបសម្ព័ន្ធទី៤ ៖** អនុក្រឹត្យស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤

**ឧបសម្ព័ន្ធទី៥ ៖** អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ

# ឧបសម្ព័ន្ធទី១៖

នស / រកម / ០៣០១ / ០៥

**ព្រះរាជក្រម**

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ ពិសាមួយនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសជាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ : ។ល។

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# ឃុំ សង្កាត់

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំការអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។



**មាត្រា ៤៣.-**

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ។ល។

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។ ៚



**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៚

# ឧបសម្ព័ន្ធទី២

ព្រះរាជក្រម

នស/រកម/១២១៥/ ០១៥

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៥៨/០០៦/ ២០១៥ កបធ.ច ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖



# ច្បាប់
## ស្តីពី
# ការបោះឆ្នោតជ្រើសរើស
# ក្រុមប្រឹក្សាឃុំ សង្កាត់



## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កា ត់ ។

ច្បាប់នេះត្រូវអនុវត្តចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣.–**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំ ម្តង ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៤ (ប្រាំបួន) ខែ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ។

**មាត្រា ៤.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**មាត្រា ៥.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល ៖

–បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ

–មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តែមួយប៉ុណ្ណោះ ។



**មាត្រា ៦.–**

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗដូចបានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិច ០៩ (ប្រាំបួន) ខែ មុនថ្ងៃបោះឆ្នោត ។

## ជំពូកទី ២
## ការគ្រប់គ្រងការបោះឆ្នោត
## ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៧ .–**

ការចាត់ចែង រៀបចំ និងគ្រប់គ្រងបញ្ជីបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៨.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាច មុខងារ និងភារកិច្ចដូចខាងក្រោម ៖

–រៀបចំ និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត

–ពិនិត្យរៀបចំបញ្ជីបោះឆ្នោតជារៀងរាល់ឆ្នាំ

–ការពារសុវត្ថិភាព និងរក្សាបញ្ជីបោះឆ្នោត

–សម្រេចលើការចុះបញ្ជីបេក្ខជន

–ពិនិត្យតាមដានយុទ្ធនាការឃោសនាបោះឆ្នោត

–គ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត

–គ្រប់គ្រងនីតិវិធីរាប់សន្លឹកឆ្នោត និងចាត់ចែងការរាប់សន្លឹកឆ្នោត

–ប្រកាសលទ្ធផលនៃការបោះឆ្នោត

–ការពារសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោត និងការពារសុវត្ថិភាពសម្ភារ ឧបករណ៍ គ្រឿងសង្ហារិម សម្រាប់ដំណើរការបោះឆ្នោតទាំងមូល

# ឧបសម្ព័ន្ធទី៣៖



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ៖ ១៦៤ អនក្រ.បក

**អនុក្រឹត្យ**
**ស្ដីពី**
**ការបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០៥ នៃឃុំជើងគោ គឺភូមិតាពៅ ភូមិតានៃ ភូមិមនោរម្យ ភូមិស្វាយ និងភូមិអន្លង់ក្រពើ។

**មាត្រា ២.-**

ឃុំតានៃ មានភូមិចំនួន០៥ គឺភូមិតាពៅ ភូមិតានៃ ភូមិមនោរម្យ ភូមិស្វាយ និងភូមិអន្លង់ក្រពើ។

ព្រំប្រទល់រដ្ឋបាលនៃឃុំតានៃ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

ទីតាំងសាលាឃុំតានៃ ស្ថិតនៅក្នុងភូមិតានៃ។





**មាត្រា ៤.-**

ការបង្កើតឃុំតានៃ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នា អាណត្តិទី៤ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាឃុំជើងគោ ត្រូវបន្តគ្រប់គ្រងភូមិចំនួន០៥ គឺភូមិតាពៅ ភូមិតានៃ ភូមិមនោរម្យ ភូមិស្វាយ និងភូមិអន្លង់ក្រពើ រហូតដល់មានក្រុមប្រឹក្សាឃុំតានៃមកជំនួស។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំតានៃ ត្រូវអនុលោមទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាខេត្តព្រះសីហនុ គណៈអភិបាលខេត្តព្រះសីហនុ ក្រុមប្រឹក្សាស្រុកព្រៃនប់ គណៈអភិបាលស្រុកព្រៃនប់ ក្រុមប្រឹក្សាឃុំជើងគោ និងក្រុមប្រឹក្សាឃុំតានៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤១ អនក្រ.បក

**អនុក្រឹត្យ**
**ស្ដីពី**
**ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់



-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
-បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
-បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបំបែកសង្កាត់ចោមចៅ នៃខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបំបែកសង្កាត់ស្ទឹងមានជ័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបំបែកសង្កាត់បឹងទំពន់ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបំបែកសង្កាត់កាកាប នៃខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបំបែកសង្កាត់ទួលសង្កែ នៃខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៤៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើតសង្កាត់អូរបែកក្អម នៃខណ្ឌសែនសុខ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៥០ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើតសង្កាត់គោកឃ្លាង នៃខណ្ឌសែនសុខ រាជធានីភ្នំពេញ
-បានឃើញអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើតឃុំក្ដុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង
-បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើតឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ
-បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ



| | | |
|---|---|---|
| ១៣០១.សង្កាត់ ទឹកវិល | - ដ - | ៧ នាក់ |
| ១៣០២.សង្កាត់ ក្របីរៀល | - ដ - | ៧ នាក់ |

**១៨-ខេត្តព្រះសីហនុ**

**ស្រុកព្រៃនប់**

| | | |
|---|---|---|
| ១៣០៣.ឃុំ អណ្ដូងថ្ម | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៣០៤.ឃុំ បឹងតាព្រហ្ម | - ដ - | ៧ នាក់ |
| ១៣០៥.ឃុំ បិតត្រាំង | - ដ - | ៥ នាក់ |
| ១៣០៦.ឃុំ ជើងគោ | - ដ - | ៥ នាក់ |
| ១៣០៧.ឃុំ អូរជ្រៅ | - ដ - | ៥ នាក់ |
| ១៣០៨.ឃុំ អូរឧកញ៉ាហេង | - ដ - | ៧ នាក់ |
| ១៣០៩.ឃុំ ព្រៃនប់ | - ដ - | ៥ នាក់ |
| ១៣១០.ឃុំ រាម | - ដ - | ៧ នាក់ |
| ១៣១១.ឃុំ សាមគ្គី | - ដ - | ៥ នាក់ |
| ១៣១២.ឃុំ សំរុង | - ដ - | ៥ នាក់ |
| ១៣១៣.ឃុំ ទឹកល្អក់ | - ដ - | ៥ នាក់ |
| ១៣១៤.ឃុំ ទឹកថ្លា | - ដ - | ៥ នាក់ |
| ១៣១៥.ឃុំ ទួលទទឹង | - ដ - | ៥ នាក់ |
| ១៣១៦.ឃុំ វាលរេញ | - ដ - | ៧ នាក់ |
| ១៣១៧.ឃុំ តានៃ | - ដ - | ៥ នាក់ |

**ស្រុកស្ទឹងហាវ**

| | | |
|---|---|---|
| ១៣១៨.ឃុំ កំពេញ | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៣១៩.ឃុំ អូរត្រេះ | - ដ - | ៥ នាក់ |
| ១៣២០.ឃុំ ទំនប់រលក | - ដ - | ៧ នាក់ |
| ១៣២១.ឃុំ កែវផុស | - ដ - | ៥ នាក់ |

**ស្រុកកំពង់សិលា**

| | | |
|---|---|---|
| ១៣២២.ឃុំ ចំការហ្លួង | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៣២៣.ឃុំ កំពង់សិលា | - ដ - | ៥ នាក់ |

## ១.១. ស្ថានភាពព័ត៌មានទូទៅរបស់ឃុំ

### ១.១.១. ស្ថានភាពភូមិសាស្ត្រ

ឃុំតានៃ មានទីតាំងនៅតាមបណ្តោយ ផ្លូវជាតិលេខ៤ពីព្រះសីហនុទៅភ្នំពេញឃុំមានទីតាំងនៅប៉ែកខាងត្បូងនៃសាលាស្រុកមានចំងាយប្រមាណ ១៦ គ.ម ពីទីរួមស្រុក ។

ឃុំ មានព្រំប្រទល់៖

- ខាងជើងទល់និង ឃុំស្ទឹងឆាយ និងឃុំចំការហ្លួងស្រុកកំពង់សិលា
- ខាងកើត ទល់ភ្នំបូកគោខេត្តកំពត
- ខាងត្បូងទល់នឹងឃុំសាមគ្គី និងជើងគោ
- ខាងលិចទល់ ឃុំកែវផុស ស្រុកស្ទឹងហាវ

លក្ខណៈភូមិសាស្ត្ររបស់ឃុំជាតំបន់ភ្នំស្ថិតនៅជាប់ជើងភ្នំបូកគោ មានផ្ទៃដី សរុបៈ១៧.៣២៣,៦៧ ហ.ត ចែកចេញជា ៖ ផ្ទៃដីលំនៅដ្ឋានចំនួនៈ២៥៤,៥ហ.ត ផ្ទៃដីកសិកម្មៈ១៦.៩៨៨ហ.ត(ក្នុងនោះផ្ទៃដីអាចធ្វើស្រែវស្សាបានចំនួនៈ២៦១,៨០ហ.ត ផ្ទៃដីដំណាំរយៈពេលវែងខ្លីចំ នួនៈ១៦៧២៦,២០ហ.ត )នឹងផ្ទៃដី ផ្សេងៗ(ដីព្រៃនិងបឹង)ចំនួនៈ៨១,១៧ហ.ត។មានប្រជាពលរដ្ឋរស់នៅចំនួន១.២៣៣គ្រួសារ មានមនុស្សសរុប៦.០៥៥នាក់ ក្នុងនោះស្ត្រី២.៧៤៨នាក់ ស្ត្រីជាមេគ្រួសារមានៈ ១០,៧០% ទំហំគ្រួសារមធ្យមមានៈ ៤,៩នាក់/គ្រួសារ ដង់ស៊ីតេប្រជាជនមានចំនួនៈ៣៤,៩៥នាក់/គ.ម២ ដែនដីរដ្ឋបាលឃុំមានភូមិចំនួន៥ចំណុះ (ភូមិតាពៅ តានៃ អមនោរម្យ១ ស្វាយ និងភូមិអន្លង់ក្រពើ ) ។

### ១.១.២. សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

តារាងសង្ខេបទិន្នន័យចម្បងរបស់ឃុំ

| ល.រ | បរិយាយ | ឆ្នាំ២០២២ |
|---|---|---|
| ១ | ផ្ទៃដីឃុំ សង្កាត់ (គ.ម២ ) | ១៧៣,២៣៦៧ |
| ២ | ចំនួនភូមិ | ៥ |
| ៣ | ចំនួនគ្រួសារ | ១.២៣៣ |
| ៤ | ចំនួនប្រជាជនសរុប | ៦.០៥៥ |
| ៥ | ចំនួនស្រី | ២.៧៤៨ |
| ៦ | ចំនួនប្រុស | ៣.៣០៧ |
| ៧ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | ១៤,៤ |
| ៨ | % មេគ្រួសារជាស្ត្រី | ១០,៧០ |
| ៩ | ទំហំគ្រួសារជាមធ្យម( នាក់/គ្រួសារ ) | ៤,៩ |
| ១០ | ដង់ស៊ីតេប្រជាជននាក់/គ.ម២ | ៣៤,៩៥ |
| ១១ | % អ្នកមានអាយុពី០-១៧ឆ្នាំ | ៣៧,២០ |
| ១២ | % អ្នកមានអាយុពី១៨-៦០ឆ្នាំ | ៥៦,៥០ |
| ១៣ | % អ្នកមានអាយុពី៦១ឆ្នាំឡើង | ៦,៣០ |
| ១៤ | អត្រាភាពក្រីក្រ (%) | ៣,១៥ |
| ១៥ | % អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | ២៦,២០ |
| ១៦ | % អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | ០ |
| ១៧ | % អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | ៧៣,៧០ |

| ល.រ | បរិយាយ | ឆ្នាំ២០២២ |
|---|---|---|
| ១៨ | % មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | ៥,៣០ |
| ១៩ | % មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | ១,៩០ |
| ២០ | % ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | ៩៣,៣០ |
| | អប់រំ | |
| ២១ | % កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | ៤៦,៧០ |
| ២២ | % កុមារអាយុ៦ឆ្នាំបានចូលរៀន | ៨៩,៨០ |
| ២៣ | % កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | ៧៨,៣០ |
| ២៤ | % កុមារអាយុ១២-១៤ឆ្នាំនៅរៀន | ៧៩,៦០ |
| ២៥ | % អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | ១០០ |
| ២៦ | % អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | ៩៩ |
| | សុខាភិបាល | |
| ២៧ | ចំនួនមណ្ឌលសុខភាព | ០ |
| ២៨ | % ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | ១០០ |
| ២៩ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល(០-១ខែ) ក្នុង១ពាន់កំណើត | ២១,៧ |
| ៣០ | អត្រាស្លាប់របស់កុមារក្រោយពេលកើត(០-១ខែ)ក្នុង១ពាន់កំណើត | ០ |
| ៣១ | % កុមារអាយុពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ១០០ |
| ៣២ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | ១១ |
| | ភាពងាយរងគ្រោះ | |
| ៣៣ | ចំនួនជនពិការ | ៥០ |
| ៣៤ | % ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | ៣៩ |
| ៣៥ | ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | ០ |
| ៣៦ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | ៥ |
| | ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ | |
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/កន្ត្រាក់ | ០ |
| ៣៨ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | ០ |
| ៣៩ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | ០ |
| ៤០ | % គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | ០ |
| ៤១ | % គ្រួសារមានទឹកស្អាតប្រើប្រាស់ | ៨៥,២០ |
| ក្នុងនោះ: | % គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | ៣,៣១ |
| | % គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ | ១៨,៧២ |
| | % គ្រួសារប្រើទឹកអណ្តូងជីកមានការការពារ | ៦៣,១៧ |
| | % គ្រួសារប្រើទឹកភ្លៀងមានការការពារ | ០ |
| ៤២ | % គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ៧៤,៦០ |
| | រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | |
| ៤៣ | % កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | ១០០ |
| ៤៤ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | ៣ |
| ៤៥ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | ១ |
| ៤៦ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | ០ |
| ៤៧ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | ៥ |

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

### ១.២.១. ស្ថានភាពសេដ្ឋកិច្ច

ការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច សង្គមបានផ្អែកទៅលើប្រភពសក្តានុពល ជាច្រើនដែលមានស្រាប់និងកំពុងធ្វើការអភិវឌ្ឍបំពេញតាមភាពរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ចនិងតម្រូវការក្នុងសហគមន៍រួមមាន ៖វិស័យកសិកម្ម ( ផ្ទៃដីស្រែ ចំការដំណាំកសិ-ឧស្សាហកម្ម(ចំការដូងប្រេង កៅស៊ូ) និងដំណាំរយៈពេលខ្លី តំបន់អភិវឌ្ឍឧស្សាហកម្ម (រោងចក្រ សហគ្រាស កសិដ្ឋានចំការដូងប្រេង ចិញ្ចឹមសត្វ ) ទេសចរណ៍ (រមណីយដ្ឋានតាមព្រៃក ស្ទឹងក្នុងតំបន់ភ្នំ) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រភពសក្តានុពលទាំងនេះជាមូលដ្ឋានគ្រឹះសំខាន់ៗសម្រាប់បំរើដល់ការអភិវឌ្ឍនៅ មូលដ្ឋាននិងបានលើកស្ទួយនូវជីវភាពប្រពលរដ្ឋ ក្នុងគោលដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតាមសហគមន៍។

មនុស្សអាយុ១៨-៦០ឆ្នាំឡើងមានមុខរបរចម្បងសរុបមានអត្រា៨៩,៨៥% ( ប្រុសមានអត្រា៩១,៣០% ស្រីមានអត្រា៨៨,៤០% )បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថរយចុះ:២,១៥ %។

**ភាពក្រីក្រ**

ភាពក្រីក្រស្ថិតនៅក្នុងកម្រិតអត្រាក្រោម៣,១៥%នៅដើមឆ្នាំ២០២២ បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ:៦,៣១%(ប្រភពទិន្នន័យCDBដើមឆ្នាំ២០២២)។ ដោយឡែកការជួបនូវវិបត្តិសកលនៃជំងឺឆ្លងកូវីដ-១៩ឆ្នាំ២០២០-២០២១ ការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ១៩ ប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺឆ្លងកូវីដ-១៩និងគ្រួសារងាយរងហានិភ័យមានចំនួន:១៣១ គ្រួសារស្មើនិងអត្រា១០,៦២% នៃចំនួនគ្រួសារសរុបក្នុងឃុំ ។

ការប្រឈមចំពោះមុខ ទិន្នផលផលិតផលកសិកម្មទទួលបានតិចតួចនិងមានតម្លៃទាប (ទិន្នផលស្រូវទាប តម្លៃស្រូវទាប ការចិញ្ចឹមសត្វក៏ថយចុះ តម្លៃសត្វនៅទីផ្សារមានតម្លៃទាប )ការប្រមូលផល ការលក់ដូរកសិផល ត្រូវទទួលរងផលប៉ះពាល់ជាយថាហេតុជាច្រើនដែលបន្សល់ទុកក្នុងបរិបទវិបត្តិជំងឺឆ្លងសកលកូវីដ-១៩ ប្រជាពលរដ្ឋមិនអាចរកចំណូលបានដោយការប្រកបរបរអាជីវកម្មនិងសេវាកម្មនានា មិនទាន់មានភាពប្រក្រតី និង ភាពអសកម្មក្នុងការងារនៅតាមរោងចក្រ សហគ្រាស បណ្តាលឱ្យអត្រាភាពក្រីក្រក្នុងឃុំមានកើនឡើងនៅក្នុងឆ្នាំ២០២២ ។

**អត្រាភាពក្រីក្រតាមបណ្តាឆ្នាំ**( CDBដើមឆ្នាំ២០២២ )




### ១.២.១.១ កសិកម្ម

បានជំរុញការធ្វើពិពិធកម្មកសិកម្ម និងបរិយាប័ន្ន ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលចំពោះការដាំដំណាំគ្រប់ប្រភេទដូចជា:បង្កើនកិច្ចសហការផ្តល់សេវាបច្ចេកទេសដំណាំឈើហូបផ្លែ ដំណាំកសិ-ឧស្សាហកម្ម ដំណាំស្រូវវស្សា ការជួយអន្តរាគមន៍ដល់ដំណាំកសិកម្មសំដៅបង្កើនទិន្នផល ការធ្វើបន្សាំដំណាំទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម និងការសហការជំរុញផលិតកម្មសត្វ និងសុខភាព សត្វ។

មនុស្សអាយុ១៨ឆ្នាំឡើងប្រកបរបរកសិកម្មជាចម្បងមានអត្រា២៦,២០% ក្នុងនោះស្ត្រីមាន ១១,៩០% នៃចំនួនមនុស្សប្រកបរបរកសិកម្ម (មនុស្សប្រកបរបរកសិកម្មជាចម្បងថយចុះក្នុងកម្រិត អត្រា ៣,៤០%បើធៀបទៅនឹងដើមឆ្នាំ២០១៨)ក្នុងនោះប្រជាជន៤,១០% មានមុខរបរធ្វើស្រែជាចម្បងនៃគ្រួសារប្រកបរបរកសិកម្មជាចម្បងសរុបបើធៀបទៅនឹងដើមឆ្នាំ២០១៨ មានអត្រាថយចុះប្រមាណ៥,៥០%។ (ប្រភពទិន្នន័យCDBដើមឆ្នាំ២០២២)។

ការងារបង្កបង្កើនផលស្រូវវស្សាអនុវត្តបានលើផ្ទៃដី១០០% នៃផ្ទៃដីដែលអាចធ្វើស្រែបាន ទិន្នផលមធ្យម១,៥តោន/ហ.ត(បើធៀបទៅនឹងដើមឆ្នាំ២០១៨មានការកើនឡើងប្រមាណ០,២ត\ហ.ត) បរិមាណផលស្រូវប្រចាំឆ្នាំនេះប្រជាពលរដ្ឋទទួលបានចំនួនប្រមាណ៦៣,៥គ.ក្រ សម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ ២០២២។

ពលរដ្ឋប្រកបរបរដាំដំណាំឈើហូបផ្លែ ដំណាំរួមផ្សំនិងបន្លែជាចម្បងមានអត្រា១២,៧០%បើធៀបនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើងប្រមាណ២,៧០% និងក្រុមហ៊ុនក្នុងស្រុកវិនិយោគដំណាំដូងប្រេងចំនួន១៤.៦៦៧ ហ.តចំការកៅស៊ូ៣.០០០ ហ.តនិងពលរដ្ឋប្រកបរបរដាំ ដំណាំឈើហូបផ្លែមានប្រមាណ ១៧១ហ.ត បើធៀបនឹងដើមឆ្នាំ២០១៨មានអត្រាដំណាំឈើហូបផ្លែកើនឡើងប្រមាណ ២៤ហ.ត។

ប្រជាជនមានរបរចិញ្ចឹមសត្វជាចម្បងមានអត្រា៦,១០%បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ០,៥០% ។(ប្រភពទិន្នន័យ CDB ដើមឆ្នាំ២០២២)

ផ្អែកតាមសក្តានុពល និងសមិទ្ធផលក្នុងការអនុវត្តជាក់ស្តែងកន្លងមក ឃុំបាននិងកំពុងជួបប្រទះបញ្ហាប្រឈមគួរឲ្យកត់សម្គាល់ដូចជា៖ ទិន្នផលបរិមាណផលនិងគុណភាពស្រូវនៅមានកម្រិតមិនទាន់ឆ្លើយតបទៅនឹងតម្រូវការស្បៀង និងទីផ្សារ បណ្តាលមកពីមិនមានប្រព័ន្ធធារាសាស្ត្រការពារសម្រាប់ស្រោចស្រព និងរំដោះទឹកពេលជំនន់ទឹកភ្លៀង ខ្វះបច្ចេកទេសដាំដុះ ការប្រើប្រាស់ពូជពុំសុទ្ធល្អ និងសត្វល្អិតបំផ្លាញ។

ការប្រកបរបរកសិកម្មតាមបែបប្រពលវប្បកម្ម និងការដាំដុះបង្កើនរដូវ ការកែលម្អដីធ្លី ការប្រើប្រាស់ពូជ ជីមិនទាន់សមស្របតាមក្សេត្របរិស្ថាន ការអនុវត្តន៍បច្ចេកទេសដាំដុះថ្មី ការ ការបណ្តុះបណ្តាលបច្ចេកទេសជំនាញដើម្បីកែប្រែទម្លាប់ដាំដុះរបស់កសិករ និងខ្វះការថែរក្សាដំណាំគ្រប់ប្រភេទ ក្នុងអំឡុងបិទខ្ទប់ ។ ទន្ទឹមនោះដំណាំរួមផ្សំបន្លែបង្ការ ដំណាំឧស្សាហកម្ម ផ្សេងៗទៀត និងការចិញ្ចឹមសត្វក៏នៅមានកម្រិតទាបទាំងបរិមាណ និងគុណភាព មិនអាចបំពេញបានតាមតម្រូវការទីផ្សារដោយមូលហេតុចម្បងដូចជា៖ កសិករខ្វះទុន ព័ត៌មានទីផ្សារ ។ ការប្រែប្រួលអាកាសធាតុបណ្តាលឲ្យកើតមានគ្រោះមហន្តរាយធម្មជាតិខុសប្រក្រតីដូចជា៖( ជំនន់ទឹកភ្លៀង) កំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច កំណើនប្រជាជនបានស្រូបយកផ្ទៃដីកសិកម្មជារៀងរាល់ឆ្នាំ ដោយសារការអភិវឌ្ឍលិវិស័យសំណង់លំនៅឋាន អាគារផ្ទះល្វែង និងហេដ្ឋារចនាស

ម្ព័ន្ធផ្សេងៗ និងកម្លាំងពលកម្មលើវិស័យកសិកម្មបានថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយប្រជាពលរដ្ឋផ្លាស់ប្តូរមុខរបរ និងស្ថិតក្នុងស្ថានភាពនៃការរស់នៅក្នុងបរិបទជំងឺឆ្លងសកលកូវីដ-១៩រយៈពេលពីរឆ្នាំ២០២០-២០២១ វិស័យកសិកម្មទទួលរងផលប៉ះពាល់ជាខ្លាំង ដោយសារការបិទខ្ទប់ចលនាប្រជាជនបានធ្វើឱ្យការប្រមូលផលក្នុងវិស័យកសិកម្មមានការថយចុះ។ ចំណែកធនធានជលផលកំពុងមានបញ្ហា ការនេសាទហួសកំរិត និងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ការបំពុលបរិស្ថានក្នុងទឹកនិងខ្វះបច្ចេកទេស និងទុនចិញ្ចឹមត្រី ។

**១.២.១.២ អាជីវកម្ម សេវាកម្ម**

ផ្នែកអាជីវកម្មត្រូវបាន ចិត្តទុកដាក់ទៅលើការគ្រប់គ្រង ធ្វើការកែលម្អទីផ្សារនិងតំបន់ទីតាំងផលិតកម្មអាជីវកម្ម សេវាកម្ម ដើម្បីឱ្យការធ្វើអាជីវកម្មប្រកបដោយស្មើភាពនិងការធ្វើចរាចរទំនិញគ្រប់ប្រភេទប្រកបដោយសុវត្ថិភាព និងបានបើកទូលាយក្នុងការផ្តល់លទ្ធភាពប្រកបរបរសេវាកម្មនានា សម្រាប់ការផ្គត់ផ្គង់ជីវភាពពលរដ្ឋ បង្កើនកិច្ចសហការជាមួយស្ថាប័នជំនាញនិងវិស័យឯកជនផ្តល់សេវាបច្ចេកទេសជំនាញវិជ្ជាជីវៈនិងសហការជំរុញការផ្តល់ប្រាក់កម្ចីរបស់ពីមីក្រូហិរញ្ញវត្ថុសម្រាប់បង្កើតមុខរបរ ។

ពលរដ្ឋអាយុ១៨ឡើងមានមុខរបរចំបងក្រៅពីវិស័យកសិកម្ម(ផលិតកម្មសេវាកម្ម) មានអត្រា ៧៣,៧០%ក្នុងនោះស្ត្រីមានអត្រា៣២,១០%បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើង៣,៣០%។

បច្ចុប្បន្នឃុំមានទីផ្សារមួយកន្លែង មានទីតាំសិប្បកម្ម និងសេវាកម្មចំនួន១៤៧កន្លែង (មានម៉ាស៊ីនកិនស្រូវខ្នាតតូច សេវាកម្មលក់ដូរចំណីអាហារ ជួសជុលម៉ូតូជួសជុលគ្រឿងយន្តនិង ជួសជុលគ្រឿងអេឡិចត្រូនិក)និងសេវាកម្មទេសចរណ៍ ។

ពលរដ្ឋក្នុងវ័យ១៧-២៥ឆ្នាំភាគច្រើនជាកម្មករ កម្មការិនីនៅតាមបណ្តារោងចក្រ សហគ្រាស ហើយចេញទៅបំរើការងារនោះនៅតាមបណ្តារោងចក្រសហគ្រាសដែលមានទីតាំងនៅតាមបណ្តាឃុំទូទាំងស្រុក។

ពលរដ្ឋភាគច្រើនមិនមានមុខរបរផ្នែកផលិតកម្មដោយខ្វះជំនាញវិជ្ជាជីវៈ និងប្រភពទុនសម្រាប់បង្កើតមុខរបរ ។

**១.២.១.៣ .ការងារទេសចរណ៍**

វិស័យទេសចរណ៍ រដ្ឋបាលឃុំ បាននិងកំពុងសហការជាសហគមន៍មូលដ្ឋានធ្វើការកែលម្អរមណីយដ្ឋានដែលមានស្រាប់ឱ្យក្លាយទៅតំបន់រមណីយដ្ឋានប្រណិត និងការអភិវឌ្ឍសេវាកម្មនានាដែលបម្រើដល់ភ្ញៀវទេសចរណ៍ដូចជាៈ រមណីយដ្ឋានធម្មជាតិ នៅភូមិអន្លង់ក្រពើ និងភូមិស្វាយ ។ ទន្ទឹមនេះមានសេវាកម្មទេសចរណ៍ដូចជា ផ្ទះសំណាក់ចំនួន០១ផ្ទះសំណាក់ ភោជនីដ្ឋានចំនួន០១កន្លែង អាហារដ្ឋានចំនួន២៩កន្លែង អាជីវកម្មខ្នាតតូច(លក់បាយ គុយទាវ)និងសេវាកម្មខ្នាតតូច(កាត់សក់ ម៉ាស្សារ)មានចំនួន៥កន្លែង។

សក្តានុពលទេសចរណ៍ធម្មជាតិដែលអាចធ្វើការអភិវឌ្ឍជារមណីយដ្ឋាន មិនទាន់មានលទ្ធភាពស្តានិងអភិវឌ្ឍ(រមណីយដ្ឋានធម្មជាតិ)ការកែច្នៃផលិតផលអនុវស្សាវរីយ៍សម្រាប់ភ្ញៀវទេសចរណ៍ ។ព្រមជាមួយនេះតំបន់ខ្លះកំពុងរងការខូចខាតពុំអាចមានលទ្ធភាពស្តារឡើងវិញបានឡើយនិងពលរដ្ឋភាគច្រើនមិនមានជំនាញវិជ្ជាជីវៈលើការងារទេសចរណ៍ ។

**១.២.១.៤ គមនាគមន៍**

ស្ថានភាពប្រព័ន្ធគមនាគមន៍ បានផ្តល់ភាពងាយស្រួលដល់ការអភិវឌ្ឍគ្រប់ផ្នែក ឃុំមានប្រព័ន្ធដឹកជញ្ជូនផ្លូវគោក ដោយមានផ្លូវតភ្ជាប់ទៅកំពង់ផែកែវផុស(ស្រុកស្ទឹងហាវ) និងផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៤ ទៅក្នុងមូលដ្ឋានភូមិ ក្រុមប្រឹក្សាធ្វើការស្តារនិងជួសជុលឡើងតាមរយៈការប្រើប្រាស់មូលនិធិឃុំនិងមានការជួយគាំទ្រពីសាលាខេត្ត មន្ទីរអភិវឌ្ឍន៍ជនបទ សាលាស្រុក និងសប្បុរសជន រួមមាន៖ ផ្លូវក្រាលក្រួសក្រហម ផ្លូវក្រាលបេតុងបានប្រវែង.....................ម៉ែត្រ ប្រព័ន្ធផ្លូវទាំងអស់ជាប្រភពសក្តានុពលសំខាន់ បានផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារ គឺការធ្វើចរាចរនូវកសិផល និងផលិតផលគ្រប់ប្រភេទទៅទីផ្សារ និងការផ្សាភ្ជាប់ទំនាក់ទំនងទៅបណ្តាក្រុង ស្រុក និងខេត្តផ្សេងៗ។ ក្នុងមូលដ្ឋានឃុំមានរថយន្ត ធុនតូចនិងធំសម្រាប់ដឹកទំនិញចំនួន១៩គ្រឿង និងអ្នកដំណើរ(ទេសចរណ៍)មានចំនួន១០គ្រឿង។ ទន្ទឹមនឹងភាពរីកចម្រើនផ្នែកសក្តានុពលដឹកជញ្ជូន ឃុំក៏ជួបប្រទះនូវបញ្ហាសំខាន់ៗដូចជា៖ ប្រព័ន្ធផ្លូវមួយចំនួនត្រូវរងការខូចខាតនិងមួយចំនួនទៀតមានសភាពចាស់ទ្រុឌទ្រោម ត្រូវទឹកហូរកាត់ខូច ដោយគ្មាន ប្រព័ន្ធលូរំដោះទឹក និងមិនមានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើការស្តារ ថែទាំនិងជួសជុលឡើងវិញ ដែលអាចបំពេញតាមតម្រូវការរបស់មូលដ្ឋាន ។

### ១.២.១.៥ ការវិនិយោគ

ស្ថានភាពនៃការវិនិយោគរបស់អ្នកវិនិយោគិនក្នុងស្រុកបាន និងកំពុងផ្តោតលើវិស័យមួយចំនួនត្រូវបានក្រុមហ៊ុនវិនិយោគដំណាំដំណាំកសិ-ឧស្សាហកម្ម(ដូងប្រេង និងកៅស៊ូ)មានកសិដ្ឋានចំការកៅស៊ូ ចិញ្ចឹមសត្វ រោងចក្រ សហគ្រាស បានផ្តល់លទ្ធភាពដល់ប្រជាជនក្នុងឃុំចូលរួមបម្រើការងារប្រមាណ២.៤៤៧នាក់ ក្នុងនោះស្រីមានចំនួន១.០៨៧នាក់បើធៀបទៅនឹងដើមឆ្នាំ២០១៨កើនឡើងចំនួន៥៥៩នាក់។

ការជួបប្រទះពលរដ្ឋមិនមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញតាមតម្រូវការទីផ្សារពលកម្ម ក្នុងបរិបទវិបត្តិជំងឺឆ្លងសកលកូវីដ-១៩ ពលរដ្ឋភាគច្រើនទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយភាពអសកម្មផលិតកម្មគ្រប់វិស័យ ។

### ១.២.១.៦.ការប្រើប្រាស់ថាមពលអគ្គិសនី

ការប្រើប្រាស់ថាមពលអគ្គិសនី បានសហការជំរុញការផ្តល់សេវាផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ប្រជាពលរដ្ឋប្រើប្រាស់ឱ្យបានគ្រប់ខ្នងផ្ទះ និងគ្រប់តាមតម្រូវការក្នុងមូលដ្ឋានតាមប្រភពទិន្នន័យមូលដ្ឋានភូមិឃុំដើមឆ្នាំ២០២២បានបង្ហាញនៅក្នុងឃុំចំនួនផ្ទះដែលមានថាមពលអគ្គិសនីប្រើប្រាស់ចំនួន១,១០៤ផ្ទះស្មើនឹងអត្រា៖៩៣,៣០%នៃចំនួនផ្ទះសរុបទូទាំងឃុំបើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើង២,២០%។

ការប្រឈមដែលកើតមាន ការរៀបចំខ្សែបណ្តាញចូលតាមផ្ទះក្នុងភូមិនៅមានភាពមិនទាន់សមស្របតាមលក្ខណៈបច្ចេកទេសនៅឡើយ។

**ភាគរយផ្ទះមានបណ្តាញអគ្គិសនីប្រើប្រាស់**( CDBដើមឆ្នាំ២០២២ )




ភាគរយផ្ទះមានបណ្តាញអគ្គិសនីប្រើប្រាស់តាមភូមិ ឆ្នាំ២០២២(ប្រភពទិន្នន័យCDBដើមឆ្នាំ២០២២)




### ១.២.២. ស្ថានភាពសង្គមកិច្ច

#### ១.២.២.១ អប់រំ

វិស័យអប់រំបានទទួល នូវការគាំទ្រពីរាជរដ្ឋាភិបាល ពីមន្ទីរអប់រំ និងបានធ្វើការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធអប់រំ ចាប់ពីថ្នាក់មត្តេយ្យរហូតដល់សាលាអនុវិទ្យាល័យ ធ្វើឲ្យវិស័យអប់រំមានលទ្ធភាពផ្តល់ការអប់រំកម្រិតមូលដ្ឋានដល់កុមារស្ថិតក្នុងវ័យសិក្សាទាំងអស់ ជាពិសេសកុមារដែលជាកូនមកពីគ្រួសារក្រីក្រទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងមានលទ្ធភាពបញ្ចប់ការសិក្សាអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

បច្ចុប្បន្នឃុំមានសាលាមត្តេយ្យរដ្ឋចំនួន៥ថ្នាក់និងមត្តេយ្យសហគមន៍ចំនួន១ថ្នាក់(សរុប៦ថ្នាក់) បើធៀបទៅនឹងដើមឆ្នាំ២០១៨ថ្នាក់មត្តេយ្យទាំងមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍មានចំនួន៧ថ្នាក់ថយចុះចំនួន០១ថ្នាក់ ។ កុមារក្រុមអាយុ ៣-៥ ឆ្នាំ បានចូលរៀន មានអត្រាប្រមាណៈ៤១,៧០%បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ២៣,៩០ % ។

សាលាបឋមសិក្សាមានចំនួន៦សាលា ថ្នាក់ចំនួន ៣៦ ថ្នាក់បើធៀបទៅនឹងដើមឆ្នាំ២០១៨មានចំនួន៦សាលានិងចំនួនថ្នាក់៣៦ថ្នាក់ ។កុមារក្រុមអាយុពី៦-១១ឆ្នាំ កំពុងរៀននៅសាលាបឋមសិក្សាមានអត្រា៧៨,៣០ % បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ១០,៦០%។

សាលាអនុវិទ្យាល័យមានចំនួន១សាលា៥បន្ទប់មានថ្នាក់ចំនួន៣ថ្នាក់បើធៀបទៅនឹងដើមឆ្នាំ២០១៨មានចំនួន១សាលាមាន៥បន្ទប់ និងចំនួន៣ថ្នាក់។ កុមារអាយុ ១២-១៤ឆ្នាំ កំពុងនៅរៀនមានអត្រា៧៩,៦០% បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ៤,៨០%។

កុមារក្រុមអាយុ១៥-១៧ឆ្នាំកំពុងរៀននៅវិទ្យាល័យមានអត្រា៣១,១១% បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះប្រមាណ ៦,៨៣% ។

ការផ្តល់សេវាអប់រំតាមមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប នៅពុំទាន់មានភាពល្អប្រសើរនៅឡើយ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធអប់រំមានស្ទើតែគ្រប់គ្រាន់ក៏ដោយ តែនៅមិនទាន់មានថ្នាក់មត្តេយ្យគ្រប់គ្រាន់ទៅតាមតម្រូវការនិងកំណើនរបស់កុមារក្នុងមូលដ្ឋាននៅឡើយ។ ពិសេសនៅតាមតំបន់ប្រជាពលរដ្ឋរស់នៅមានចំនួនគ្រួសារតិច ដែលជាទីតាំងរស់នៅឆ្ងាយពីសាលារៀន ។ ចំណែកកុមារក្រុមអាយុ ១៥-១៧ឆ្នាំរៀននៅសាលា វិទ្យាល័យក៏មានកម្រិតទាប ដោយកុមារក្រុមអាយុទាំងនេះបានចេញទៅប្រកបរបររកប្រាក់ចំណូលសម្រាប់គ្រួសារ។បច្ចុប្បន្នចលនានៃការបង្រៀន និងការរៀនរបស់គ្រូ និងសិស្ស ការចូលរៀននៅតាមគ្រឹះស្ថានសិក្សា នៅតែមានការប្រុងប្រយ័ត្នខ្ពស់ដោយបានពង្រឹងការអនុវត្តរបៀបរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទជំងឺកូវីដ-១៩ និងគោរពនូវសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលពីវិធានការការពារទប់ស្កាត់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩(ពិសេស៣កុំ៣ការពារ)និងវិធានការនានារបស់ក្រសួងសុខាភិបាល។

### ១.២.២.២ សុខាភិបាល

សុខភាពប្រជាពលរដ្ឋទទួលបាននូវការផ្តល់សេវាថែទាំព្យាបាលបានទាន់ពេលវេលា និងបានល្អប្រសើរ ការផ្គត់ផ្គង់និងការផ្តល់សេវាថែទាំព្យាបាលសាធារណៈ ដូចជា៖ការជួយគាំពារ និងការថែរក្សាការពារសុខភាព ផ្តល់នូវអាហារូបត្ថម្ភ និងការចាក់វ៉ាក់សាំងការពារដល់ស្ត្រី-កុមារការផ្សព្វផ្សាយបង្កើនការយល់ដឹងពីការការពារថែទាំសុខភាពអនាម័យ និងការអនុវត្តតាមណែនាំរបស់ក្រសួងសុខាភិបាល ពង្រឹងវិធានការទប់ស្កាត់ជម្ងឺឆ្លង(ពិសេសជំងឺកូវីដ-១៩)និង ការអប់រំបង្កើនការយល់ដឹងពីដល់យុវវ័យពីសុខភាពបន្តពូជ តាមរយៈមណ្ឌលសុខភាពស្ថិតនៅក្នុងឃុំជើងគោនិងការបង្កើតបណ្តាញភ្នាក់ងារសុខភាពភូមិ ។

ស្ថិតនៅក្នុងបរិបទកូវីដ-១៩ រយៈពេលពីរឆ្នាំកន្លងមកកិច្ចការផ្តល់សេវាសុខភាពសាធាណៈ ដើម្បីការពារសុខភាពប្រជាជនជាការងារចម្បងរបស់វិស័យសុខាភិបាល។ ឆ្នាំ២០២០-២០២១ ជាឆ្នាំដែលសកម្មភាពវិស័យសុខាភិបាលមានភាពមមាញឹកប្រយុទ្ធប្រឆាំងនិងជំងឺឆ្លងសកល ក្នុងន័យការពារសុខភាពអនាម័យជូនប្រជាជនក៏ដូចជាសង្គមទាំងមូល ។ រដ្ឋបាលឃុំ បានសហការជាមួយមន្ទីរសុខាភិបាលអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ទីរ អង្គភាព បានពង្រឹងការអនុវត្តនូវគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ៣ការពារ និង៣កុំ និងវិធានរបស់ក្រសួងសុខាភិបាល ដែលជាយន្តការសម្រាប់ជួយគ្រប់គ្រង និង ការពារនិងការអនុវត្តប្រយុទ្ធប្រឆាំងការពារចំពោះជំងឺឆ្លងកាចសាហាវនៅក្នុងសហគមន៍ ។ ព្រមជាមួយការចុះអប់រំដល់សហគមន៍ស្តីពីការថែរក្សាអនាម័យ សុខភាព ប្រើប្រាស់កម្លាំងចល័តក្នុងសហគមន៍ជួយផ្សព្វផ្សាយ អប់រំការពារនិងមានវិធានការជួយទប់ស្កាត់នៅតំបន់បិទខ្ទប់ ជំរុញឱយមានការទទួលយកព័ត៌មានបន្ទាន់ ការជំរុញការចាក់វ៉ាក់សាំងការពារ និងការផ្សព្វផ្សាយនូវ យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគម្លងប្រក្រតីភាពថ្មីក្នុងបរិបទជំងឺកូវីដ-១៩។

**ឃុំមានសេវាសុខភាព៖**

- ឱសថស្ថាននិងឱសថស្ថានរងមានចំនួន០២កន្លែង

ស្ថានភាពក្នុងឆ្នាំ២០២១ កន្លងមកវិស័យសាសនាត្រូវបានទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺឆ្លងសកលកូវីដ-១៩ ដោយសារការបិទខ្ទប់ចលនាប្រជាជន ក៏ដូចជាសាសនិក ដែលត្រូវចូលរួមគោរពតាមប្រពៃណីរបស់ខ្លួន។

**១.២.២.៥ អន្តោប្រវេសន៍ និងការផ្លាស់លំនៅ**

ពលរដ្ឋធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្នុងប្រទេសមានអត្រា:៥,៣០% នៃចំនួនមនុស្សធ្វើចំណាកស្រុកក្នុងប្រទេសបើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ១,២០% និងធ្វើចំណាកស្រុកទៅក្រៅប្រទេសមានអត្រា:១,៩០ % នៃចំនួនមនុស្សធ្វើចំណាកស្រុកក្រៅប្រទេសបើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាថយចុះ០,៥០% ។

បច្ចុប្បន្នប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរទីលំនៅមករស់នៅក្នុងឃុំ ភាគច្រើនប្រកបរបរសេវាកម្ម និងកសិកម្ម ការស្នាក់នៅទៅបំពេញការងារនៅតាមបណ្តារោងចក្រ សហគ្រាស កសិដ្ឋានចំការដូង ដែលមាននៅក្នុងឃុំនិងឃុំជាប់ព្រំប្រទល់នឹងរដ្ឋបាលឃុំ ចំណែកពលរដ្ឋក្នុងឃុំមួយចំនួនបានផ្លាស់ទីលំនៅស្វែងរកការងារធ្វើ។

បញ្ហាប្រឈម ពលរដ្ឋចំណាកស្រុកភាគច្រើនមកតាំងទីលំនៅខុសច្បាប់ នៅតាមតំបន់ការពារនិងអភិរក្ស តំបន់ផ្ទៃដីបំរុងទុក ។ ក្នុងបរិបទជំងឺឆ្លងសកលកូវី-១៩ ការធ្វើចំណាកស្រុកប្រជាជនមករស់នៅក្នុងឃុំមានការថយចុះ ដោយសារការបិទខ្ទប់ ហាមឃាត់ការប្រកបរបរអាជីវកម្ម សេវាកម្មនានា និងនៅតាមបណ្តារោងចក្រ សហគ្រាស និងកសិដ្ឋានមួយចំនួនបានផ្អាកសកម្មភាពផលិត។

**១.២.៣.ស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

**១.២.៣.១ ការប្រើប្រាស់ដីធ្លី**

បច្ចុប្បន្នដែនដីរដ្ឋបាល បានប្រើប្រាស់ដីតាមស្ថានភាពនៃការរស់នៅរបស់ប្រជាជន និងតាមការកំណត់របស់រាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ដែលបានកំណត់ក្នុងភូមិសាស្ត្ររបស់ឃុំ គឺមានដីសម្រាប់តំបន់លំនៅស្ថាន ផ្ទៃដីអភិរក្សតំបន់ឧទ្យានជាតិបូកគោ និងផ្ទៃដីគម្របព្រៃឈើ ។

លំនៅស្ថានបច្ចុប្បន្នភាគច្រើនរីកដុះដាលតាមបណ្តោយផ្លូវសំខាន់ និងមួយចំនួនទៀតបានមកតាំងលំនៅលើដីសាធារណៈ តាមដីចំណីផ្លូវ លើផ្ទៃដីកសិកម្ម ផ្ទៃដីគម្របព្រៃឈើ និងព្រៃលិចទឹកតាមតំបន់ការពារនិងអភិរក្សតាម ព្រែកមអ៊ីរ និងឧទ្យានជាតិរាម ។

ប្រជាពលរដ្ឋប្រមា១៣៨គ្រួសារមានប័ណ្ណកម្មសិទ្ធិដីធ្លី ផលធៀបគ្រួសារមានប័ណ្ណកម្មសិទ្ធដីធ្លីក្នុង១០០០គ្រួសារមា៨៣៤គ្រួសារដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី បើធៀបទៅនឹងដើមឆ្នាំ២០១៨គ្រួសារមានប័ណ្ណកម្មសិទ្ធិដីធ្លីថយចុះចំនួន៤២គ្រួសារ ។ ទន្ទឹមនោះភាពអនាធិបតេយ្យ ការទន្ទ្រាញដីព្រៃយកធ្វើជាកម្មសិទ្ធិនៅតែជាបញ្ហាប្រឈមរបស់រដ្ឋបាលឃុំ ដោយប្រជាពលរដ្ឋខ្វះការយល់ដឹងពីច្បាប់ និងការរំលោភបំពានចំពោះច្បាប់។

**១.២.៣.២ធនធានធម្មជាតិ ៖**

បច្ចុប្បន្នការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពពិតជាមានការចាំបាច់ណាស់ សម្រាប់សុខុមាលភាពប្រជាជន ធនធានធម្មជាតិនៅមូលដ្ឋានសម្បូរនូវប្រព័ន្ធជីវៈចម្រុះ តំបន់ការពារធនធានធម្មជាតិ

តំបន់ការពារជាប់ជើងភ្នំបូកគោ និងតំបន់ការពារព្រៃ ការពារព្រៃបំរុងទុកជាប់ជើងភ្នំ តំបន់ទាំងនោះបានធ្វើនិងកំណត់អត្តសញ្ញាណកម្មក្បាលដី បោះបង្គោលព្រំដី ព្រមទាំងបានធ្វើការ ផ្សព្វផ្សាយបានយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងមានក្រុមការពារបរិស្ថានថែរក្សាជាប្រចាំ ប៉ុន្តែតែសកម្មភាពអនាធិបតេយ្យនៅតែមានការចូលទន្ទ្រានកាន់កាប់ និងបំផ្លិចបំផ្លាញផ្ទៃដីតំបន់អភិរក្សនិង តំបន់ការពារព្រៃឈើបំរុងទុក និងការប្រើប្រាស់ព្រៃឈើហួសកម្រិត ។

**១.២.៣.៣បរិស្ថាន ៖**

បច្ចុប្បន្ន ការថែរក្សាអនាម័យបរិស្ថានមានភាពល្អប្រសើរ បង្កើតបាននូវបរិយាកាសល្អ និងធានាបាននូវកិច្ច គាំពារបរិស្ថាន ការអភិរក្ស ជីវចម្រុះ និសម្រាប់ការរស់នៅរបស់ពលរដ្ឋប្រកបដោយចីរភាព។ ទន្ទឹមនឹងនោះមន្ទីរជំនាញបានធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីច្បាប់ គោលការណ៍ និងវិធានការនានាស្តីពីការថែរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រ នៃការរក្សាសុខភាព អនាម័យ សុវត្ថិភាពចំណីអាហារ និងការសម្អាតអនាម័យបរិស្ថាននៅតាមផ្ទះសម្បែង ភូមិឃុំរបស់ខ្លួន ផ្តល់ចំណេះដឹងពីការវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងការចូលរួមអនុវត្តវិធានការ ៣ កុំ ៣ ការពារដើម្បីភូមិដ្ឋានរបស់យើងមានអនាម័យ បរិស្ថានល្អមានផាសុកភាពសម្រាប់ការរស់នៅ សុខុមាលភាពពលរដ្ឋល្អ ជៀសផុតពីការឆ្លងជំងឺទាំងឡាយ។

ក្រុមប្រឹក្សាក៏ដូចរដ្ឋបាលឃុំបានសហការជាមួយមន្ទីរ អង្គភាពជំនាញ បង្កើនយល់ដឹងការគ្រប់គ្រង និងពង្រឹងវិធានការទប់ស្កាត់ការបំពុលបរិស្ថាន ដោយការបង្ហូរសំណល់រាវចូលក្នុង ប្រឡាយ អូរ និងតាមតំបន់ទីប្រជុំជន។

កំណើននៃការអភិវឌ្ឍគ្រប់វិស័យ នៅក្នុងមូលដ្ឋាន បាននិងកំពុងធ្វើឱ្យស្ថានភាពបរិស្ថានធម្មជាតិ និងបរិស្ថានអនាម័យ ប្រឈមនឹងការគំរាមកំហែងជាច្រើនដូចជាកំណើនប្រជាជន ការអភិវឌ្ឍដំណាំ កសិ-ឧស្សាហកម្ម និងកំណើនឧស្សាហកម្ម ត្រូវបានប្រើប្រាស់ផ្ទៃដីព្រៃច្រើនហួសប្រមាណ និងការប្រើប្រាស់ជកហូតធនធានធម្មជាតិហួសហេតុពេកស្ថានភាពបរិស្ថាន កំពុងតែប្រឈមនឹងការគំរាមកំហែងជាច្រើនដូចជា: ការបាត់បង់បរិស្ថានធម្មជាតិ និងបរិស្ថាន អនាម័យ ។

ការគ្រប់គ្រងសំណល់រឹង សំណល់រាវ មិនទាន់បានល្អ បង្កភាពក្រខ្វក់ដល់បរិស្ថានរស់នៅរបស់ប្រជាជន ប្រជាជនខ្វះការយល់ដឹងពីការគ្រប់គ្រងកាកសំណល់ ការចោលកាកសំណល់រឹងនៅតាមទីប្រជុំជន ការចោលកាកសំណល់រឹងនិងការបង្ហូរសំណល់រាវចូលក្នុងទឹក បរិស្ថាន អនាម័យ និងការគ្រប់គ្រងសំណល់រឹង សំណល់រាវ មិនទាន់បានល្អ បង្កភាពក្រខ្វក់ដល់បរិស្ថានរស់នៅរបស់ប្រជាជន ។ ប្រជាជនខ្វះការយល់ដឹងពីការគ្រប់គ្រងកាកសំណល់ ការចោលកាកសំណល់រឹងនៅតាមទីប្រជុំជន ការចោលកាកសំណល់រឹងនិងការបង្ហូរសំណល់រាវចូលក្នុងទឹកព្រែក ស្ទឹង ប្រឡាយ អូរ និងតំបន់អាជីវកម្មទេសចរណ៍ ទឹកភ្លៀងជន់លិចនៅទីប្រជុំជនគ្មានប្រព័ន្ធបង្ហូររំដោះទឹកភ្លៀងចេញពីភូមិ។

**ការប្រើប្រាស់បង្គន់អនាម័យ**

គ្រួសារមានបង្គន់អនាម័យប្រើប្រាស់មានចំនួន៖៩២០គ្រួសារស្មើនិងអត្រា៧៤,៦០%បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើង១៥,៩០% (គ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេសមានចំនួន៧៣១គ្រួសារស្មើនិងអត្រា៥៩,៣០%បើធៀទៅនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើង១៧%) ។

បញ្ហាប្រឈមប្រជាពលរដ្ឋនៅពុំទាន់មានការយល់ដឹង ពីបញ្ហាសុខភាព និងអនាម័យ បរិស្ថានរស់នៅស្អាត ខ្វះការយល់ដឹងពីសារៈប្រយោជន៍នៃការប្រើប្រាស់បង្គន់អនាម័យ និងខ្វះការជួយឧបត្ថម្ភគាំទ្រ ដូចជាការផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ និងថវិកាសម្រាប់ការសាងសង់បង្គន់អនាម័យតាមគ្រួសារ។

**ភាគរយគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស**(CDBដើមឆ្នាំ២០២២)




**ភាគរយគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេសតាមភូមិដើមឆ្នាំ២០២២**




### ការប្រើប្រាស់ទឹកស្អាត

ការថែទាំសុខភាពអនាម័យដល់គ្រួសារទូទៅក្នុងឃុំអាចរស់នៅប្រកបដោយសុខដុមរមនា ជាប្រក្រតីតាមរយៈការផ្សព្វផ្សាយបង្កើនការយល់ដឹងស្តីពីការធ្វើអនាម័យតាមសហគមន៍ និងការផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ ដោយបានការគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទ និងបណ្តាអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់អណ្តូងស្នប់ អណ្តូងលូមានគម្របការពារ ក្រុមហ៊ុនទឹកស្អាតបានរៀបចំបណ្តាញទឹកស្អាតជូនប្រពលរដ្ឋក្នុងសហគមន៍ ។

បច្ចុប្បន្នពលរដ្ឋក្នុងសង្កាត់មានទឹកស្អាតប្រើប្រាស់ចំនួន១.០៥១គ្រួសារស្មើនិង ៨៥,២០% បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើង៥,៩០%។

នៅគ្រប់ភូមិទាំងអស់ការផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់មិនទាន់គ្រប់គ្រាន់ដូចជាៈប្រព័ន្ធទឹកស្អាតមិនទាន់មានបណ្តាញគ្រប់គ្រាន់ និងមួយចំណែកទៀតអណ្តូងស្នប់ខូចមិនមានជួសជុលឡើងវិញ។

**ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់**(CDBដើមឆ្នាំ២០២២




**ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់តាមភូមិដើមឆ្នាំ២០២២**




### ១.២.៤ ស្ថានភាពរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ១.២.៤.១អភិបាលកិច្ច ៖

ក្រោយការបោះឆ្នោតជាសកលនិងក្រោយប្រកាសសុពលភាពក្រុមប្រឹក្សាឃុំបានពង្រឹងតួនាទី ភារកិច្ចខ្លួន ដោយបាននិងកំពុងអនុវត្តឱ្យសម្រេចបានតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងការអនុវត្តនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ។

រចនាសម្ព័ន្ធរដ្ឋបាលឃុំបានរៀបចំស្របតាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងបានពង្រឹងអភិបាលកិច្ច បង្កើនសមត្ថភាពក្រុមប្រឹក្សា ពង្រឹងការអនុវត្តតួនាទីភារកិច្ចស្មៀន បានបង្វិតសេវាសាធាណៈឱ្យជិតប្រជាពលរដ្ឋ ជំរុញការលើកស្ទួយកិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើកស្ទួយសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រើប្រាស់ថវិកា ប្រកបដោយសុចរិតភាព តម្លាភាព គណនេយ្យភាព និងបានធ្វើឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការទទួលយកសេវាសាធារណៈ។

### ១.២.៤.២គ្រប់គ្រងដែនដី ៖

ឃុំជាតំបន់ភ្នំស្ថិតនៅជាប់ជើងភ្នំបូកគោមានផ្ទៃដី សរុបៈ១៧.៣២៣,៦៧ហ.ត ចែកចេញជា ៖ ផ្ទៃដីលំនៅដ្ឋានចំនួនៈ២៥៤,៥ហ.ត ផ្ទៃដីកសិកម្មៈ១៦.៩៨៨ហ.ត(ក្នុងនោះផ្ទៃដីអាចធ្វើស្រែវស្សាបានចំនួនៈ២៦១,៨០ហ.ត ផ្ទៃដីដំណាំរយៈពេលវែងខ្លីចំ នួនៈ១៦៧២៦,២០ហ.ត )នឹងផ្ទៃដី ផ្សេងៗ(ដីព្រៃនិងបឹង)ចំនួនៈ៨១,១៧ហ.តនិងមានភូមិចំនួន ៥ចំណុះ(ភូមិតាពៅ តានៃ អមនោរម្យ១ ស្វាយ និងភូមិអន្លង់ក្រពើ ) ។

ទន្ទឹមនឹងនោះក្រុមប្រឹក្សា និងរដ្ឋបាលឃុំបង្កើនកិច្ចសហការជាមួយមន្ទីរ អង្គភាពជំនាញ ពង្រឹងការអនុវត្តន៍ និងផ្សព្វផ្សាយច្បាប់ និងអនុក្រឹត្យ នានាដែលពាក់ព័ន្ធនិងការគ្រប់គ្រងដីធ្លី ការកំណត់អត្តសញ្ញាណក្បាលដី និងការផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ជូនប្រជាពលរដ្ឋ។

ការអភិវឌ្ឍវិស័យ សំណង់ និងសំណង់អគារលំនៅឋានបានគ្របដណ្តប់លើផ្ទៃដីបំរុងទុក និងតំបន់ការពារអភិរក្ស នាំឱ្យផ្ទៃដីទាំងនោះត្រូវរងការបាត់បង់ជាច្រើន។ ម្យ៉ាងទៀតពលរដ្ឋរស់នៅក្នុងឃុំមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធកាន់កាប់ដីធ្លីគ្រប់គ្រួសារ ដែលនាំឱ្យមានករណីទំនាស់កើនឡើង។

### ១.២.៤.៣ ការគ្រប់គ្រងស្ថិតិៈ

ជំរុញការផ្សព្វផ្សាយយ៉ាងទូលំទូលាយជាសាធារណៈដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនការយល់ដឹងដល់ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋានសម្រាប់ពលរដ្ឋម្នាក់ៗ ដែលរស់នៅក្នុងប្រទេសជានិតិរដ្ឋ ។

បច្ចុប្បន្នកុមារបានមកចុះបញ្ជីសំបុត្រកំណើត (ក្រោយកើត៣០ថ្ងៃ)មានអត្រាប្រមាណ១០០% បើធៀបទៅនឹងដើមឆ្នាំ២០១៨មានអត្រាកើនឡើង២៤,៥០%។ ទន្ទឹមនេះក្រុមប្រឹក្សានិងរដ្ឋបាលឃុំបានសហការជាមួយមន្ទីរផែនការពង្រឹងសមត្ថភាពមន្ត្រីភូមិ/ឃុំ ដើម្បីប្រមូលព័ត៌មានទិន្នន័យភូមិ ឃុំជារៀងរាល់ឆ្នាំនិងសហការចុះអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ -១៩និងប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺឆ្លងកូវីដ-១៩ និងគ្រួសារងាយរងហានិភ័យ ។

បញ្ហាប្រឈមពលរដ្ឋមិនទាន់យល់ពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន។

### ១.២.៤.៤ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ៖

ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខដុមរមនាមានសុវត្ថិភាព និងមានសន្តិសុខសណ្តាប់ធ្នាប់ល្អដោយយើងបានអនុវត្តនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព តាមរយៈការបង្កើត នឹងពង្រឹងប្រជាការពារតាមភូមិកិច្ចសហការជាមួយបណ្តាស្ថាប័នជំនាញ និងអង្គការនានា ធ្វើការអប់រំផ្សព្វផ្សាយដល់ពលរដ្ឋបានយល់ដឹងពីច្បាប់នានាដែលពាក់ព័ន្ធដល់កិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍជាមូលដ្ឋានកាត់បន្ថយនូវភាពអស្ថិរភាពក្នុងសហគមន៍មូលដ្ឋាន និងបង្កើនការចូលរួមពីប្រជាពលរដ្ឋអនុវត្តឱ្យបានល្អប្រសើរនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ។

បច្ចុប្បន្នមានអាគាររដ្ឋបាលឃុំសម្រាប់ធ្វើការទំនាក់ទំនងបានល្អប្រសើរ អាចផ្តល់នូវការទំនាក់ទំនងនិងការផ្តល់ព័ត៌មានទៅថ្នាក់ភូមិ និងមានការិយាល័យច្រកចេញចូលតែមួយដែលមានលទ្ធភាពងាយស្រួលចំពោះផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានសហគមន៍ទូទាំងឃុំ ។

# ជំពូកទី២ :

## ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ

**២.១. ចក្ខុវិស័យអភិវឌ្ឍន៍**

**ប្រជាពលរដ្ឋមានកម្រិតជីវភាពកើនឡើង មានចំណេះដឹង មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានស្អាត មានអនាម័យ មានសន្តិសុខ សណ្តាប់ធ្នាប់ល្អ និងទទួលបានសេវាសាធារណៈប្រកបដោយសមធម៌ ។**

**២.២. គោលបំណងអភិវឌ្ឍន៍**

- ពលរដ្ឋទទួលបានប្រាក់ចំណូលខ្ពស់ពីវិស័យកសិកម្ម មានជីវភាព កាន់តែប្រសើរឡើង។
- អភិវឌ្ឍវិស័យកសិកម្មនិងផ្តល់ឱ្យពលរដ្ឋទទួលបានប្រាក់ចំណូលខ្ពស់និងបំពេញបានតាមតម្រូវការមូលដ្ឋាននិងទីផ្សារ ។
- ប្រជាពលរដ្ឋគ្រប់រូបមានសមត្ថភាពជំនាញចំណេះដឹងប្រកបរបរសេវាកម្មផលិតកម្មនិងទទួលបាននូវប្រាក់ចំណូលខ្ពស់ ការធ្វើចំណាកស្រុកត្រូវបានកាត់បន្ថយជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។
- រមណីយដ្ឋានទេសចរណ៍ធម្មជាតិ ត្រូវបានធ្វើការអភិវឌ្ឍស្របតាមតម្រូវការគោលនយោបាយរបស់រាជរដ្ឋាភិបាល និងតម្រូវការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងមូលដ្ឋាន(តំបន់ស្ទឹង តាមដងជ្រលងភ្នំ) ។
- ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់មានភាពល្អប្រសើរ ប្រកបដោយគុណភាព ការធ្វើដំណើររបស់ពលរដ្ឋមានសុវត្ថិភាព ។
- ពង្រីកថាមពលអគ្គិសនីបំពេញតាមតម្រូវមូលដ្ឋាន និងការអភិវឌ្ឍ។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅគ្រប់មូលដ្ឋានសិក្សា បង្កើនការអប់រំ កុមារបានចូលរៀនគ្រប់ៗគ្នា និងអនក្ខរភាពត្រូវបានលុបបំបាត់។
- ពលរដ្ឋមានសុខភាពមាំមួន ទទួលបាននូវសេវាសុខាភិបាលសាធារណៈគ្រប់គ្រាន់ កាត់បន្ថយការឈឺស្លាប់របស់មាតា ទារក -កុមារ កាត់បន្ថយអត្រាស្លាប់ និងឆ្លងដោយសារជំងឺអេដស៍ និងជំងឺរបេងគ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗ។
- ពលរដ្ឋមានលទ្ធភាពនិងយល់ដឹងពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទជំងឺកូវីដ-១៩។
- ក្រុមជនងាយរងគ្រោះនិងក្រុមជនរងគ្រោះទទួលបានការទ្រទ្រង់ជីវភាពពីរាជរដ្ឋាភិបាល និងសេវាថែទាំឧបត្ថម្ភគាំពារសុខភាព និងមានសុវត្ថិភាពល្អប្រសើរជនពិការ និងកុមារកំព្រាមានលទ្ធភាព និងមានសមត្ថភាព ចេញទៅប្រកបរបរតាមទីផ្សារ។
- ស្ត្រីមានសមត្ថភាពមានជំនាញវិជ្ជាជីវៈគ្រប់គ្រាន់ និងមានលទ្ធភាពចូលបំរើការងារក្នុងសង្គមប្រកបដោយសមធម៌ ។
- ពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់គ្រួសារ និងការរស់នៅក្នុងបរិស្ថានស្អាត គ្មានការបំពុលបរិស្ថាន
- ពលរដ្ឋមិនរងគ្រោះដោយសារជំនន់ទឹកភ្លៀងជន់លិច ដោយមានប្រព័ន្ធបង្ហូរនិងរំដោះទឹកចេញពីទីប្រជុំជន(ទីផ្សារ)និងភូមិ។
- ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីក្នុងដែនរដ្ឋបាលឃុំស្របទៅតាមច្បាប់កំណត់ ដោយមានកិច្ចការពារនិងថែរក្សាធនធានធម្មជាតិប្រកបដោយនិរន្តរភាព។
- ពលរដ្ឋបានយល់ពីច្បាប់ភូមិបាលនិងទទួលបានប័ណ្ណកម្មសិទ្ធដីធ្លីដោយស្របច្បាប់ ករណីទំនាស់ដីធ្លីត្រូវបានកាត់បន្ថយ ។

- ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីក្នុងដែនរដ្ឋបាលឃុំស្របទៅតាមច្បាប់កំណត់ ដោយមានកិច្ចការពារនិងថែរក្សាធនធានធម្មជាតិប្រកបដោយនិរន្តរភាព។
- ស្ត្រី-កុមាររស់នៅប្រកបដោយសុវត្ថិភាព ក្រោមកិច្ចការពារដោយច្បាប់ និងមិនមានការរងគ្រោះដោយសារអំពើជួញដូរ និងអំពើហិង្សា ។
- ពលរដ្ឋបានយល់ដឹងពីសារប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ។
- ពលរដ្ឋរស់នៅប្រកបដោយសុខដុមរមនា មានសន្តិសុខសណ្តាប់ធ្នាប់ល្អប្រសើរ រដ្ឋបាលឃុំ និង ភូមិមានទីកន្លែងល្អប្រសើរសម្រាប់ផ្តល់សេវាជូនពលរដ្ឋ។
- ពលរដ្ឋបានយល់ដឹង និងចេះគោរពច្បាប់ចរាចរណ៍។

## ២.៣. គោលដៅអភិវឌ្ឍន៍

### ២.៣.១-ផ្នែកសេដ្ឋកិច្ច

- ទិន្នផល និងផលិតផលកសិកម្មកើនឡើងប្រកបដោយគុណភាពល្អ អាចធ្វើចរាចរនៅទីផ្សារទៅតាមតម្រូវការ ។
- ពលរដ្ឋមានសមត្ថភាពជំនាញចំណេះដឹងនិងមានលទ្ធភាព ធ្វើពិពិធកម្មកសិកម្ម។
- ពលរដ្ឋមានសមត្ថភាពជំនាញចំណេះដឹង និងមានលទ្ធភាពអាចប្រកបរបរផលិតកម្ម សេវាកម្ម។
- ស្ពា និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និង កិច្ចការពារសុវត្ថិភាពការធ្វើចរាចរណ៍ ។
- ពលរដ្ឋប្រកបរបរសេវាកម្ម និងផលិតកម្មកើនឡើង ការធ្វើចំណាកស្រុកត្រូវបានកាត់បន្ថយ។
- ស្ត្រីមានចំណេះដឹងចូលរួមប្រកបរបរក្រៅពីកសិកម្ម និងមានលទ្ធភាពរកប្រាក់ចំណូលតាមទីផ្សារពលកម្មក្នុងមូលដ្ឋាន។
- ពលរដ្ឋមានលទ្ធភាព និងសមត្ថភាពអាចទទួលចំណូលពីវិស័យទេសចរណ៍ខ្ពស់និងធ្វើការកែលម្អរមណីយដ្ឋាន ពង្រីកសេវាកម្មទេសចរណ៍។
- ប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះនិងគ្រប់តម្រូវការ។

### ២.៣.២-ផ្នែកសង្គមកិច្ច

- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅគ្រប់ភូមិសិក្សា (មត្តេយ្យ បឋមសិក្សា និងអនុវិទ្យាល័យ) អប់រំឱ្យកុមារ បានចូលរៀនគ្រប់ៗគ្នា អនក្ខរភាពត្រូវបានលុបបំបាត់។
- សហការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស និងផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋអាចចេញទៅប្រកបរបរនៅតាមទីផ្សារពលកម្ម
- កាត់បន្ថយការឈឺ និងស្លាប់របស់មាតា ទារក និងកុមារ អត្រាស្លាប់ និងឆ្លងដោយសារជំងឺអេដស៍ អត្រាស្លាប់ និងឆ្លងដោយ សារជំងឺរបេងគ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗ។
- អនុវត្តយុទ្ធសាស្ត្រ និងវិធីសាស្ត្រអប់រំប្រកបដោយប្រសិទ្ធភាព គុណភាពនៅក្នុងស្ថានភាពដែលនៅតែរងផលប៉ះពាល់ពីជំងឺឆ្លងសកលកូវីដ-១៩ និងជំងឺឆ្លងនានា។

- ការអប់រំផ្សព្វផ្សាយក្នុងសហគមន៍ ឲ្យគោរពនូវសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលពីវិធានការការពារទប់ស្កាត់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩) ពិសេស៣កុំ ៣ការពារ(
- ពង្រឹងសកម្មភាពសង្គ្រោះបន្ទាន់សម្រាប់ជួយប្រជាជនក្រីក្រ ទុគ៌តជន ចាស់ជរាគ្មានទីពឹងនិងប្រជាជនរងគ្រោះដោយធម្មជាតិ ឬដោយគ្រោះមហន្តរាយផ្សេងៗ
- សហការជាមួយមន្ទីរជំនាញចុះអង្កេតស្រាវជ្រាវកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ចំពោះក្រុមគ្រួសារងាយរងគ្រោះនិងគ្រួសារងាយរងហានិភ័យ។
- ស្ត្រីមានសមត្ថភាពចំណេះដឹង ជំនាញវិជ្ជាជីវៈ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមប្រកួតប្រជែងអភិវឌ្ឍសង្គម ប្រកបដោយស្មើភាព សមភាព និងសមធម៌
- ក្រុមជនងាយរងនិងក្រុមជនរងគ្រោះទទួលសេវាថែទាំឧបត្ថម្ភគាំពារសុខភាពនិងសុវត្ថិភាពល្អប្រសើជនពិការនិងកុមារកំព្រាមានលទ្ធភាពនិងសមត្ថភាព ចេញទៅប្រកបរបរតាមទីផ្សារលើកកម្ពស់ឱ្យស្ត្រីបានចូលបំរើការងារក្នុងសង្គម។

**២.៣.៣-ស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

- ពលរដ្ឋរស់នៅក្នុងបរិស្ថានស្អាត មានបង្គន់អនាម័យមានបច្ចេកទេសប្រើប្រាស់គ្រប់ផ្ទះនិងមានទឹកស្អាត ប្រើប្រាស់គ្រប់គ្រួសារ។
- ស្តា អភិវឌ្ឍប្រព័ន្ធបង្ហូរ និងរំដោះជំន់ទឹកភ្លៀង មិនឱ្យមានការលិចលង់តាមទីផ្សារ និងក្នុងភូមិ។
- ពលរដ្ឋបានយល់ដឹងពីគ្រប់គ្រង និងទុកដាក់ កាកសំណល់រឹង រាវ មិនឱ្យប៉ះពាល់បរិស្ថាន និងមិនមានការការបំពុលបរិស្ថាន ។
- ពង្រឹងកិច្ចការពារធនធានព្រៃឈើ ឱ្យមាននិរន្តរភាព ការពារធនធានជលផលមាននិរន្តរភាព និងបង្កើតវារីវប្បកម្ម ។

**២.៣.៤-ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

- ពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធកាន់កាប់ដីធ្លី កាត់បន្ថយទំនាស់ដីធ្លី។
- កាត់បន្ថយភាពងាយរងគ្រោះស្ត្រី-កុមារដោយសារការជួញដូរ និងការរំលោភផ្លូវភេទ។
- កាត់បន្ថយភាពងាយរងគ្រោះស្ត្រី-កុមារដោយសារអំពើហិង្សា
- ពលរដ្ឋបានយល់ដឹងពីសារប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- ការអនុវត្តគោលនយោបាយ ភូមិឃុំសុវត្ថិភាពឱ្យមានភាពកាន់តែប្រសើរឡើង និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។
- សន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានភាពល្អប្រសើឡើង។
- រដ្ឋបាលឃុំ និង ភូមិ មានទីកន្លែងល្អប្រសើសម្រាប់ផ្តល់សេវាជូនពលរដ្ឋ

**២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍**

**២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច**

- ជំរុញការស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ។
- បង្កើនការផ្តល់ចំណេះដឹងផ្នែកបច្ចេកទេសដំណាំស្រូវបង្កើនទិន្នផលស្រូវ។

- ជំរុញការផ្តល់និងផ្សព្វផ្សាយពូជស្រូវដែលមានទិន្នផលខ្ពស់ ពង្រឹងសេវាផ្សព្វផ្សាយកសិកម្ម។
- ពង្រឹងការផ្សព្វផ្សាយនិងលើកទឹកចិត្តដល់ប្រជាកសិករនិងការធ្វើស្រែតាមបែបប្រពលវប្បកម្ម។
- ពង្រឹងសមត្ថភាពនិងការគ្រប់គ្រងសហគមន៍កសិកម្ម។
- ជំរុញការផ្តល់បច្ចេកទេសដំណាំ និងពង្រឹងភ្នាក់ងារកសិកម្មជួយអន្តរាគមន៍ទាន់ពេលវេលានិងការផ្តល់ពូជដំណាំបង្កើនគុណភាព។
- បង្កើនការផ្តល់បច្ចេកទេសយល់ដឹងពីសុខភាពសត្វ និងជំងឺឆ្លង។
- បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ទប់ស្កាត់ការនាំចូល និងជួយរកទីផ្សារផលិតផលសត្វជូនកសិករ។
- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។
- ជំរុញការអភិវឌ្ឍប្រព័ន្ធរំដោះ និងបង្ហូរទឹកការពារគុណភាពផ្លូវ។
- សហការបង្កើនការផ្សព្វផ្សាយព័ត៌មានឧតុនិយម។
- ជំរុញការផ្តល់ជំនាញវិជ្ជាជីវៈជំនាញអាជីវកម្ម សិប្បកម្ម និងការសហការផ្តល់ទុនបង្កើតមុខរបរ។
- បង្កើនការយល់ដឹងពីផលប៉ះពាល់នៃការធ្វើចំណាក ស្រុកនិងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។
- បង្កើនកិច្ចសហការជាមួយអង្គការពាក់ព័ន្ធជួយផ្តល់ការ បណ្តុះបណ្តាលសមត្ថភាពស្ត្រីបង្កើនភាពអង់អាចចូលរួមអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ដើម្បីឲ្យមានជំនឿចិត្តលើខ្លួនឯងពីការធ្វើអាជីវកម្ម ឬការងាររកប្រាក់ចំណូលផ្សេងៗ ។
- សហការជំរុញការផ្តល់ជំនាញវិជ្ជាជីវៈផ្នែកទេសចរណ៍បង្កើនធនធានមនុស្ស ដើម្បីកសាងពង្រីកហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ និងធ្វើការស្តារអភិវឌ្ឍនូវរមណីយដ្ឋានដែលមានស្រាប់រមណីយដ្ឋានដែលរងការបំពុលបរិស្ថានឱ្យមាន សោភណ័ភាពសម្រាប់ភ្ញៀវទេសចរណ៍។
- ពង្រឹងវិធានការការពាររមណីយធម្មជាតិ ។
- បង្កើនកិច្ចសហការជំរុញការរៀបចំបណ្តាញអគ្គិសនីឱ្យបានដល់ផ្ទះប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានគ្រប់តាមតម្រូវការ។

### ២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

- ជំរុញការអប់រំផ្សព្វផ្សាយ ដល់ឪពុកម្តាយឲ្យយល់ដឹងពីតំម្លៃការសិក្សារបស់កុមារតូច បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍពង្រីកការគាំទ្រតាមគ្រប់រូបភាពឱ្យសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍មានដំណើរការបានល្អប្រសើរ។
- បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍនិងមន្ទីរអប់រំជួយបង្កើតសាលាមត្តេយ្យនិង មត្តេយ្យសិក្សាសហគមន៍បានគ្រប់តាមតម្រូវការ។
- បង្កើនការយល់ដឹងដល់ឪពុកម្តាយ អាណាព្យាបាលក្នុងការគាំពារ និងអភិវឌ្ឍន៍កុមារតូចអាយុក្រោម៦ឆ្នាំ។

- ពង្រឹងកិច្ចសហការជំរុញការជួយគាំទ្រដល់ មធ្យោបាយធ្វើដំណើរនានាដល់គ្រួសារ សិស្សក្រីក្រនិងការផ្តល់អាហារូបករណ៍ បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ពីតម្លៃនៃការសិក្សាដល់មូលដ្ឋានដាច់ស្រយាល ។
- ពង្រីកការផ្សព្វផ្សាយនិងបង្កើនការប្រមូលកុមារដល់អាយុចូលរៀន(៦-១៤ឆ្នាំ)នៅបឋមសិក្សានិងអនុវិទ្យាល័យនិងការផ្សព្វផ្សាយ និងជំរុញឱ្យពលរដ្ឋមានការចូលរួមលើកកម្ពស់អក្ខរកម្ម និងលុបបំបាត់អនក្ខរភាព។
- សហការនិងជំរុញបង្កើតឥណទានកម្ចីការប្រាក់ទាប ដើម្បីផ្តល់ដល់សិក្ខាកាមប្រជាពលរដ្ឋ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈរួច និងគ្មានលទ្ធភាពបង្កើតមុខរបរផ្ទាល់ខ្លួនប្រចាំគ្រួសារ។
- បង្កើនការយល់ដឹងពីការថែរក្សាសុខភាពដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយសំរាល និងជំរុញការផ្តល់សេវាពិនិត្យផ្ទៃពោះនៅតាមមូលដ្ឋាន បង្កើនការយល់ដឹងពីការសំរាលកូន និងគាំទ្រមធ្យោបាយធ្វើដំណើរដល់ស្ត្រីមានបញ្ហាពេលសំរាល។
- បង្កើនការទទួលយកសេវាសុខភាពសំរាប់កុមារ ថែទាំសុខភាពពលរដ្ឋតាមគ្រួសារឱ្យបានល្អប្រសើរ និងបង្កើនការយល់ដឹងនិងសហការជំរុញការផ្តល់ពីអាហារូបត្ថម្ភដល់ស្ត្រី ទារកនិងកុមារអាយុក្រោម៥ឆ្នាំ។
- ពង្រឹង និងពង្រីកការផ្តល់សេវាសុខភាពបន្តពូជ សកម្មភាពពន្យារកំណើតនិងការចាក់ថ្នាំការពារដល់ស្ត្រីក្នុងវ័យបន្តពូជ។
- សហការ ផ្សព្វផ្សាយនិងជំរុញដល់ប្រជាពលរដ្ឋដែលកើតជំងឺអេដស៍មកទទួលយកសេវាថែទាំសុខភាព និងបង្កើនសកម្មភាពអប់រំផ្សព្វផ្សាយអំពី ជំងឺអេដស៍ និងជំងឺកាមរោគ ជំរុញការផ្តល់សេវាថែទាំគាំពារជំងឺអេដស៍។
- ពង្រឹងនិងពង្រីកសេវាការពារនិងបង្ការការចម្លងពីម្តាយទៅកូន ផ្តល់ការយល់ដឹង ជំរុញការថែទាំគាំពារសុខភាព និងមានវិធានការទប់ស្កាត់នៃការឆ្លងជំងឺគ្រប់ប្រភេទ។
- ពង្រឹងកិច្ចសហការបង្កើនការអប់រំផ្សព្វផ្សាយក្នុងសហគមន៍ ឲ្យគោរពនូវសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលពីវិធានការការពារទប់ស្កាត់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩(ពិសេសពកុំពការពារ)។
- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន គ្រប់សហគមន៍ អនុវត្តឲ្យបានហ្មឹងម៉ាត់នូវសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ពីវិធានការការពារ សុខភាពអនាម័យដើម្បីការពារទប់ស្កាត់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺរាតត្បាតផ្សេងទៀត។
- បង្កើនការផ្សព្វផ្សាយនូវ យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទជំងឺកូវីដ-១៩។
- បង្កើនកិច្ចសហការជំរុញការផ្តល់សេវាសង្គមជួយថែទាំឧបត្ថម្ភគាំពារសុខភាពនិងសុវត្ថិភាព និងបង្កើនកិច្ចសហការបង្កើតសមាគមន៍ជនងាយរងគ្រោះ។
- ផ្សព្វផ្សាយនិងជំរុញក្រុមជនងាយរងនិងក្រុមជនរងគ្រោះមកទទួលយកសេវាថែទាំឧបត្ថម្ភគាំពារសុខភាពនិងសុវត្ថិភាព បង្កើនការផ្តល់ចំណេះដឹង និងសមត្ថភាពជំនាញវិជ្ជាជីវៈសមស្រប និងការផ្សព្វផ្សាយលុបបំបាត់ភាពរើសអើង។

- សហការជាមួយមន្ទីរជំនាញចុះអង្កេតស្រាវជ្រាវកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ចំពោះក្រុមគ្រួសារងាយរងគ្រោះនិងគ្រួសារងាយរងហានិភ័យ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធជួយជំរុញឱ្យគ្រប់ស្ថាប័នរដ្ឋនិងឯកជនអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ផ្តល់អនុសាសន៍ ឬ ព័ត៌មានត្រឡប់ផ្តល់ការលើកទឹកចិត្ត ជួយដោះស្រាយរាល់បញ្ហាដែលជួបប្រទះ គាំទ្រជួយផ្តល់ឱកាសឱ្យស្ត្រីចូលរួមក្នុងកម្មវិធីផ្សេងៗដូចជាសិក្ខាសាលា និងជំរុញការផ្តល់ចំណេះដឹងស្តីពីការបញ្ជ្រាបយេនឌ័របរិយាប័ន្ន និងសមធម៌សង្គម។
- បង្កើនការផ្តល់ព័ត៌មានពីការជ្រើសរើសស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍ សង្គមដល់ស្ត្រីឱ្យបានទាន់ពេល។

## ២.៤.៣. យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

- សហការជំរុញការតណ្តាញ ការផ្គត់ផ្គង់អណ្តូងទឹកស្អាត និងបង្កើនការផ្សព្វផ្សាយពីការប្រើប្រាស់ទឹកស្អាត។
- បង្កើនការផ្សព្វផ្សាយពីការប្រើប្រាស់បង្គន់អនាម័យនិងការថែរក្សាអនាម័យបរិស្ថាន និងសហការបង្កើនការផ្គត់ផ្គង់បង្គន់អនាម័យ និងផ្តល់សម្ភារៈសាងសង់បង្គន់ ។
- បង្កើនការផ្សព្វផ្សាយយល់ដឹងពីការថែរក្សាអនាម័យបរិស្ថាន។
- បង្កើនការយល់ដឹងពីគ្រប់គ្រង ទុកដាក់ សំណល់រឹង រាវ និង ការផ្តល់សម្ភារទុកដាក់ សំណល់រឹងតាមទីសាធារណៈ ទីប្រជុំជននិងគ្រួសារសហគមន៍ និងជំរុញឱ្យមានសេវាប្រមូលនិងដឹកជញ្ជូនសម្រាម។
- ជំរុញការស្តារនិងរៀបចំប្រព័ន្ធទុកដាក់និងបង្ហូរទឹកស្អុយ ការស្តារនិងអភិវឌ្ឍប្រព័ន្ធរំដោះទឹក ។
- បង្កើនយល់ដឹងការគ្រប់គ្រងទុកដាកកាកសំណល់រាវមិនឱ្យហូរចូលក្នុងសមុទ្រនិងជំរុញឱ្យបង្កើតប្រព័ន្ធការពារនិងទុកដាក់កាកសំណល់រាវ។
- ពង្រឹងវិធានការទប់ស្កាត់ការបង្ហូរកាកសំណល់និងការចាក់ដីចូលអូរប្រឡាយ និងការបំពានយកដីចំណីផ្លូវនិងប្រឡាយអូរជាកម្មសិទ្ធិ។
- ពង្រឹងវិធានការគ្រប់គ្រងការពារទប់ស្កាត់ការបំផ្លាញព្រៃឈើយកដីជាកម្មសិទ្ធនិងការធ្វើអាជីវកម្មលើព្រៃឈើហួសកម្រិត។
- បង្កើនការយល់ដឹងពីច្បាប់និងសារប្រយោជន៍ព្រៃឈើ និងពង្រឹងវិធានការគ្រប់គ្រងការពារទប់ស្កាត់ការប្រម៉ាញ់សត្វ។
- ពង្រឹងវិធានការទបប់ស្កាត់ការកាប់បំផ្លាញព្រៃលិចនិងការធ្វើអាជីវកម្មក្នុងតំបន់អភិរក្ស ។
- សហការជំរុញផ្តល់ជំនាញវារីវប្បកម្មនិងការផ្តល់ពូជនិងទុនបង្កើតរបរ។

## ២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

- បង្កើនផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់នានា ពង្រឹងការអនុវត្តច្បាប់ភូមិបាល និង ជំរុញការចុះវាស់វែងនិងផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី។
- បង្កើនការយល់ដឹងពីច្បាប់ប្រើប្រាស់ពលកម្មកុមារ ការជួញដូរមនុស្ស និងពង្រឹងវិធានការទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់ពលកម្មកុមារ។
- បង្កើនការផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សា ពង្រឹងវិធានការអប់រំទប់ស្កាត់នៅគ្រប់សហគមន៍និងបង្កើនសកម្មភាពជួយសង្គ្រោះជនរងគ្រោះ បន្តពង្រឹងការជួយឧបត្ថម្ភដល់គ្រួសារក្រីក្រ បន្តកិច្ចសហការជួយថែរក្សាគាំពារសុខភាពនិងសុកមាលភាពរបស់គាត់ អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលសហការផ្តល់ជំនាញចំណេះដឹង និងការជួយផ្តល់ទុនសម្រាប់បង្កើតមុខរបរ។
- បង្កើនការផ្តល់ចំណេះដឹងស្តីពីការលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រីនិងគ្រួសារខ្មែរ ។
- បង្កើនការយល់ដឹងពិសារប្រយោជន៍នៃអត្រានុកូលដ្ឋាន ជំរុញការផ្តល់សេវា និងបង្កើនការផ្សព្វផ្សាយពលរដ្ឋឱ្យមកទទួលយកសេវាអត្រានុកូលដ្ឋាន។
- បង្កើនការផ្សព្វផ្សាយឱ្យពលរដ្ឋយល់ដឹងនិងទទួលយកសេវាសាធារណៈតាមច្រកចេញចូលតែមួយនិងលើកកម្ពស់ការសេវាជូនពលរដ្ឋប្រកបដោយតម្លាភាពគណនេយ្យភាពនិងមានប្រសិទ្ធភាពខ្ពស់
- បង្កើនការយល់ដឹងពីច្បាប់ ពង្រឹងវិធានការអនុវត្តច្បាប់ចរាចរណ៍ ។
- បង្កើនការផ្សព្វផ្សាយនិងពង្រឹងវិធានការទប់ស្កាត់លែងសត្វពាហណៈនៅតាមដងផ្លូវសាធារណៈ។
- បង្កើនការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់ដោយសារផលពីការប្រើប្រាស់គ្រឿងញៀន។
- ពង្រឹងវិធានការការពារថែរក្សារក្សាសុវត្ថិភាពសន្តិសុខ សណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន។
- បង្កើនការផ្សព្វផ្សាយនិងពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។
- បង្កើនកិច្ចសហការស្វែងរកមូលនិធិខាងក្រៅនិងប្រើប្រាស់មូលនិធិរដ្ឋបាលឃុំធ្វើការកែលម្អ និងសាងសង់ទីស្នាក់ការភូមិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្តព្រះសីហនុ**
**ក្រុង ស្រុក ខណ្ឌព្រៃនប់**
**រដ្ឋបាលឃុំ សង្កាត់តានៃ**
លេខ ០០១...ដ.ក

# ដីកា
## ស្តីពី
បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តានៃ
ក្រុង ស្រុក ខណ្ឌព្រៃនប់ រាជធានី ខេត្តព្រះសីហនុ

## ក្រុមប្រឹក្សាឃុំ តានៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧០/១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរសិទ្ធិអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងតាមកិច្ចប្រជុំអនុម័តរបស់ក្រុមប្រឹក្សាឃុំ អាណត្តិទី៥ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២

## សម្រេច
## ជំពូកទី១
## អំពីកិច្ចប្រជុំ

**ប្រការ១ .**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ មានពីរប្រភេទគឺ កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។

ក្រុមប្រឹក្សាឃុំ ត្រូវធ្វើការប្រជុំសាមញ្ញយ៉ាងតិចចំនួនមួយដងក្នុងមួយខែ។

កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ មិនត្រូវប្រារព្ធធ្វើឡើងមុន២៥ (ម្ភៃប្រាំ) ថ្ងៃ និងលើសពី ៣៥ (សាមសិបប្រាំ) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ។

ក្រុមប្រឹក្សាឃុំតានៃ ត្រូវអនុម័តប្រតិទិន នៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនសម្រាប់កិច្ចប្រជុំរយៈពេល ១២ (ដប់ពីរ) ខែ មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី២ និងប្រតិទិនសម្រាប់កិច្ចប្រជុំលើកក្រោយៗទៀត ក្នុងរយៈពេល១២ (ដប់ពីរ)ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងឱ្យបានជាក់លាក់។

ក្រុមប្រឹក្សាឃុំតានៃ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេល មិនឱ្យលើសពី៣(បី)ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាឃុំ បានអនុម័ត។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ អាចធ្វើការប្រជុំវិសាមញ្ញ ដើម្បីពិភាក្សាលើការងារនានាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានកំណត់ថាជាកិច្ចការពិសេស ឬកិច្ចការបន្ទាន់ចាំបាច់។

កិច្ចប្រជុំវិសាមញ្ញ ត្រូវប្រារព្ធឡើងក្នុងអំឡុងពេល៣ (បី) ថ្ងៃ បន្ទាប់ពីប្រធានក្រុមប្រឹក្សាឃុំ សម្រេចឱ្យមានការរៀបចំកិច្ចប្រជុំវិសាមញ្ញនេះ ឬបន្ទាប់ពីសមាជិកចំនួន១/៣ (មួយភាគបី) យ៉ាងតិច នៃសមាជិកក្រុមប្រឹក្សាទាំងមូល ស្នើសុំឱ្យរៀបចំកិច្ចប្រជុំវិសាមញ្ញ។

ការសម្រេច ឬការស្នើសុំឱ្យមានកិច្ចប្រជុំវិសាមញ្ញ ត្រូវបញ្ជាក់ពីមូលហេតុសមស្រប។

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ និងគណៈកម្មាធិការជំនួយការត្រូវធ្វើជាសាធារណៈ លើកលែងតែបញ្ហាដូចមានចែងក្នុងប្រការ៩ នៃបទបញ្ជាផ្ទៃក្នុងនេះ។

ប្រការ២ .

ប្រធានក្រុមប្រឹក្សាឃុំតានៃ ជាអ្នកកោះអញ្ជើញសមាជិកក្រុមប្រឹក្សារបស់ខ្លួនឱ្យចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ។ ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំតានៃ មិនអាចកោះអញ្ជើញប្រជុំបានដោយសារកាលៈទេសពិសេស ឬអវត្តមានរបស់ប្រធានក្រុមប្រឹក្សា ជំទប់ រងតាមឋានានុក្រម អាចកោះអញ្ជើញប្រជុំក្រុមប្រឹក្សាស្របតាមច្បាប់ និងលិខិតបទដ្ឋានកំណត់។

គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ត្រូវមានលិខិតអញ្ជើញដែលត្រូវប្រគល់ជូនសមាជិកគ្រប់រូបនៃក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល៣ (បី) ថ្ងៃ មុនកិច្ចប្រជុំចាប់ផ្តើម។

លិខិតអញ្ជើញត្រូវបញ្ជាក់ពីកន្លែង ពេល ម៉ោង ថ្ងៃ ខែ ឆ្នាំ របៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងត្រូវភ្ជាប់ជាមួយនូវឯកសារនានា ប្រសិនបើមាន។

ប្រសិនបើមានបញ្ហាបន្ទាន់កើតមានឡើងនៅក្នុងឃុំ ការកោះអញ្ជើញប្រជុំវិសាមញ្ញអាចបន្ថយមកត្រឹមរយៈពេល៦ (ប្រាំមួយ) ម៉ោង យ៉ាងតិចមុនការប្រជុំចាប់ផ្តើម។

ប្រការ៣ .

កាលបរិច្ឆេទនិងកន្លែងប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ត្រូវបិទផ្សាយនៅលើក្តារព័ត៌មានសាធារណៈនៅសាលាឃុំ សង្កាត់ និងតាមកន្លែងសាធារណៈគ្រប់ភូមិក្នុងឃុំ ។ ពេលវេលានៃការបិទផ្សាយ ត្រូវអនុវត្តដូចប្រការ១៣ នៃបទបញ្ជាផ្ទៃក្នុងនេះ។

ប្រការ៤ .-

របៀបវារៈ នៃកិច្ចប្រជុំសាមញ្ញ ចាំបាច់ត្រូវមាន៖

- ការពិនិត្យឡើងវិញ និងអនុម័តកំណត់ហេតុនៃអង្គប្រជុំលើកមុន
- ការពិភាក្សា និងអនុម័តកិច្ចការដែលបានអនុវត្តក្នុងខែ កិច្ចការដែលនៅសេសសល់ និងទិសដៅការងារខែបន្ទាប់

- ការពិភាក្សា និងអនុម័តលើឯកសារដែលបានប្រគល់ជូនសមាជិកក្រុមប្រឹក្សាឃុំ រួមមាន៖
    + ស្ថានភាពនៃការគ្រប់គ្រងប្រើប្រាស់មូលនិធិឃុំ និងចំណូល ចំណាយថវិកាឃុំ សង្កាត់
    + ស្ថានភាពនៃការអនុវត្តគម្រោងនានាដោយរដ្ឋបាលឃុំ
    + ឯកសារផ្សេងៗទៀត។
- បញ្ហាផ្សេងៗ។

ប្រធានក្រុមប្រឹក្សាឃុំតានៃ ដោយមានស្មៀនឃុំ ជាជំនួយការត្រូវរៀបចំរបៀបវារៈនៃកិច្ចប្រជុំ។

សមាជិកក្រុមប្រឹក្សាឃុំចំនួន១/៣ (មួយភាគបី) នៃសមាជិកក្រុមប្រឹក្សាឃុំ ទាំងមូលមានសិទ្ធិស្នើសុំដាក់បញ្ចូលនូវបញ្ហានានាដែលស្ថិតក្នុងវង្វង់តួនាទី មុខងារ និងអំណាចរបស់ក្រុមប្រឹក្សាទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំ។

ការស្នើសុំដាក់បញ្ចូលបញ្ហានានាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ ត្រូវមានពាក្យសុំដែលភ្ជាប់ជាមួយនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ ហើយដែលត្រូវផ្តល់ជូនប្រធានក្រុមប្រឹក្សាឃុំ តាមរយៈស្មៀនឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិច២ (ពីរ) ថ្ងៃ មុនការប្រជុំចាប់ផ្តើម។

ប្រការ៥ ._

ស្មៀនឃុំតានៃ ត្រូវរក្សាទុកនូវឯកសារច្បាប់ដើមនៃរបៀបវារៈកិច្ចប្រជុំ ឯកសារ កំណត់ហេតុ និងមាតិកាសំខាន់ៗ នៃកិច្ចប្រជុំនៅក្នុងសាលាឃុំ និងត្រូវថតចម្លងជាឯកសារសម្រាប់បិទផ្សាយឱ្យសាធារណជនពិនិត្យមើល។

## ជំពូកទី២

## អំពីរបៀបរបបប្រជុំរបស់ក្រុមប្រឹក្សាឃុំ តានៃ

ប្រការ៦ ._

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃដែលអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកក្រុមប្រឹក្សាឃុំលើសពីពាក់កណ្តាល នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូលចូលរួមជាក់ស្តែងគឺ៖

- ក្នុងករណីក្រុមប្រឹក្សាឃុំតាសនៃ មានសមាជិកចំនួន៥ (ប្រាំ) រូប ត្រូវមានសមាជិកយ៉ាងតិចចំនួន ៣ (បី) រូប ចូលរួមក្នុងអង្គប្រជុំ
- ក្នុងករណីក្រុមប្រឹក្សាឃុំតានៃ មានសមាជិកចំនួន៧ (ប្រាំពីរ) រូប ត្រូវមានសមាជិកយ៉ាងតិចចំនួន៤ (បួន) រូប ចូលរួមក្នុងអង្គប្រជុំ
- ក្នុងករណីក្រុមប្រឹក្សាឃុំតានៃ មានសមាជិកចំនួន៩ (ប្រាំបួន) រូប ត្រូវមានសមាជិកយ៉ាងតិចចំនួន៥ (ប្រាំ) រូប ចូលរួមក្នុងអង្គប្រជុំ
- ក្នុងករណីក្រុមប្រឹក្សាឃុំតានៃ មានសមាជិកចំនួន១១ (ដប់មួយ) រូប ត្រូវមានសមាជិកយ៉ាងតិចចំនួន៦ (ប្រាំមួយ) រូប ចូលរួមក្នុងអង្គប្រជុំ។

ប្រការ៧ ._

ក្រុមប្រឹក្សាឃុំតានៃ ត្រូវដំណើរការប្រជុំតាមកម្មវិធីដែលមានតាមលំដាប់លំដោយដូចតទៅ៖

- ពិនិត្យកូរ៉ុមសម្រាប់ការប្រជុំ

- ពិនិត្យនិងអនុម័តរបៀបវារៈនៃកិច្ចប្រជុំដូចមានចែងក្នុងប្រកា៤ នៃបទបញ្ជាផ្ទៃក្នុង មានជាអាទិ៍៖
  + ពិភាក្សា និងអនុម័តលើកំណត់ហេតុកិច្ចប្រជុំលើកមុន
  + ពិភាក្សា និងអនុម័តលើឯកសារដែលបានដាក់ជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
  + បញ្ហាផ្សេងៗ។

ប្រការ៨ .–

សមាជិកគ្រប់រូប នៃក្រុមប្រឹក្សាឃុំតានៃ មានសិទ្ធិបញ្ចេញមតិយោបល់ និងបោះឆ្នោតអនុម័តនៅគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ស្មៀនឃុំតានៃ និងបុគ្គលិកផ្សេងទៀតដែលតែងតាំងដោយក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិចូលរួម និងអាចបញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ទៅតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាឃុំតានៃ ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ប្រធានក្រុមប្រឹក្សាឃុំតានៃ ត្រូវអញ្ជើញតំណាង២ (ពីរ) រូប នៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំ តានៃ ដើម្បីចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ។

ប្រការ៩ .–

ក្រុមប្រឹក្សាឃុំតានៃអាចចាត់ឱ្យមានកិច្ចប្រជុំជាសម្ងាត់បាន។

កិច្ចប្រជុំជាសម្ងាត់របស់ក្រុមប្រឹក្សាឃុំ គឺជាការប្រជុំដើម្បីពិភាក្សាលើបញ្ហាដូចតទៅ៖

- ការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ
- អំពីបញ្ហាសន្តិសុខក្នុងឃុំ
- អំពីការរៀបចំគម្រោងដើម្បីធ្វើលទ្ធកម្មអ្វីមួយ
- ការរៀបចំសំណុំរឿងដើម្បីតវ៉ាឬការពារក្តីអ្វីមួយ
- ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងកិត្តិយសបុគ្គល...។

ប្រការ១០ .–

ក្នុងកិច្ចប្រជុំជាសម្ងាត់ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានស្មៀនឃុំ សង្កាត់ជាជំនួយការត្រូវពិនិត្យឱ្យបានច្បាស់ថាមានតែសមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ សង្កាត់តែប៉ុណ្ណោះ ដែលមានសិទ្ធិចូលរួមក្នុងអង្គប្រជុំ។

## ជំពូកទី៣

## អំពីការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំតានៃ

ប្រការ១១ .–

គ្រប់ការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ដែលអាចចាត់ទុកជាបានការលុះត្រាតែ សេចក្តីសម្រេចនោះ ត្រូវបានអនុម័តដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ ទាំងមូល ជាពិសេសការអនុម័តលើបញ្ហាណាមួយ ដូចមានខាងក្រោម៖

- ផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

- គម្រោងថវិកាឃុំ
- កំណត់តម្លៃសារពើពន្ធមូលដ្ឋានមិនមែនសារពើពន្ធមូលដ្ឋាន និងកំណត់កម្រៃសេវាផ្សេងៗ
- ដីកានិងបទបញ្ជាផ្ទៃក្នុងរបស់ឃុំ
- ការដាក់វិន័យសមាជិកក្រុមប្រឹក្សាឃុំ ណាម្នាក់ដែលស្របទៅតាមមាត្រា៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ចំពោះការសម្រេចលើកិច្ចការផ្សេងពីនេះអាចចាត់ទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃចំនួនសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។

ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ និងត្រូវប្រកាសភ្លាមៗនូវចំនួនសំឡេងយល់ព្រម សំឡេងជំទាស់ និងសំឡេងអនុប្បវាទ ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុលើកលែងតែក្នុងការអនុម័តដូចមានចែង ក្នុងប្រការ៣៦ នៃបទបញ្ជាផ្ទៃក្នុងនេះ។

ប្រការ១២ .–

ការស្នើសុំពិភាក្សា និងអនុម័តដើម្បីធ្វើការកែប្រែលើដីកាឃុំ សង្កាត់អាចប្រព្រឹត្តទៅបានតែនៅក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំតានៃ បន្ទាប់ពីកិច្ចប្រជុំបានអនុម័តលើសំណើនោះ។

ប្រការ១៣ .–

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានក្រុមប្រឹក្សាឃុំតានៃ ត្រូវចាត់ឱ្យធ្វើការផ្សព្វផ្សាយដល់សាធារណជនអំពីសេចក្តីសម្រេចនានារបស់ខ្លួន។

សេចក្តីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំតានៃ ត្រូវចាត់ឱ្យធ្វើការបិទផ្សាយជាសាធារណៈនៅលើក្តារព័ត៌មាននៅសាលាឃុំ សង្កាត់ក្នុងរយៈពេល៤៨ (សែសិបប្រាំបី) ម៉ោង យ៉ាងតិច។

ប្រការ១៤ .–

ស្មៀនឃុំត្រូវរក្សា និងតម្កល់ច្បាប់ដើមកំណត់ហេតុនៃកិច្ចប្រជុំនៅសាលាឃុំ និងថតចម្លងកំណត់ហេតុ នៃកិច្ចប្រជុំសម្រាប់សាធារណជនធ្វើការពិនិត្យ ឬចម្លងចែកជូនប្រជាពលរដ្ឋដែលមានបំណងស្នើសុំដោយត្រូវបង់ថ្លៃសម្រាប់ការថតចម្លងឯកសារ។

## ជំពូកទី៤
## អំពីសិទ្ធិអំណាចរបស់អធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ

ប្រការ១៥ .–

ប្រធានក្រុមប្រឹក្សាឃុំតានៃ សង្កាត់ត្រូវធ្វើជាអធិបតីនៅគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ របស់ខ្លួន។

ក្នុងករណី ប្រធានក្រុមប្រឹក្សាឃុំតានៃ អវត្តមាន ជំទប់ទី១ ត្រូវធ្វើជាអធិបតីនៃអង្គប្រជុំ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំតានៃ ឬជំទប់ទី១ អវត្តមាន ជំទប់ទី២ ត្រូវធ្វើជាអធិបតីនៃអង្គប្រជុំ។

ប្រសិនបើប្រធានក្រុមប្រឹក្សាឃុំតានៃ ជំទប់ទី១ ជំទប់ទី២ អវត្តមាន ប៉ុន្តែសមាជិកក្រុមប្រឹក្សាឃុំមានវត្តមានគ្រប់ចំនួនអាចដំណើរការប្រជុំបានកិច្ចប្រជុំត្រូវជ្រើសរើសសមាជិកណាម្នាក់ធ្វើជាអធិបតីនៃអង្គប្រជុំ។

ប្រការ១៦ .–

មេឃុំតានៃ ត្រូវធ្វើលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ដើម្បីប្រគល់សិទ្ធិទៅជំទប់ តាមឋានានុក្រមឱ្យធ្វើជាមេឃុំ ក្នុងអំឡុងពេលដែលមេឃុំ អវត្តមាន។

ប្រការ១៧ .–

អធិបតីនៃអង្គប្រជុំ ត្រូវធានាឱ្យកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រព្រឹត្តទៅក្នុងលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន។

អធិបតីនៃអង្គប្រជុំ ត្រូវធានាឱ្យមានសមភាពចំពោះសមាជិកក្រុមប្រឹក្សាឃុំ ទាំងអស់។

សមាជិកម្នាក់ៗ នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ដែលមានបំណងបញ្ចេញមតិយោបល់ ត្រូវលើកដៃសុំការអនុញ្ញាតពីប្រធានអង្គប្រជុំ។

រយៈពេលបញ្ចេញមតិរបស់សមាជិកម្នាក់ៗ ក្នុងមួយលើកៗមិនលើសពី១៥នាទី ហើយត្រូវមានមតិយោបល់តែពីប្រធានបទដែលកំពុងពិភាក្សា។ ប្រធានអង្គប្រជុំអាចអនុញ្ញាតបន្ថែមរយៈពេល៥នាទីទៀតបាន ប្រសិនបើយល់ឃើញថា មានប្រយោជន៍ដល់ប្រធានបទដែលកំពុងពិភាក្សា។ ការបន្ថែមនេះអាចអនុញ្ញាតឱ្យបន្តបាន២ (ពីរ) ដង ក្នុងប្រធានបទដដែល។

ក្នុងករណីសមាជិកក្រុមប្រឹក្សាឃុំតានៃ រូបណា មានមតិយោបល់ក្រៅប្រធានបទ ប្រធានអង្គប្រជុំត្រូវរំលឹកឱ្យមានមតិយោបល់តែពីប្រធានបទដែលកំពុងពិភាក្សា។ ក្នុងករណីដែលប្រធានក្រើនរំលឹកហើយសមាជិកនោះនៅតែពុំព្រមអនុវត្តតាមការណែនាំរបស់ប្រធានអង្គប្រជុំ ប្រធានអង្គប្រជុំមានសិទ្ធិបញ្ឈប់ការមានមតិយោបល់របស់សមាជិកនោះ។ ក្នុងករណី នៅតែបន្តចចេសរឹងរូសតទៅទៀត ប្រធានអង្គប្រជុំអាចបណ្តេញសមាជិករូបនោះ ចេញពីអង្គប្រជុំសម្រាប់របៀបវារៈដែលកំពុងពិភាក្សានោះ។ ចំពោះរបៀបវារៈផ្សេងពីនេះ សមាជិកដែលត្រូវបណ្តេញចេញនោះ មានសិទ្ធិចូលរួមប្រជុំជាធម្មតាវិញបាន។

សមាជិកក្រុមប្រឹក្សាឃុំតានៃម្នាក់ៗ មានសិទ្ធិធ្វើការបញ្ចេញមតិយោបល់ដោយសេរីដោយពុំមានការភ័យខ្លាច ឬការបំភិតបំភ័យឡើយ។

ការបញ្ចេញមតិយោបល់ក្នុងអង្គប្រជុំរបស់សមាជិកឃុំតានៃ គ្រប់រូប នៃក្រុមប្រឹក្សាមិនត្រូវផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានឡើយ។

ប្រការ១៨ .–

អធិបតីនៃអង្គប្រជុំអាចបណ្តេញសមាជិកក្រុមប្រឹក្សាឃុំតានៃ ឬសាធារណជនណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាឃុំ ឬសាធារណជននោះចចេស រឹងរូសធ្វើឱ្យខូចរបៀប

## ជំពូកទី៦

## អំពីកំណត់ហេតុនៃកិច្ចប្រជុំ

ប្រការ២០ .—

កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ត្រូវកត់ត្រានូវបញ្ហាដូចខាងក្រោម៖

- ថ្ងៃ ខែ ឆ្នាំ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ
- ការបញ្ជាក់អះអាងថាការប្រជុំមានលក្ខណៈស្របច្បាប់ (កូរ៉ុម របៀបវារៈ ការបន្ថែមរបៀបវារៈ...)
- បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ ដែលវត្តមាន និងអវត្តមាន
- ឈ្មោះនិងអង្គភាពរបស់អ្នកដែលបានចូលរួមប្រជុំ ប្រសិនបើមាន
- ការអនុម័ត និងចុះហត្ថលេខាលើកំណត់ហេតុ នៃកិច្ចប្រជុំលើកមុន
- សេចក្តីសម្រេច និងលទ្ធផលនៃការបោះឆ្នោតអនុម័តលើបញ្ហាទាំងឡាយក្នុងរបៀបវារៈនៃកិច្ចប្រជុំ រួមទាំងចំណុចដែលបានបន្ថែមក្នុងរបៀបវារៈ
- បញ្ហាផ្សេងៗទៀតដែលត្រូវកត់ត្រា
- ពេលវេលាបិទអង្គប្រជុំ។

ស្មៀនឃុំ ត្រូវជួយដល់ក្រុមប្រឹក្សាឃុំ ដើម្បីរៀបចំកំណត់ហេតុគ្រប់កិច្ចប្រជុំ។

ប្រការ២១ .—

កំណត់ហេតុនៃកិច្ចប្រជុំត្រូវកត់ត្រានូវពាក្យពេចន៍ ឬឃ្លាប្រយោគសំខាន់ៗ ឬមាតិកាសំខាន់ៗនៃកិច្ចពិភាក្សា តែក៏មិនត្រូវកត់ត្រាសង្ខេបខ្លាំងពេកនាំឱ្យបាត់បង់នូវខ្លឹមសារ នៃកិច្ចប្រជុំនោះឡើយ។

សេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដាក់បញ្ចូលក្នុងរបៀបវារៈ នៃកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញលើកបន្ទាប់ដើម្បីអនុម័ត។

សេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញនោះ ត្រូវតែអនុម័តយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាឃុំ ដែលមានវត្តមានក្នុងកិច្ចប្រជុំ។

ក្នុងករណីមានសំណូមពរឱ្យធ្វើការកែសម្រួល ត្រូវតែកែសម្រួលជាបន្ទាន់ហើយបន្ទាប់មកត្រូវបោះឆ្នោតអនុម័តដោយសំឡេងភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាឃុំ ដែលមានវត្តមានក្នុងកិច្ចប្រជុំ។

អធិបតីនៃអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ នៃកិច្ចប្រជុំបន្ទាប់ពីក្រុមប្រឹក្សាឃុំ បានអនុម័តយល់ព្រមលើកំណត់ហេតុនោះ។

ស្មៀនឃុំ ត្រូវថែរក្សាកំណត់ហេតុ នៃកិច្ចប្រជុំដែលបានចុះហត្ថលេខារួចហើយឱ្យបានគង់វង្ស។

ស្មៀនឃុំ ត្រូវថតចម្លងកំណត់ហេតុ នៃកិច្ចប្រជុំដែលបានចុះហត្ថលេខារួចហើយ និងប្រគល់ទៅសមាជិកគ្រប់រូបនៃក្រុមប្រឹក្សាឃុំ ។

## ជំពូកទី៧

## អំពីការខកខានមិនបានចូលរួមប្រជុំ

ប្រការ២២ .—

សមាជិកក្រុមប្រឹក្សាឃុំតានៃ គ្រប់រូបត្រូវតែចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ។

ប្រការ២៣ .-

នៅក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ស្មៀនឃុំ ត្រូវស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ ដែលអវត្តមានដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ប្រការ២៤ .-

សមាជិកក្រុមប្រឹក្សាឃុំមិនអាចអវត្តមានក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដោយគ្មានការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាឃុំ បានឡើយ។

ក្នុងករណីសមាជិកក្រុមប្រឹក្សាឃុំ ណាម្នាក់ដើរចេញពីអង្គប្រជុំ ដោយគ្មានការអនុញ្ញាតពីអធិបតីនៃអង្គប្រជុំត្រូវចាត់ទុកជាអវត្តមានមួយដងដោយគ្មានច្បាប់។

ក្នុងករណីមានធុរៈមិនអាចចូលរួមប្រជុំបាន សមាជិកក្រុមប្រឹក្សាឃុំ ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរជូនប្រធានក្រុមប្រឹក្សាឃុំ នៅមុនពេលកិច្ចប្រជុំចាប់ផ្តើម។

ប្រការ២៥ .-

ប្រធានក្រុមប្រឹក្សា ដែលមានបំណងអវត្តមានពីកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់១ (មួយ) លើក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ក្រុមប្រឹក្សារបស់ខ្លួនយ៉ាងតិច១ (មួយ) ថ្ងៃ មុនកិច្ចប្រជុំដោយបញ្ជាក់ឱ្យច្បាស់លាស់អំពីមូលហេតុ នៃការអវត្តមានពីកិច្ចប្រជុំនេះ។

ក្នុងករណី ប្រធានក្រុមប្រឹក្សាអវត្តមានពីកិច្ចប្រជុំ២ (ពីរ) លើក ជាប់ៗគ្នាឡើងទៅ ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន ត្រូវសុំសេចក្តីសម្រេចពីក្រុមប្រឹក្សាទាំងមូល។ ប្រសិនបើក្រុមប្រឹក្សាអនុម័តមិនយល់ព្រម ត្រូវចាត់ទុកជាការអវត្តមានដោយគ្មានច្បាប់អនុញ្ញាត។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលអវត្តមានក្នុងកិច្ចប្រជុំ២ (ពីរ) លើកជាប់ៗគ្នាឡើងទៅ ដោយមានជំងឺ ត្រូវចាត់ទុកជាការអវត្តមានដោយមានច្បាប់អនុញ្ញាត ប្រសិនបើមានលិខិតបញ្ជាក់ពីគ្រូពេទ្យ។

ប្រការ២៦ .-

ប្រធានក្រុមប្រឹក្សាឃុំ អាចអនុញ្ញាតច្បាប់ឱ្យសមាជិកក្រុមប្រឹក្សាឃុំ អវត្តមានក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបានតែ១ (មួយ) លើកប៉ុណ្ណោះ។

ក្នុងករណី សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អវត្តមានពីកិច្ចប្រជុំ២ (ពីរ) លើក ជាប់ៗគ្នាឡើងទៅដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន ត្រូវសុំសេចក្តីសម្រេចពីក្រុមប្រឹក្សាទាំងមូល។ ប្រសិនបើ ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តមិនយល់ព្រម ត្រូវចាត់ទុកជាការអវត្តមានដោយគ្មានច្បាប់អនុញ្ញាត។

សមាជិកក្រុមប្រឹក្សាឃុំ ដែលអវត្តមានក្នុងកិច្ចប្រជុំ២ (ពីរ) លើកជាប់ៗគ្នាឡើងទៅ ដោយមានជំងឺ ត្រូវចាត់ទុកជាការអវត្តមានដោយមានច្បាប់អនុញ្ញាត ប្រសិនបើមានលិខិតបញ្ជាក់ពីគ្រូពេទ្យ។

ប្រការ២៧ .-

សមាជិកក្រុមប្រឹក្សាឃុំ ណាម្នាក់ក្រោយពីទទួលបានលិខិតអញ្ជើញដូចមានចែងក្នុងប្រការ២ នៃបទបញ្ជាផ្ទៃក្នុងនេះហើយ តែមិនបានចូលរួមប្រជុំដោយគ្មានការអនុញ្ញាត សមាជិកក្រុមប្រឹក្សាឃុំ រូបនោះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងប្រការ២៩ នៃបទបញ្ជាផ្ទៃក្នុងនេះ។

## ជំពូកទី៨
## អំពីទណ្ឌកម្មខាងវិន័យ

ប្រការ២៨ .-

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំតានៃ មានដូចតទៅ៖

- ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ ដែលខកខានមិនបានចូលរួមប្រជុំ ដោយគ្មានច្បាប់អនុញ្ញាត។
- ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ ក្នុងអំឡុងពេលកិច្ចប្រជុំ។

ប្រការ២៩ .-

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ ដែលខកខានមិនបានចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាត មានដូចតទៅ៖

- ប្រសិនបើអាក់ខានមិនបានចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាត១ (មួយ) លើកត្រូវទទួលការក្រើនរំឭកពីប្រធានក្រុមប្រឹក្សាឃុំ
- ប្រសិនបើអាក់ខានមិនបានចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាត២ (ពីរ) លើកជាប់ៗគ្នា ត្រូវទទួលការព្រមានដោយមានចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ
- ប្រសិនបើអាក់ខានមិនបានចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាត៣ (បី) លើកជាប់ៗគ្នា ត្រូវទទួលនូវការស្ដីបន្ទោសជាលាយលក្ខណ៍អក្សរ ហើយកាត់បន្ថយប្រាក់បំណាច់ចំនួនពាក់កណ្ដាល ឬទាំងអស់បន្ទាប់ពីមានការសម្រេចយល់ព្រមឱ្យកាត់ប្រាក់បំណាច់ពីអភិបាលរាជធានី ខេត្តសាមីដែលជាតំណាងឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រកាសព័ត៌មានជូនដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។
- ប្រសិនបើអាក់ខានចូលរួមប្រជុំដោយគ្មានច្បាប់អនុញ្ញាតចាប់ពី៤ (បួន) លើក ជាប់ៗគ្នា ឡើងទៅក្រុមប្រឹក្សាឃុំ ត្រូវធ្វើការពិភាក្សាដើម្បីសម្រេចបញ្ឈប់ពីតំណែងតាមសំឡេងភាគច្រើនដាច់ខាតនៃក្រុមប្រឹក្សាទាំងមូល។

ប្រធានក្រុមប្រឹក្សាឃុំតានៃ ត្រូវចាត់ចែងធ្វើនូវរាល់ឯកសារនៃការក្រើនរំឭក ការព្រមាន ការស្ដីបន្ទោស និងការបញ្ឈប់ពីតំណែងឱ្យបានដល់សមាជិកក្រុមប្រឹក្សាឃុំ ដែលត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យ។

ប្រការ៣០ .-

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ ក្នុងអំឡុងពេលកិច្ចប្រជុំ មានដូចតទៅ ៖

- ក្រើនរំឭក
- ក្រើនរំឭកដោយចុះក្នុងកំណត់ហេតុ
- ស្ដីបន្ទោសជាលាយលក្ខណ៍អក្សរ
- កាត់ប្រាក់បំណាច់ចំនួនពាក់កណ្ដាល ឬទាំងអស់
- បញ្ឈប់ពីតំណែង។

ប្រការ៣១ .–

អធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាឃុំត្រូវក្រើនរំឭកចំពោះវាគ្មិន ឬសមាជិកក្រុមប្រឹក្សាឃុំ ណាដែលប្រព្រឹត្តខុសពីលក្ខខណ្ឌដែលមានចែងក្នុងប្រការ១៧ នៃបទបញ្ជាផ្ទៃក្នុងនេះ។

ប្រការ៣២ .–

សមាជិកក្រុមប្រឹក្សាឃុំ ដែលត្រូវទទួលការក្រើនរំឭក១ (មួយ) ដង ហើយនៅតែប្រព្រឹត្តខុសឆ្គងថែមទៀតក្នុងពេលប្រជុំតែមួយ អធិបតីនៃអង្គប្រជុំត្រូវក្រើនរំឭកម្តងទៀត និងត្រូវចុះក្នុងកំណត់ហេតុ នៃកិច្ចប្រជុំអំពីការក្រើនរំឭកនោះ។

ប្រការ៣៣ .–

ត្រូវធ្វើការស្តីបន្ទោសជាលាយលក្ខណ៍អក្សរចំពោះសមាជិកក្រុមប្រឹក្សាឃុំ ណាដែល៖

- អធិបតីនៃអង្គប្រជុំបានក្រើនរំឭក ព្រមទាំងចុះក្នុងកំណត់ហេតុរួចហើយនូវការក្រើនរំឭកនោះតែមិនរាងចាល។
- អធិបតីនៃអង្គប្រជុំបានធ្វើការក្រើនរំឭកចំនួន៣ (បី) ដង ហើយតែនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់លើកបន្ទាប់នៅតែបន្តប្រព្រឹត្តខុសដដែល។
- បង្កការច្របូកច្របល់ ឬនាំអាទិ៍ដល់សមាជិកក្រុមប្រឹក្សាឃុំ ផ្សេងទៀតឱ្យបង្កការច្របូកច្របល់ក្នុងកិច្ចប្រជុំ។
- ជេរប្រមាថមើលងាយ ឬបង្កជម្លោះឬគំរាមកំហែងសមាជិកក្រុមប្រឹក្សាដទៃទៀត។

ប្រការ៣៤ .–

ត្រូវហាមចូលរួមប្រជុំចំនួន២ (ពីរ) លើក ជាប់ៗគ្នាចំពោះសមាជិកក្រុមប្រឹក្សាឃុំ រូបណាដែលទទួលការស្តីបន្ទោសហើយនៅតែមិនរាងចាល និងជេរប្រមាថមើលងាយអធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ។

ត្រូវហាមចូលរួមប្រជុំចំនួន៤ (បួន) លើក ជាប់ៗគ្នាចំពោះសមាជិកក្រុមប្រឹក្សាឃុំ រូបណាដែលជេរប្រមាថ មើលងាយថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

ត្រូវហាមចូលរួមប្រជុំ រហូតដល់សមត្ថកិច្ចបញ្ចប់ការស្រាវជ្រាវចំពោះសមាជិកក្រុមប្រឹក្សាឃុំ រូបណាដែលញុះញង់ឱ្យមានប្រើអំពើហិង្សាក្នុងកិច្ចប្រជុំ។

ប្រការ៣៥ .–

ហាមសមាជិកក្រុមប្រឹក្សាឃុំតានៃ និយាយកាត់នៅពេលដែលសមាជិកក្រុមប្រឹក្សាឃុំ ណាម្នាក់កំពុងមានមតិយោបល់ និងហាមការនិយាយវាយប្រហារចំពោះបុគ្គល និងសម្តែងអាកប្បកិរិយាដែលនាំឱ្យខូចសណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ។

ប្រការ៣៦ .–

ការក្រើនរំឭក ការស្តីបន្ទោស និងការព្រមានជាលាយលក្ខណ៍អក្សរ ព្រមទាំងការបញ្ឈប់ពីតំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ ណាម្នាក់ ត្រូវធ្វើតាមវិធីបោះឆ្នោតជាសម្ងាត់ដោយយកសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ដូចមានគំរូសន្លឹកឆ្នោតជូនភ្ជាប់មកជាមួយ។